កេចសេចក្ត

ភ្លេងកោះកុង
លើកទី២

ប្រធានពន្យល់

93

ជាជំនួយដល់សិស្សានុសិស្សនៅថ្នាក់មធ្យមសិក្សា

កាន់ ចាន់ណារ៉ា និង រ៉ាន់ ឌី

www.elibraryofcambodia.org

www.elibraryofcambodia.org

ក្រសួងបណ្ណាល័យហ៊ុន សែន ទុកជាឯកសារ

តែងសេចក្តី

១

ប្រធានពន្យល់

00026787

HUN SEN LIBRARY
R U P P

អ្នករៀបរៀង៖ កាន់ ចាន់ដារ៉ា និង ភ័ន្ត រ៉ី

អ្នកត្រួតពិនិត្យអក្ខរាវិរុទ្ធ៖ វណ្ណ ណែន

© រក្សាសិទ្ធិគ្រប់យ៉ាងដោយអ្នកនិពន្ធ, បោះពុម្ពលើកទី១ ឆ្នាំ ២០១២, បោះពុម្ពលើកទី២ ខែមករា ឆ្នាំ២០១៥

ISBN-1: 9789996375002

www.elibraryofcambodia.org

មាតិកា

អារម្ភកថា.....ii

ដូចម្តេចដែលហៅថា តែងសេចក្តី?.....១

វិធីសាស្ត្រនៃការបង្រៀននិងរៀនតែងស្រ្ទេចក្តី.....២

ប្រភេទប្រធានតែងសេចក្តី.....២១

ប្រធានអត្ថាធិប្បាយ.....២២

ប្រធានពន្យល់.....២៥

ប្រធានគំរូ.....៣៩

ប្រធានតែងសេចក្តីដែលធ្លាប់ចេញក្នុងការប្រឡង.....១៦៥

www.elibraryofcambodia.org

អារម្ភកថា

ការសរសេរតែងសេចក្តីឱ្យបានល្អពុំមែនជារឿងពិបាកទេ តែក៏ពុំមែនជារឿងងាយស្រួលប៉ុន្មានដែរ។

បើគ្រាន់តែមានគំនិតឬចំណេះដឹងទូទៅ ហើយមិនទាន់ចេះវិធីធ្វើតែងសេចក្តី គេក៏ពិបាកនឹងសរសេរឱ្យបានល្អដែរ។ ហេតុនេះ គេចាំបាច់ត្រូវចេះពីវិធីក្នុងការសរសេរ ទើបធ្វើឱ្យការសរសេរមានលក្ខណៈល្អប្រសើរតាមក្បួនខ្នាត ដោយមិនចាប់ចុងប្រយុងដើម។

ទន្ទឹមគ្នានេះ ដើម្បីសរសេរឱ្យបានល្អ គេចាំបាច់បង្កើតទម្លាប់សរសេរនិងអានឱ្យបានច្រើន។ ការហាត់ធ្វើតែងសេចក្តីឱ្យបានច្រើនជាការបណ្តុះទឹកដៃនៃការសរសេរ ហើយការ

www.elibraryofcambodia.org

អានច្រើនជាជំនួយដល់ការសរសេរព្រោះអាចផ្តល់នូវចំណេះដឹងទូលាយ។

ក្នុងសៀវភៅនេះជាឯកសារជំនួយដល់ការសិក្សាខ្លះៗប៉ុណ្ណោះ ពោលគឺពុំមែនជាពុម្ពគំរូដ៏ត្រឹមត្រូវឥតខ្ចោះនោះទេ។ យើងសង្ឃឹមថា នឹងមានអ្នកយល់ដឹងជ្រៅជ្រះផ្នែកនេះស្រាវជ្រាវបន្ថែមទៀត ដើម្បីបានជាពន្លឺដល់អ្នកសិក្សាជំនាន់ក្រោយៗទៀត។

-ការធ្វើដំណើរដ៏វែងឆ្ងាយ គង់ចាប់ផ្តើមពីមួយជំហានដំបូង។-

ភ្នំពេញ ១៩ មករា ២០១៥
ការ ចាន់ដារ៉ា និង ភ្ន ន ី

បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ
បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យា

www.elibraryofcambodia.org

ដូចម្តេចដែលហៅថា តែងសេចក្តី?

តែងសេចក្តី គឺជាការសរសេរពន្យល់អំពីបញ្ហាក្នុងប្រធានចោទណាមួយឱ្យងាយស្តាប់ងាយយល់ ដោយសេចក្តីពន្យល់នោះក្បោះក្បាយ ទូលំទូលាយ ឬខ្លីទេ តែច្បាស់លាស់អាចធ្វើឱ្យអ្នកអានឆាប់យល់ន័យសេចក្តីបាន។

ប្រសិនបើយើងយកតែងសេចក្តីមកប្រៀបធៀបនឹងខ្លួនមនុស្សយើងគ្រប់គ្នា យើងនឹងឃើញថា តែងសេចក្តីដូចគ្នាបេះបិទនឹងរូបរាងកាយរបស់មនុស្សនេះឯង ពោលគឺរូបរាងកាយរបស់មនុស្សមានក្បាល ដងខ្លួន និងដៃជើង។

រូបរាងកាយមនុស្សគឺជាការតាក់តែងរបស់ធម្មជាតិ ចំណែកឯតែងសេចក្តីវិញគឺជាការតាក់តែងរបស់មនុស្ស។

www.elibraryofcambodia.org

វិធីសាស្ត្រនៃ
ការបង្រៀននិងរៀនតែងសេចក្តី

១- គួរនាទីមុខវិជ្ជាតែងសេចក្តី

តែងសេចក្តី គឺជាផ្នែកអនុវត្តមួយដ៏សំខាន់នៃមុខវិជ្ជាអក្សរសិល្ប៍ បង្រៀននៅសាលារៀន។ ដូចជាមុខវិជ្ជាដទៃទៀតដែរ មុខវិជ្ជាអក្សរសិល្ប៍ក្រៅពីមានមុខងារអប់រំសតិអារម្មណ៍ និងផ្តល់ពុទ្ធិ នៅមានមុខងារសំខាន់មួយទៀត គឺហ្វឹកហាត់សមត្ថភាពប៉ិនប្រសប់ក្នុងការនិយាយស្តី ផ្តល់យោបល់ និងការសរសេរ។ នៅពេលណាដែលសតិអារម្មណ៍ និងពុទ្ធិបានក្លាយទៅជាសមត្ថភាពប៉ិនប្រសប់យ៉ាងស្ទាត់ជំនាញហើយនោះ ទើបគេអាចចាត់ទុកថាសតិអារម្មណ៍ និងពុទ្ធិមានលក្ខណៈរឹងមាំ។

មុខវិជ្ជាតែងសេចក្តី ពុំគ្រាន់តែជាប្រភេទមេរៀនអនុវត្តហ្វឹកហាត់តែទៅលើផ្នែកណាមួយនៃពុទ្ធិណាមួយនោះទេ តែវាបានប្រមូលផ្តុំរួមផ្សំនូវ

www.elibraryofcambodia.org

បណ្តាពុទ្ធិទាំងឡាយ ដែលនៅក្នុងនោះក៏មានពុទ្ធិអក្សរសិល្ប៍ និងជីវភាពរស់នៅផងដែរ។ ក្នុងការធ្វើតែងសេចក្តី សិស្សមិនត្រឹមតែត្រូវប្រមូលផ្តុំបញ្ញាស្មារតី ចំណេះដឹងរបស់ខ្លួនទាំងអស់ដែលខ្លួនមានមកលាតត្រដាងបង្ហាញ និងចេះដកស្រង់អត្ថន័យសំខាន់ៗពីអត្ថបទនេះ ឬអត្ថបទនោះប៉ុណ្ណោះទេ តែត្រូវមានសមត្ថភាពច្នៃប្រឌិត ស្វែងយល់ ត្រិះរិះ ពិភាក្សា និងពុទ្ធិប្រវត្តិអក្សរសិល្ប៍ ទ្រឹស្តីអក្សរសិល្ប៍ វេយ្យាករណ៍ ប្រវត្តិសាស្ត្រ នយោបាយ បច្ចុប្បន្នភាព និងជីវភាពរស់នៅជាក់ស្តែងថែមទៀត។

លទ្ធផលនៃការសិក្សាតែងសេចក្តីរបស់សិស្ស គឺជាម៉ែត្រសម្រាប់វាស់លទ្ធផលនៃការបង្រៀនរបស់សាស្ត្រាចារ្យ និងកម្រិតរៀនសូត្ររបស់សិស្សយ៉ាងច្បាស់លាស់។

ចំពោះវិស័យពង្រីកសមត្ថភាព ប្រភេទតែងសេចក្តីទាំងអស់សុទ្ធតែមានគោលបំណងហ្វឹក

www.elibraryofcambodia.org

ហ្វាត់របៀបនិយាយ របៀបសរសេរ របៀបដោះ
ស្រាយដល់សិស្ស។ ការហ្វឹកហ្វាត់សមត្ថភាព
នេះ គឺចង់ឱ្យសិស្ស៖

១. ចេះបរិយាយតាមសតិអារម្មណ៍ ការត្រិះរិះ
របស់ខ្លួនស្តីពីប្រធានបទណាមួយឱ្យបានច្បាស់
លាស់ និងងាយស្តាប់។

២. ចេះបញ្ចេញមតិ យោបល់ ដោយចេះលើក
យកភស្តុតាងបញ្ជាក់ផង។

៣. ចេះចោទបញ្ហា ចេះដោះស្រាយបញ្ហា និង
ចេះបូកសរុបបញ្ហា។

៤. ចេះសរសេរបង្ហាញពីសតិអារម្មណ៍ ការត្រិះ
រិះពិចារណាប្រកបដោយភាពត្រឹមត្រូវ និងមិន
ខុសពីក្បួនខ្នាតវេយ្យាករណ៍នៃភាសា។

www.elibraryofcambodia.org

២- វិធីសាស្ត្រនៃការធ្វើតែងសេចក្តី

តែងសេចក្តីជាកិច្ចការដ៏សំខាន់ចំពោះសិស្ស និស្សិត ឬមនុស្សភាគច្រើនគប្បីចេះ ដើម្បីប្រឡង ឬប្រើប្រាស់ក្នុងកិច្ចការផ្សេងៗទៀត។

ដើម្បីសរសេរតែងសេចក្តីឱ្យបានល្អជាទីចាប់ចិត្តដិតអារម្មណ៍របស់អ្នកអាន អ្នកស្តាប់ ឬអ្នកកែ អ្នកធ្វើតែងសេចក្តីត្រូវប្រកាន់ជំហរ និងធ្វើការងារចាំបាច់មួយចំនួនដូចខាងក្រោម៖

១- ជំហរសតិអារម្មណ៍ និងចិត្តគំនិត

សតិអារម្មណ៍ និងចិត្តគំនិតក្នុងពេលធ្វើតែងសេចក្តីមានសារៈសំខាន់ណាស់។ ដើម្បីឱ្យតែងសេចក្តីបានល្អ អ្នកធ្វើតែងសេចក្តីត្រូវមានជំហរម៉ឹងម៉ាត់ មិនតក់ស្លុតរញ៉ីរញ៉ូរបាត់ស្មារតី មិនប្រញាប់ប្រញាល់ពេក ដើម្បីជៀសវាងការបាត់បង់ភាពម្ចាស់ការ និងការភ្លេចភ្លាំង។

www.elibraryofcambodia.org

ក្នុងជំហានដំបូង អ្នកធ្វើតែងសេចក្តីគប្បីកត់ប្រធានតែងសេចក្តីនៅលើក្រដាសសស្អាតមួយ ដោយសរសេរច្បាស់ និងគោរពការដកឃ្លា ឬ ខណ្ឌសញ្ញាទៅតាមប្រធានដែលបានកត់នៅលើក្តារខៀន ហើយត្រូវជៀសវាងការបន្ថែមបន្ថយពាក្យសម្តីផ្ទាល់ខ្លួនទៅលើប្រធានដែលបានដាក់ឱ្យធ្វើ។ ការធ្វើយ៉ាងនេះមានសារៈសំខាន់ណាស់ដល់ជំហានក្រោយទៀត ដែលវានឹងអាចធ្វើឱ្យមានការខុសឆ្គង ឬភាន់ច្រឡំដល់អ្នកធ្វើតែងសេចក្តី ក្នុងករណីដែលមិនយកចិត្តទុកដាក់ពីបញ្ហានេះ។

២- សិក្សាប្រធាន

ក្នុងការធ្វើតែងសេចក្តី ស្ទើរពុំមែនគ្រាន់តែឃើញប្រធានរួចចាប់ផ្តើមសរសេរនោះទេ។ ពេលប្រឡងម្តងៗ គេឃើញមានសិស្សជាច្រើន

www.elibraryofcambodia.org

ស្រងាកចិត្ត និងសោកស្តាយយ៉ាងខ្លាំងក្រោយ ពេលដែលខ្លួនបានសរសេរតែងសេចក្តីចប់។ ការស្រងាកចិត្ត និងការសោកស្តាយបែបនេះ អាចបណ្តាលមកពីតែងសេចក្តីរបស់ខ្លួនបាន ឃ្លាតឆ្ងាយពីប្រធាន ឬកំចាកប្រធានតែម្តង។ កំហុសនេះដើមបំផុត មកពីអ្នកធ្វើតែងសេចក្តីពុំ បានសិក្សាប្រធាន និងពុំយល់ប្រធានឱ្យច្បាស់ លាស់ជាមុន។

តើត្រូវសិក្សាប្រធានដូចម្តេច?

មុនចាប់ផ្តើមសរសេរ អ្នកធ្វើតែងសេចក្តីត្រូវ សិក្សាប្រធានជាមុនសិន។ គេត្រូវអានប្រធាន អានហើយអានទៀតឱ្យបានច្រើនដង គួសពី ក្រោម ពាក្យសំខាន់ៗដែលពិបាកយល់ ឬជា ពាក្យគន្លឹះរបស់ប្រធាន។ ត្រូវចោទសួរនៅក្នុង ចិត្តខ្លួនឯងថា តើប្រធាននេះគេចង់និយាយពីអ្វី?

www.elibraryofcambodia.org

ជាប្រធានតែងសេចក្តីប្រភេទអ្វី? តើពាក្យគ្រង់ណាដែលសម្គាល់ជាប្រធានប្រភេទនោះ?

ការស្គាល់ប្រធានបានច្បាស់អាចឱ្យស្មេរធ្វើគម្រោងតែងសេចក្តីបានត្រឹមត្រូវ ហើយគំនិតដែលត្រូវលើកយកមកបរិយាយក៏សម្បូរបែប និងឆ្លើយតបទៅនឹងសំណូមពររបស់ប្រធាន។

៣- ការធ្វើគម្រោងតែង

ការធ្វើគម្រោងតែងជាការងារមួយចាំបាច់របស់អ្នកធ្វើតែងសេចក្តី។ ដូច្នេះ ការធ្វើគម្រោងតែងសេចក្តីជាការចាំបាច់ខានមិនបានចំពោះអ្នកធ្វើតែងសេចក្តី។

ក្រោយពីសិក្សាប្រធានតែងសេចក្តីបានយល់ច្បាស់ពីប្រភេទប្រធានហើយ អ្នកធ្វើតែងសេចក្តីគួរគិតទៅដល់គម្រោងតែងនៃប្រភេទតែងសេចក្តីនោះ។

www.elibraryofcambodia.org

ផ្នែកទាំងបីនៃតែងសេចក្តី

តាមធម្មតា តែងសេចក្តីទោះបីប្រភេទណាក្តី សុទ្ធតែមានផ្នែកទាំងបីសំខាន់ៗដូចខាងក្រោម៖

ក. សេចក្តីផ្តើម

ដូចម្តេចដែលហៅថា សេចក្តីផ្តើម? សេចក្តីផ្តើមជាសេចក្តីដំបូងដែលអ្នកតែងសេចក្តីត្រូវចាប់ផ្តើមសរសេរដើម្បីបង្ហាញប្រាប់ដល់អ្នកដទៃទៀត មានអ្នកអាន អ្នកស្តាប់ ពិសេសអ្នកកែថា យើងចង់និយាយអំពីអ្វី។

គេអាចនិយាយម្យ៉ាងទៀតថា សេចក្តីផ្តើមគឺជាពាក្យសម្តីនាំផ្លូវ ឬជាពាក្យអន្ទងឱ្យអ្នកដទៃទៀតតាមដាន ឬទៅជួបនឹងអ្វីដែលគេបានលើកឡើង តែពុំមែនជាការបកស្រាយនោះទេ។

សេចក្តីផ្តើមមានច្រើនបែបយ៉ាងណាស់ អាស្រ័យដោយអ្នកតែង និងទៅតាមប្រភេទនៃ

www.elibraryofcambodia.org

ប្រធានតែងសេចក្តីនីមួយៗផង។ គេពុំអាចមាន
សេចក្តីផ្តើមគំរូណាមួយសម្រាប់គ្រប់ប្រធានតែង
សេចក្តី និងគ្រប់ប្រភេទតែងសេចក្តីនោះទេ។
ដូច្នេះ ស្មេរមានសិទ្ធិសេរីភាពគ្រប់គ្រាន់ក្នុងការ
បរិយាយសេចក្តីផ្តើមនេះ។ និយាយនេះមិន
មែនមានន័យថា អ្នកធ្វើតែងសេចក្តីទៅតាម
ទំនើងចិត្តនោះទេ តែកត្តាសំខាន់យើងត្រូវចេះ
សរសេរយ៉ាងណាឱ្យទាក់ទាញនិងទាក់ទងទៅ
នឹងប្រធាន ដើម្បីឱ្យអ្នកអាន និងអ្នកស្តាប់ភ្ជាក់
អារម្មណ៍ចង់ដឹងចង់តាមដានតទៅទៀត។

<u>កំណត់សម្គាល់</u>៖ ជាទូទៅប្រភេទអត្ថាធិប្បាយត្រូវ
ផ្តើមដោយផ្អែកលើគោលការណ៍បីគឺ៖

- លំនាំបញ្ជា
- ចំណូលបញ្ជា

www.elibraryofcambodia.org

- ចំណោទបញ្ហា (ប្រែប្រួលតាមបែប
ប្រធាននីមួយៗ)

ក្នុងការធ្វើសេចក្តីផ្តើម យើងគួរជៀសវាង៖

- កុំផ្តើមចាកប្រធាន (មិនទាក់ទងនឹង
ប្រធាន)។
- កុំលើកយកគំនិតឥតខ្លឹមសារ ឬឥត
ប្រយោជន៍ដាក់នៅក្នុងសេចក្តីផ្តើម។
- កុំប្រើពាក្យបាលីសំស្ក្រិតច្រើន ប្រសិន
បើពាក្យនោះពុំមានតម្លៃចាំបាច់ទេ។
- កុំផ្តើមបែបរឿងប្រលោមលោកលន្លង់
លន្ធោចឥតប្រយោជន៍។
- កុំផ្តើមដោយស្រាយបញ្ហានៅក្នុងសេចក្តី
ផ្តើម។
- កុំផ្តើមវែង ឬខ្លីពេក (ប្រាំមួយ ឬប្រាំពីរ
បន្ទាត់បានហើយ)។

www.elibraryofcambodia.org

ខ. តួសេចក្ដី

តួសេចក្ដីគឺជាការវែកញែកបញ្ហាចោទសួរនៅក្នុងប្រធាន ដោយយកគោលគំនិតទាក់ទងមកបំបែកឱ្យល្អិត ហើយធ្វើការសំយោគឡើងវិញទៅតាមគោលការណ៍ជាហ្ការហ៊ និងទៅតាមវិធីសាស្ត្រប្រភេទប្រធាននោះ។

ដើម្បីសម្រេចបំណងនេះ អ្នកធ្វើតែងសេចក្ដីគួរដើរតាមគោលគំនិតដូចខាងក្រោម៖

- បើមានពាក្យពិបាកដែលជាគន្លឹះរបស់ប្រធាន អ្នកតែងគួរពន្យល់ពាក្យនោះសិន តែគួរលើកយកពាក្យមួយម៉ាត់ ឬពីរម៉ាត់មកពន្យល់បានហើយ (ការពន្យល់ពាក្យ មិនត្រូវបានធ្វើនៅគ្រប់តែប្រធាននោះទេ គឺចាំបាច់ ឬមិនចាំបាច់អាស្រ័យទៅលើប្រធានមានពាក្យពិបាក ឬពុំមាន)។

www.elibraryofcambodia.org

- ត្រូវយកអត្ថន័យដែលយើងបានទទួលពីការពន្យល់ពាក្យគន្លឹះទៅសម្រួលន័យដើម្បីជាការពន្យល់ន័យប្រធាន។

- បន្ទាប់មក អ្នកតែងត្រូវបកស្រាយពន្យល់ដោះស្រាយទៅតាមចំណុចនីមួយៗ ព្រមទាំងមានអំណះអំណាង ឬភស្តុតាងបញ្ជាក់ឱ្យបានច្បាស់លាស់។

- ការបរិយាយត្រូវគោរពតាមគម្រោងដែលយើងបានរៀបរាប់រួចមកហើយ។

- ពាក្យណាមិនច្បាស់កុំប្រើ ហើយកុំតែងប្រយោគវែងពេក។

- ត្រូវចេះប្រើពាក្យ ឬឃ្លាភ្ជាប់សេចក្តី ដើម្បីឱ្យការអធិប្បាយរបស់យើងជាប់ទាក់ទងគ្នា។

www.elibraryofcambodia.org

❖ ពាក្យភ្ជាប់សេចក្តី

ជាពាក្យប្រើសម្រាប់ភ្ជាប់សេចក្តីពីឃ្លាមួយទៅឃ្លាមួយទៀតនៅក្នុងវគ្គជាមួយគ្នា។ ពាក្យភ្ជាប់សេចក្តីមានដូចជា តែ, ប៉ុន្តែ, ក៏ប៉ុន្តែ, យ៉ាងណាមិញ, ទោះបីជាយ៉ាងណាក៏ដោយ, បើសិនជា, គួរគប្បី, ល្អ៉ីកណា, ល្អ៉ីកនោះ, ពេលណា, ពេលនោះ, ជាទូទៅ, យ៉ាងហោចណាស់, តាមធម្មតា, អាស្រ័យហេតុនេះ, ដូច្នេះ, យ៉ាងដូចនេះ, ម្យ៉ាងទៀត, លើសពីនេះ, ជាងនេះទៅទៀត ...។

❖ ឃ្លាភ្ជាប់សេចក្តី

ជាឃ្លាប្រើសម្រាប់ភ្ជាប់សេចក្តីពីវគ្គមួយទៅវគ្គមួយ ឬពីកថាខណ្ឌមួយទៅកថាខណ្ឌមួយទៀត ដើម្បីកុំឱ្យអ្នកអានអ្នកស្តាប់ ពិសេសអ្នកកែ មានការភ្ញាក់ផ្អើល ឬពុំយល់ថា ហេតុអ្វីបាន

www.elibraryofcambodia.org

ជាយើងលើកយកមតិមួយថ្មីទៀតមកសរសេរ
បរិយាយ។

ឃ្លាភ្ជាប់សេចក្ដីមានដូចជា៖

- ដើម្បីជាជំនួយដល់ការបកស្រាយពំនោល
ខាងលើ យើងគប្បីពន្យល់ពាក្យ.....ជាមុនសិ
ន។

- រួចមកហើយ យើងអត្ថាធិប្បាយអំពី.....ត
ទៅនេះយើងនឹងលើកយក...មករៀបរាប់។

- យើងទើបនិយាយពី.....ឥឡូវយើងនិយាយ
ពី.....ម្តង។

- កន្លងមកយើងបានឃើញ.....ឥឡូវនេះ
យើងនឹងលើកយក.....មកបង្ហាញបញ្ជាក់។

- ដើម្បីបញ្ជាក់បញ្ជានេះឱ្យកាន់តែច្បាស់
ថែមទៀត យើងនឹងលើកយក..... មកបញ្ជាក់
បន្ថែម .....។ល។

www.elibraryofcambodia.org

គ. សេចក្តីបញ្ជាប់

សេចក្តីបញ្ជាប់ គេហៅបានច្រើនយ៉ាង ដូចជា *យោបល់បញ្ជាប់, សេចក្តីបឆ្លើយ, យោបល់រួម ឬ សេចក្តីសន្និដ្ឋានរួម* ជាដើម។

សេចក្តីបញ្ជាប់ ជាផ្នែកមួយដែលឱ្យតម្លៃលើបញ្ហាដែលបានវែកញែករួចហើយ ព្រមទាំងបញ្ជាក់ដោយមតិយើងជាអ្នកតែងផ្ទាល់ផង ដើម្បីឱ្យតែងសេចក្តីរបស់យើងមានវិសេសភាពឡើង។

ក្នុងការបញ្ជាប់តែងសេចក្តី យើងគួរគោរពតាមគោលការណ៍ដូចតទៅនេះ៖

- ត្រូវឆ្លើយឱ្យចំ និងសម្រេចឱ្យច្បាស់លាស់ទៅលើសំណួរដែលប្រធានបានចោទ។
- គួរជៀសវាងបញ្ជាប់សេចក្តីដោយលើកយកបញ្ហាថ្មីមួយទៀតមកចោទជាបញ្ហាដែល

www.elibraryofcambodia.org

អាចនឹងធ្វើឱ្យមានបញ្ហានៅសេសសល់ហាក់
បីដូចជាតែងសេចក្តីរបស់យើងនៅមិនទាន់ចប់។

- យោបល់បញ្ចប់ គឺជាគំនិតផ្ទាល់ខ្លួន ដែល
មានលក្ខណៈអត្តនោម័តម៉ឹងម៉ាត់ ច្បាស់លាស់
ពុំមែនជាការនិយាយស្ទាក់ស្ទើរមិនដាច់ស្រេច
នោះទេ។

- យោបល់បញ្ចប់ដែលត្រឹមត្រូវ ត្រូវឈរលើ
គោលការណ៍ពីរយ៉ាងគឺ *ការយកតម្លៃប្រជាន* និង
មតិផ្ទាល់ខ្លួន។

ចំណុចមួយចំនួនដែលអ្នកធ្វើតែងសេចក្តីគួរ
យកចិត្តទុកដាក់ក្រៅពីវិធីសាស្ត្រដូចបានរៀប
រាប់ខាងលើ អ្នកធ្វើតែងសេចក្តីត្រូវយកចិត្តទុក
ដាក់លើចំណុចដូចខាងក្រោម៖

- សរសេរអក្សរឱ្យស្អាត ច្បាស់ៗ និងមានស
ណ្តាប់ធ្នាប់។

មន្ទីរសៀវភៅ ហ៊ុន សែន
HUN SEN LIBRARY

www.elibraryofcambodia.org

- ជៀសវាងសរសេរអក្សរកាត់។

- ការសរសេរអក្សរ និងការប្រើវណ្ណយុត្តិត្រូវសរសេរឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។

- ត្រូវចេះប្រើប្រាស់ឃ្លាប្រយោគតាមក្បួនវេយ្យាករណ៍ ដូចជា ឃ្លាល្អ: ចុះបន្ទាត់ និងដើមបន្ទាត់។

- កុំសរសេរជារបៀបមេរៀនមានចំណងជើងតូចធំ។

- កុំដាក់លេខរៀងសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់។

៤- វិធីសាស្ត្រសង្ខេបក្នុងការធ្វើតែងសេចក្តី

- ត្រូវអានប្រធានឱ្យបានច្រើនដងច្រើនសារ រួចគិតវិភាគលម្អិតលើពាក្យនីមួយៗឱ្យយល់សព្វគ្រប់។

www.elibraryofcambodia.org

- ត្រូវកំណត់ប្រភេទប្រធានឱ្យច្បាស់ (មើលពាក្យចោទសួរ ឬពាក្យបង្គាប់បញ្ជា តើជាប្រភេទប្រធានពន្យល់ ឬពិភាក្សា ឬប្រៀបធៀប)។

- ត្រូវជ្រើសរើសពាក្យមកពន្យល់ (ពាក្យគន្លឹះ) ពន្យល់ន័យរបស់ប្រធាន ឬក៏ត្រូវរកពាក្យសំខាន់ៗមកពន្យល់ទោះតិចក្តី ច្រើនក្តី។

- ត្រូវកំណត់ព្រំដែននៃការបកស្រាយត្រឹមណា ក្នុងសង្គម ឬក្នុងអក្សរសិល្ប៍ ឬក៏ទាំងពីរតែម្តង (សម្គាល់លើពាក្យបង្គាប់បញ្ជាក្នុងប្រធាន ឬន័យសេចក្តីក្នុងប្រធានដែលចោទ "ហាមបកស្រាយហួសព្រំដែន")។

- ត្រូវជ្រើសរើសគោលគំនិតសំខាន់ៗ "គំនិតធំ" រួចបំបែកជា "គំនិតតូចៗ" ដោយភ្ជាប់នឹងភស្តុតាងដែលជាឧទាហរណ៍បញ្ជាក់។ (ចំពោះ

www.elibraryofcambodia.org

ប្រធានពន្យល់ គំនិតធំមានតែមួយ ឯប្រធាន
ពិភាក្សាគំនិតធំមានពីរ គឺស្របមួយផ្ទុយមួយ)។

- ត្រូវធ្វើយោបល់បញ្ចាប់បណ្តា ៖អាសន្ន
យ៉ាងខ្លីមួយ (ប្រធានខុស ឬត្រូវ ឬខុសផងត្រូវ
ផងជាដើម)។ ពេលកែសេចក្តីព្រាងរួច ត្រូវសរ
សេរកិច្ចការតែម្តង កុំបង្ខង់យូរឱ្យសោះ)។

- ឃ្លាប្រយោគមិនត្រូវសរសេរគ្មានរបៀប
មើលមិនយល់ថាសរសេរពីរឿងអ្វីនោះឡើយ។

www.elibraryofcambodia.org

ប្រភេទប្រធានតែងសេចក្តី

តែងសេចក្តីត្រូវគេបែងចែកជាច្រើនប្រភេទ ដុសៗគ្នាអាស្រ័យលើខ្លឹមសារ គោលបំណង និងកម្រិតយល់ដឹងរបស់អ្នកតែងសេចក្តី។ ក្នុងចក្រគេបែងចែកតែងសេចក្តីដូចខាងក្រោម៖

១. អត្ថាធិប្បាយ

ប្រធាននេះ គេចែកជា៖

- អត្ថាធិប្បាយពន្យល់
- អត្ថាធិប្បាយពិភាក្សា
- អត្ថាធិប្បាយប្រៀបធៀប
- អត្ថាធិប្បាយនិទស្សន៍...

២. ពណ៌នាកថា

៣. និទានកថា

៤. កំណត់ហេតុ

៥. របាយការណ៍

៦. សុន្ទរកថា

៧. អត្ថាធិប្បាយនយោបាយ

៨. លិខិតឆ្លើយឆ្លង

www.elibraryofcambodia.org

ប្រធានអត្ថាធិប្បាយ

ពាក្យ *អត្ថាធិប្បាយ*មកពីពាក្យបាលីថា *អត្ថ* «*ប្រយោជន៍ ឬសេចក្តី*» ឬកន្លឹង *អធិប្បាយ* «ការពន្យល់ដោយមានគ្រឿងអាង ឬភស្តុតាង»។

ដូច្នេះពាក្យនេះអាចមានន័យថា ជាការពន្យល់សេចក្តីដោយមានអំណះអំណាងត្រឹមត្រូវ ឬជាការពន្យល់ដ៏មានប្រយោជន៍ដោយលើកយកទ្រឹស្តី ភស្តុតាង ហេតុផល ដើម្បីបំភ្លឺពីបញ្ហាណាមួយក្នុងបំណងធ្វើឱ្យអ្នកអាន អ្នកស្តាប់យល់ច្បាស់ យល់ត្រូវ និងមានអាកប្បកិរិយាត្រឹមត្រូវចំពោះបញ្ហានោះ។

តាមការសង្កេត [illegible]
ប្រធានអត្ថាធិប្បាយ[illegible]

១. ប្រធានអក្សរ[illegible] ជាឃ្លាន[illegible]
នឹងបញ្ជាអក្សរសិលា[illegible]

www.elibraryofcambodia.org

- ចូររៀបរាប់ពីការបង្ហាញតួអង្គនៅក្នុងអក្សរសិល្ប៍។
- អ្នកខ្លះថាទុំស្លាប់ព្រោះរឿងស្នេហា ឯខ្លះថាទុំស្លាប់ព្រោះទំនាយគ្រូ។ តើអ្នកយល់យ៉ាងណា?

២. ប្រធានចរិយាសាស្ត្រ និងប្រធានទូទៅ៖ ច្រើនលើកឡើងពីសុភាសិត ច្បាប់អប់រំផ្សេងៗ ឬក៏បញ្ហាទូទៅ។ ឧទាហរណ៍៖

- ចូរពន្យល់សុភាសិត «ចេះពីរៀន មានពីរក»។
- គេថា៖ «យុវជនជាអនាគតនៃប្រទេសជាតិ»។

៣. ប្រធានទស្សនវិជ្ជា៖ ជាប្រធានទាក់ទងនឹងទស្សនវិជ្ជា។ ឧទាហរណ៍៖

- គេពោលថា "ការងារជាសេរីភាព"។ តើអ្នកយល់ដូចម្តេច?
- គេតែងពោលថា "ជីវិតគឺជាការតស៊ូ"។ ចូរស្រាយបំភ្លឺ។

www.elibraryofcambodia.org

ក្រៅពីការបែងចែកខាងលើនេះ គេតែងបែងចែកប្រធានអត្ថាធិប្បាយជាបីឬបួនលក្ខណៈគឺ៖

១. អត្ថាធិប្បាយពន្យល់

២. អត្ថាធិប្បាយពិភាក្សា

៣. អត្ថាធិប្បាយនិទស្សន៍

៤. អត្ថាធិប្បាយប្រៀបធៀប(ពេលខ្លះ គេបញ្ចូលប្រធានប្រៀបធៀបក្នុងប្រធានពន្យល់និងពិភាក្សា ដោយមិនបែងចែកជាប្រភេទដទៃបែបនេះទេ)។

ប្រធានអត្ថាធិប្បាយមានសារៈសំខាន់គ្រប់សម័យកាល។ ក្នុងកូនសៀវភៅនេះ យើងនឹងលើកយកប្រធានពន្យល់មកបរិយាយជាមុនសិន ហើយក្នុងសៀវភៅក្រោយៗ យើងនឹងចង្ហាញប្រធានអត្ថាធិប្បាយផ្សេងៗទៀត។

www.elibraryofcambodia.org

ប្រធានពន្យល់

១. តើប្រធានពន្យល់ជាអ្វី?

ប្រធានពន្យល់ជាប្រធានអត្ថាធិប្បាយមួយ បែបដែលតម្រូវឱ្យអ្នកធ្វើតែងសេចក្តីត្រូវពន្យល់ នូវអ្វីដែលគេសួរក្នុងប្រធាន ដើម្បីឱ្យអ្នកឯទៀតយល់។

ពាក្យ "ពន្យល់" មានន័យថា ធ្វើឱ្យគេយល់។ ក្នុងការពន្យល់អ្នកធ្វើតែងសេចក្តីត្រូវខិតខំ ពន្យល់បកស្រាយពីមតិរបស់ប្រធានទៅតាមបញ្ហា ឬទស្សនៈដែលគេទាមទារឱ្យពន្យល់។

ជាទូទៅប្រធានប្រភេទនេះ ភាគច្រើនតម្រូវឱ្យយើងពន្យល់ទស្សនៈ ពាក្យស្លោក សុភា សិតសិលធម៌សង្គម ខ្លឹមសារ ឧត្តមគតិ ឬគុណកថាណាមួយ ដែលជួនកាលមានលក្ខណៈសាកលមានន័យសមស្របទៅហើយ គ្រាន់តែ ឱ្យយើង

www.elibraryofcambodia.org

បំផុសបង្ហាញ ពន្យល់ពង្រីកសេចក្តីតែ ប៉ុណ្ណោះ គឺពុំមែនវែកញែករកខុសរកត្រូវដូចប្រធានពិភាក្សាទេ។

ការសរសេរទៀតសោត ត្រូវបកស្រាយលើប្រធានទាំងមូល ឬបែងចែកជាវគ្គខ្លីៗតាមអន្លើ ដើម្បីពន្យល់ប្រាប់គេទៅតាមគំនិតរបស់ខ្លួនដែលចង់ប្រាប់ ព្រមទាំងលើកយកឧទាហរណ៍ផ្សេងៗមកបញ្ជាក់ឱ្យបានច្បាស់លាស់។ ចំពោះអំណះអំណាងវិញ ត្រូវចេះជ្រើសយកខ្លីៗ កុំឱ្យវែងអន្លាយពេក។

យើងត្រូវពន្យល់ពីគំនិតមិនសូវសំខាន់ ទៅដល់សំខាន់ ឬពីគំនិតសំខាន់ទៅគំនិតមិនសូវសំខាន់ ហើយឆ្លងពីគំនិតមួយទៅគំនិតមួយ ត្រូវមានឃ្លាភ្ជាប់សេចក្តី និងត្រូវផ្តុំចងក្រងគំនិតធំៗ។ បន្ទាប់ពីពន្យល់គំនិតនីមួយៗរួចហើយ

www.elibraryofcambodia.org

យើងត្រូវផ្ចុំគំនិតទាំងនោះ និងពន្យល់សរុបជាចុងក្រោយ។

២. លក្ខណៈនៃប្រធានពន្យល់

តើគេអាចស្គាល់ប្រធានពន្យល់បានដោយរបៀបណា?

គេអាចដឹងថាប្រធានមួយជាប្រធានពន្យល់ដោយសារតែគេអាចសង្កេតឃើញពាក្យចោទសួរ និងពាក្យបង្គាប់ឱ្យដោះស្រាយនៅក្នុងប្រធាននោះ។

ក. ពាក្យចោទសួរ

ពាក្យចោទសួរមួយចំនួនខាងក្រោមនេះអាចបញ្ជាក់ថា ប្រធានមួយជាប្រធានពន្យល់ៃ

.....ដូចម្តេច?

.....ដូចម្តេចខ្លះ?

.....យ៉ាងណាខ្លះ?

www.elibraryofcambodia.org

.....ប៉ុន្មានយ៉ាង?

.....អ្វីខ្លះ?

.....បែបណាខ្លះ?

ខ. ពាក្យបង្គាប់បញ្ជា

ពាក្យបង្គាប់បញ្ជាខាងក្រោមនេះអាចបញ្ជាក់ថា ប្រធានមួយជាប្រធានពន្យល់ៃ

ចូរពន្យល់.....។

ចូរបកស្រាយ.....។

ចូរស្រាយបំភ្លឺ.....។

ចូរស្រាយបញ្ជាក់.....។

ចូរអធិប្បាយ.....។

ចូររៀបរាប់.....។

ចូរបង្ហាញ.....។

ចូរលាតត្រដាង.....។

ចូរគូសបញ្ជាក់.....។

www.elibraryofcambodia.org

ចម្លុះបញ្ជាំង.....។

ចូរវិភាគ..... (តួអង្គ និងអក្សរសិល្ប៍)។

៣. គម្រោងសង្ខេបនៃប្រធានពន្យល់

១. សេចក្តីផ្តើម

- លំនាំបញ្ហា
- ចំណូលបញ្ហា
- ចំណោទបញ្ហា

២. តួសេចក្តី

ក. ឃ្លាភ្ជាប់សេចក្តី និងពន្យល់ពាក្យ

ខ. ពន្យល់នយប្រធាន

គ. បំណកស្រាយប្រធាន

គំនិតគាំទ្រទី១៖ ឧ.....

គំនិតគាំទ្រទី២៖ ឧ.....

គំនិតគាំទ្រទី៣៖ ឧ.....។ល។

ឃ. សរុប

៣. សេចក្តីបញ្ចប់

www.elibraryofcambodia.org

- ភាយតម្លៃប្រធាន
- មតិផ្ទាល់ខ្លួន

៤. គម្រោងលម្អិតនៃប្រធានពន្យល់

១. សេចក្តីផ្តើម

ក. លំនាំបញ្ហា៖

ជាការនាំឱ្យគេស្គាល់បញ្ហា ពោលគឺអ្នកសរសេរគប្បីនាំអ្នកអានឱ្យដឹងជុំវិញបញ្ហាប្រធាន តែពុំមែនជាការបកស្រាយទេ។ អ្នកសរសេរអាចនិយាយអំពីសង្គមរស់នៅ រួចអាចនិយាយអំពីអក្សរសិល្ប៍ម្តង (ឬចំណេះដឹងទូទៅទាក់ទងនឹងប្រធាន)។

ខ. ចំណូលបញ្ហា៖

ជាការបង្ហាញនូវបញ្ហារបស់ប្រធាន គឺលើកឡើងពីមតិរបស់ប្រធាន ហើយអ្នកនឹងបង្ហាញពី

www.elibraryofcambodia.org

មតិរបស់ប្រធាន គេអាចប្រើឃ្លាភ្ជាប់សេចក្តីមួយចំនួនដូចជា៖

- *អាស្រ័យហេតុនេះហើយបានជាមានមតិមួយបានអះអាងថា "មតិប្រធាន"។*
- *មូលហេតុនេះហើយទើប... "មតិប្រធាន"*
- *ហេតុនេះហើយបានជា... "មតិប្រធាន"*
- *អាស្រ័យហេតុនេះហើយទើប... "មតិប្រធាន"*

គ. ចំណោទបញ្ហា៖

នៅក្នុងចំណោទបញ្ហា អ្នកធ្វើតែងសេចក្តីត្រូវចោទសួរតាមលក្ខណៈរបស់ប្រធានពន្យល់ពោលគឺគេអាចចោទសួរដូចខាងក្រោម៖

- *តើមតិខាងលើនេះមានអត្ថន័យដូចម្តេចខ្លះ?*
- *តើទស្សនៈខាងលើនេះមានអត្ថន័យយ៉ាងណា?*
- *តើពំនោលខាងលើនេះមានអត្ថន័យយ៉ាងណាខ្លះ?*

HUN SEN LIBRARY
R.U.P.P.
www.elibraryofcambodia.org

- *តើមានមូលហេតុ(កត្តា, កស្តុតាង, ចំណុច)ណាខ្លះ ជានាមីតិ(យោបល់, គំនិត) ឬតួអង្គខាងលើ លើការឆ្លើងរបៃបនេះ?*

២. តួសេចក្តី

ក. ឃ្លាភ្ជាប់សេចក្តី និងពន្យល់ពាក្យគន្លឹះ

ក្នុងផ្នែកនេះ គេចាំបាច់ប្រើឃ្លាភ្ជាប់សេចក្តី ដើម្បីភ្ជាប់ពីផ្តើមសេចក្តីមកតួសេចក្តី រួចទើបគេពន្យល់ពាក្យគន្លឹះសំខាន់ៗដែលមាននៅក្នុងមតិប្រធាន។

ឃ្លាភ្ជាប់សេចក្តីដែលគេនិយមប្រើមាន៖

- *ដើម្បីបកស្រាយប្រធានខាងលើ យើងគប្បីយល់អត្ថន័យរបស់ពាក្យ "..." ជាមុនសិន។*
- *ដើម្បីជាជំនួយដល់ការបកស្រាយប្រធានខាងលើ ឲ្យកាន់តែច្បាស់លាស់និងស៊ីជម្រៅ យើងគប្បីយល់ពាក្យគន្លឹះរបស់ប្រធានជាមុនសិន។ ពាក្យ*

www.elibraryofcambodia.org

"..." មានន័យថា... ។ ឯពាក្យ "..." មានន័យថា... ចំពោះពាក្យ "..." វិញ មានន័យថា... ។

ដើម្បីបំភ្លឺប្រធានខាងលើ ឲ្យបានច្បាស់លាស់ យើងគួរយល់ន័យពាក្យគន្លឹះជាមុនសិន ។ ពាក្យ "..." មានន័យថា... ។

មុននឹងបង្ហាញ ឲ្យបានច្បាស់លាស់ទៅលើបញ្ហាប្រធានខាងលើ យើងគួរពន្យល់ពាក្យ "..." ជាមុនសិន ។ ចំពោះពាក្យ "..." មានន័យថា ... ។

មុននឹងបំភ្លឺបញ្ហាដែលបានចោទខាងលើ ឲ្យបានក្បោះក្បាយ យើងគប្បីពន្យល់ពាក្យ "..." ជាមុនសិន ។ ពាក្យ "..." មានន័យថា "..." ។ ចំណែកឯពាក្យ "..." មានន័យថា "..." រីឯពាក្យ "..." នោះវិញ សំដៅយកន័យថា "..." ។

ខ. ពន្យល់អត្ថន័យរបស់ប្រធាន៖

ក្នុងចំណុចនេះ អ្នកសរសេរគប្បីនិយាយតាមប្រធានឡើងវិញ ឬយកពាក្យដែលបានដក

www.elibraryofcambodia.org

ទៅពន្យល់មកបូកបញ្ចូលនឹងមតិប្រធាន ហើយ
សម្រួលន័យសេចក្ដីឱ្យសមស្រប មានអត្ថន័យ
អាចស្តាប់បានជាការស្រេច។

គេអាចប្រើឃ្លាមួយចំនួនដូចខាងក្រោម៖

- *ដូច្នេះមតិប្រធាន(គំនិត យោបល់ ទស្សនៈ...)*
  ដែលបានលើកឡើងខាងលើមានន័យថា"..."។

គ. បំណាកស្រាយប្រធាន៖

នៅក្នុងផ្នែកនេះ អ្នកសរសេរចាំបាច់បក
ស្រាយពន្យល់និងផ្តល់អំណះអំណាងនានាឱ្យ
ស្របនឹងប្រធានដែលគេដាក់ឱ្យ។

ក្នុងន័យដដែលនេះ អ្នកសរសេរចាំបាច់
ជ្រើសរើសយកគោលគំនិតសំខាន់ៗ ឱ្យបាន
ច្រើនតាមលទ្ធភាព(ទាក់ទងនឹងលក្ខណៈទូទៅ
សង្គម ឬអក្សរសិល្ប៍ជាដើម ហើយបើប្រធាន

www.elibraryofcambodia.org

មានលក្ខខណ្ឌច្បាស់លាស់ ត្រូវបកស្រាយតាមពាក្យបង្គាប់ទាំងនោះ)។

បន្ទាប់មកពង្រីកគោលគំនិតសំខាន់ៗឱ្យបានទូលំទូលាយ ដោយរកឧទាហរណ៍ជាភស្តុតាងមកបញ្ជាក់ជាសាក្សី ដោយនិយាយម្តងមួយចំណុចៗដូចខាងក្រោម៖

-គំនិតគាំទ្រទី១៖ ...

-គំនិតគាំទ្រទី២៖ ...

-គំនិតគាំទ្រទី៣៖ ...

ក្នុងចំណុចឧទាហរណ៍នីមួយៗ អ្នកសរសេរអាចប្រើពាក្យភ្ជាប់សេចក្តីមួយចំនួនដូចជា៖

- *ជាក់ស្តែង...*
- *ជាតឹកតាង...*
- *ជាគួយ៉ាង...*
- *ជាការពិត...*
- *យ៉ាងណាមិញ*

www.elibraryofcambodia.org

ង. សរុបមតិ

សរុបគឺជាផ្នែកមួយដែលគេត្រូវសរុបខ្លឹមសាររបស់តួសេចក្តីឱ្យខ្លីល្មម និងមានន័យគ្រប់តួសេចក្តីទាំងមូល។ ក្នុងចំណុចនេះគេអាចប្រើពាក្យ ឬឃ្លាភ្ជាប់សេចក្តីមួយចំនួនដូចជា៖

- *សរុបមក...។*
- *សរុបសេចក្តីទៅ...។*
- *រួមសេចក្តីមក...។*
- *ជារួមមក...។*

៣. សេចក្តីបញ្ជាប់

ក. រ៉ាយតម្លៃប្រធាន

គឺជាការឱ្យតម្លៃទៅលើប្រធានដែលគេបានសិក្សារួចមកហើយនៅខាងលើថា "មានខ្លឹមសារ ឬមានអត្ថន័យល្អ" ជាដើម ដោយមានបញ្ជាក់នូវហេតុផលផងដែរ។

www.elibraryofcambodia.org

ក្នុងចំណុចនេះ គេនិយមប្រើពាក្ស ឬឃ្លា ភ្ជាប់សេចក្តីមួយចំនួនដូចជា៖

- តាមការបកស្រាយមតិខាងលើ យើងឃើញថា ទស្សនៈនេះ មតិនេះ ឬពំនោលនេះ...។

- ឆ្លងតាមការបកស្រាយខាងលើ ដោយមានឧទាហរណ៍ផងនោះ យើងឃើញថា ...។

- ឆ្លងតាមការវិភាគខាងលើ យើងឃើញថា...។

- តាមការបកស្រាយមតិ ឬទស្សនៈខាងលើ បានបង្ហាញឱ្យឃើញថា...។

- ចំណុចទាំងអម្បាលម៉ានដែលបានអធិប្បាយរួចមកហើយខាងលើ បញ្ជាក់ថា...។

- សន្និដ្ឋានជារួមមក យើងអាចកំណត់បានថា....។

ខ. មតិផ្ទាល់ខ្លួន

ស្មេរគប្បីបញ្ចេញយោបល់ផ្ទាល់ខ្លួនទៅលើមតិរបស់ប្រធានឱ្យបានច្បាស់លាស់។ មតិនេះត្រូវស្ថិតនៅក្នុងគោលបំណងដ៏ប្រសើរមួយ គឺ

www.elibraryofcambodia.org

ឆ្ពោះទៅរកការអប់រំ ហើយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ និងការរីកចម្រើនជឿនលឿន។

ក្នុងចំណុចនេះ គេនិយមប្រើពាក្ស ឬឃ្លាភ្ជាប់សេចក្តីមួយចំនួនដូចជា៖

- *ដូច្នេះ...*
- *ដូច្នេះយើងជា...*
- *ដូច្នេះយើងម្នាក់ៗ...*
- *តាមការវាយតម្លៃ សន្និដ្ឋានខាងលើ យើងជា...*។

នៅផ្នែកខាងក្រោយនេះ យើងសូមលើកយកប្រធានគំរូមួយចំនួនសម្រាប់ជាជំនួយដល់អ្នកធ្វើតែងសេចក្តី។ សេចក្តីអធិប្បាយនៅក្នុងប្រធានទាំងនេះពុំមានជាពុម្ពគំរូនេះ គឺគ្រាន់តែជាឧទាហរណ៍ខ្លះៗសម្រាប់ការបកស្រាយប្រធានពន្យល់ ជាពិសេសសម្រាប់ការធ្វើតែងសេចក្តីនៅថ្នាក់មធ្យមសិក្សាប៉ុណ្ណោះ។

www.elibraryofcambodia.org

ប្រធានគំរូ

ប្រធានគំរូទី១

ការអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើនប្រកបដោយសុខសុវត្ថិភាព ពិតជាមិនអាចផ្តាច់ចេញពីការបណ្តុះបណ្តាលធនធានមនុស្សបានឡើយ។ ក្នុងស្ថានភាពបច្ចុប្បន្ន តើត្រូវបណ្តុះបណ្តាលធនធានមនុស្សឱ្យមានលក្ខណសម្បត្តិដូចម្តេច?

កម្រោងអធិប្បាយ

១-សេចក្តីផ្តើម៖

+លំនាំបញ្ហា៖ មនុស្សគឺជាកត្តាសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ

+ចំណូលបញ្ហា៖ អាស្រ័យហេតុនេះហើយ ទើបមានមតិមួយពោលថា " (ប្រធាន)"

www.elibraryofcambodia.org

+ចំណោទបញ្ហា៖ តើពំនោលខាងលើនេះមានអត្ថន័យដូចម្តេច ?

តើធនធានមនុស្សដែលត្រូវចូលរួមក្នុងការអភិវឌ្ឍជាតិ ត្រូវមានលក្ខណសម្បត្តិដូចម្តេចខ្លះ?

២-គូសេចក្តី៖

ក- ឃ្លាភ្ជាប់សេចក្តី និងពន្យល់ពាក្យ

- ការអភិវឌ្ឍ៖ ការរីកចម្រើនខ្លាំង ការលូតលាស់ក្រៃលែង។

- សុវត្ថិភាព៖ ភាពប្រកបដោយសេចក្តីសុខ។

- ធនធានមនុស្ស៖ មនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ពេញលេញ។

ខ-ពន្យល់ន័យប្រធាន៖ ប្រធាននេះចង់និយាយថា ការធ្វើឱ្យប្រទេសជាតិរីកចម្រើនប្រកបដោយ

www.elibraryofcambodia.org

ភាពសុខសាន្ត ចាំបាច់ត្រូវមានមនុស្សដែលមានសមត្ថភាពគ្រប់យ៉ាង។

គ- បំណាកស្រាយប្រធាន៖

ប្រទេសដែលមានធនធានធម្មជាតិច្រើន មិនប្រាកដថាជាប្រទេសអភិវឌ្ឍន៍នោះទេ ហើយប្រទេសដែលគ្មានធនធានធម្មជាតិក៏មិនប្រាកដថាជាប្រទេសអន់ថយនោះដែរ ជាអាទ៍ ប្រទេសជប៉ុន សិង្ហបុរី ....។

លក្ខណៈសម្បត្តិដែលត្រូវបណ្តុះបណ្តាលមាន៖

- កាយសម្បទារឹងមាំ (កីឡា)

- ប្រាជ្ញាវាងវៃ ប្រាជ្ញាសម្បទា (រៀន និងបង្រៀន)

- មានបំណិន និងឥរិយាបថល្អត្រឹមត្រូវ មានបទពិសោធ

www.elibraryofcambodia.org

- សីលធម្មទា (មានសីលធម៌រស់នៅល្អ)

- ចេះរស់នៅក្នុងសន្តិភាព និងចុះសម្រុងគ្នា

- សិទ្ធិ និងប្រជាធិបតេយ្យ

ឃ-សរុប៖

ក្នុងស្ថានភាពបច្ចុប្បន្ននេះ យើងគប្បីខិតខំបណ្តុះបណ្តាលធនធានមនុស្សឱ្យមានសមត្ថភាពទាំងផ្លូវកាយ ប្រាជ្ញា សីលធម៌ បំណិន ជីវិត និងជំនាញផ្សេងៗ។

៣- សេចក្តីបញ្ចប់៖

- ប្រធានខាងលើពិតជាត្រឹមត្រូវ ពីព្រោះធនធានមនុស្សជាកត្តាកំណត់រាល់ការអភិវឌ្ឍនានាក្នុងសង្គម។ មនុស្សអភិវឌ្ឍទៅមុខឥតឈប់ឈរ ខុសពីសត្វនានាដែលមានត្រឹមតែសភាវគតិ។

- ដើម្បីមានលទ្ធភាពចូលរួមក្នុងការកសាងជាតិ យើងជាកុលបុត្រកុលធីតាខ្មែរត្រូវខិតខំរៀន

www.elibraryofcambodia.org

សូត្រឱ្យមានសមត្ថភាព ចំណេះដឹង បទពិសោធ និងបំណិនច្បាស់លាស់ ។ អនក្ខភាពគឺជា ឧបសគ្គនៃការអភិវឌ្ឍ។ ក្នុងការរៀនសូត្រទៀត សោត យើងត្រូវធ្វើយ៉ាងណា ឱ្យមានការស៊ីចង្វាក់គ្នារវាងការរីកចម្រើនផ្លូវកាយ និងប្រាជ្ញា រវាងវិទ្យា សាស្ត្រ និងសីលធម៌ រវាងបុគ្គល និងសង្គម រវាងជាតិ និងអន្តរជាតិ ។

សេចក្តីអធិប្បាយ

មនុស្សគឺកោសិកាដ៏ចាំបាច់របស់សង្គម។ ប្រទេសជាតិនីមួយៗ ត្រូវការចាំបាច់នូវមនុស្ស ដែលមានចំណេះដឹង មានសមត្ថភាពសព្វបែប យ៉ាងដើម្បីអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន។ ដើម្បីទទួលបានមនុស្សដែលមានសមត្ថភាព គេ ចាំបាច់ត្រូវឆ្លងកាត់ការអប់រំជាមុនសិន។ ហេតុ

www.elibraryofcambodia.org

នេះហើយទើបមានពំនោលមួយពោលថា "ការអភិវឌ្ឍប្រទេសជាតិឲ្យរីកចម្រើនប្រកបដោយសុខសុវត្ថិភាព មិនអាចផ្តាច់ចេញពីការ បណ្តុះបណ្តាលធនធានមនុស្សបានឡើយ"។

តើពំនោលខាងលើនេះមានអត្ថន័យដូចម្តេច?

តើធនធានមនុស្សដែលត្រូវចូលរួមក្នុងការអភិវឌ្ឍជាតិ ត្រូវមានលក្ខណៈសម្បត្តិដូចម្តេចខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយមតិប្រធានខាងលើ យើងគួរយល់ពាក្យមួយចំនួនជាមុនសិន។ ពាក្យ *ការអភិវឌ្ឍ* មានន័យថាការរីកចម្រើនខ្លាំង ការលូតលាស់ក្រៃលែង។ រីឯពាក្យ *សុវត្ថិភាព* មានន័យថាភាពប្រកបដោយសេចក្តីសុខ។ ចំណែកពាក្យ *ធនធានមនុស្ស* វិញ សំដៅដល់មនុស្សដែលមានសមត្ថភាពគ្រប់

www.elibraryofcambodia.org

គ្រាន់ពេញលេញ។ ទស្សនៈប្រធាននេះចង់មាន
ន័យថា ការធ្វើឱ្យប្រទេសជាតិរីកចម្រើន
ប្រកបដោយភាពសុខសាន្ត ចាំបាច់ត្រូវមាន
មនុស្សដែលមានសមត្ថភាពគ្រប់យ៉ាង។
ប្រទេសដែលមានធនធានធម្មជាតិច្រើនមិន
ប្រាកដថា ជាប្រទេសអភិវឌ្ឍន៍នោះទេ ហើយ
ប្រទេសដែលគ្មានធនធានធម្មជាតិក៏មិនប្រាកដ
ថាជាប្រទេសអន់ថយនោះដែរ ជាអាទិ៍មាន
ប្រទេសជប៉ុន សិង្ហបុរីជាដើម។

គ្រប់ប្រទេសជាតិទាមទារឱ្យមានការអភិវឌ្ឍ
ជាប្រចាំ។ ដើម្បីអភិវឌ្ឍប្រទេសឱ្យរីកចម្រើនគេ
ត្រូវបណ្តុះបណ្តាលធនធានមនុស្សជាមុន និង
ជាប្រចាំ។ លក្ខណៈសម្បត្តិដែលត្រូវបណ្តុះប
ណ្តាលមានដូចជា ការធ្វើឱ្យកាយសម្បទារឹងមាំ
តាមរយៈការលេងកីឡា ការហាត់ប្រាណទៀង

www.elibraryofcambodia.org

ទាត់ ការបរិភោគអាហារដែលសម្ស្ករទៅដោយ
ជីវជាតិ និងមិនមានជាតិគីមីជាដើម។ ដើម្បីប
ណ្តុះបណ្តាលពលរដ្ឋឱ្យមានប្រាជ្ញាស្មារតីទាំង
ក្នុងការរៀន ទាំងការបង្រៀន គឺទាំងគ្រូទាំង
សិស្សត្រូវមានប្រាជ្ញាវាងវៃ។ គេត្រូវបណ្តុះឱ្យ
មានបំណិន និងឥរិយាបថល្អត្រឹមត្រូវ មានបទ
ពិសោធច្រើនទាក់ទងនឹងបញ្ហាសង្គម មានសីល
សម្បទាគឺមានសីលធម៌ល្អក្នុងការរស់នៅ ចេះ
រស់នៅក្នុងសន្តិភាព និងចុះសម្រុងគ្នានៅក្នុងស
ង្គម។ ទន្ទឹមគ្នានោះ គេក៏ត្រូវចេះគោរពសិទ្ធិ ចេះ
យោគយល់អធ្យាស្រ័យ អត់ឱនសណ្តាស
ប្រណី ដល់គ្នានិងគ្នា ស្រឡាញ់និងបង្កើត
មិត្តភាពរវាងគ្នានឹងគ្នាជាដើម។ ជាក់ស្តែងសង្គម
យើងសព្វថ្ងៃកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុង
ការបណ្តុះបណ្តាលធនធានមនុស្ស ដោយ

www.elibraryofcambodia.org

បង្កើតឱ្យមានសាលារៀនគ្រប់ទីកន្លែងទាំងរដ្ឋ និងឯកជន។ ការយកចិត្តទុកដាក់ចំពោះវិស័យកីឬាដោយបំផុសចលនាលេងកីឬាគ្រប់ប្រភេទ ធ្វើយ៉ាងណាឱ្យមានទាំងចំណេះដឹង ទាំងសុខភាព។ បើមើលតាមរយៈប្រវត្តិសម័យអង្គរ យើងឃើញថា សម័យនោះរីកចម្រើនដល់កម្រិតកំពូលក៏ដោយសារសម័យនោះសម្បូរទៅដោយធនធានមនុស្ស ដោយមានសាកលវិទ្យាល័យ ហើយព្រះនាងឥន្ទ្រទេវីជាសាកលវិទ្យាធិការិនី។

សរុបសេចក្តីមក ក្នុងស្ថានភាពបច្ចុប្បន្ន យើងត្រូវបណ្តុះបណ្តាលធនធានមនុស្សឱ្យមានគ្រប់សមត្ថភាពទាំងផ្លូវកាយ ប្រាជ្ញា សីលធម៌ និងបំណិន ឬជំនាញឱ្យបានពិតប្រាកដ។ ក្នុងការរៀនសូត្រទៀតសោត យើងត្រូវធ្វើយ៉ាងណាឱ្យមានការស៊ីចង្វាក់គ្នារវាងការរីកចម្រើនផ្លូវ

www.elibraryofcambodia.org

កាយនិងប្រាជ្ញា រវាងវិទ្យាសាស្ត្រនិងសីលធម៌ រវាងបុគ្គលនិងសង្គម រវាងជាតិនិងអន្តរជាតិ។

ឆ្លងតាមរយៈការបកស្រាយមកខាងលើ មតិប្រធានពិតជាត្រឹមត្រូវសមហេតុផល ព្រោះថាធនធានមនុស្សគឺជាកត្តាកំណត់នូវរាល់ការអភិវឌ្ឍក្នុងសង្គម។ មនុស្សអភិវឌ្ឍឥតឈប់ឈរ ខុសពីសត្វនានាដែលមានត្រឹមតែសភាវគតិ។ ដូច្នេះដើម្បីមានលទ្ធភាពចូលរួមក្នុងការកសាងជាតិ យើងជាកុលបុត្រកុលធីតាខ្មែរត្រូវខិតខំរៀនសូត្រឱ្យមានសមត្ថភាព ចំណេះដឹង បទពិសោធ ជំនាញច្បាស់លាស់ ព្រោះអនក្ខរភាពគឺជាឧបសគ្គនៃការអភិវឌ្ឍប្រទេសជាតិ។

www.elibraryofcambodia.org

ប្រធានគំរូទី២

> អ្នកសិក្សាស្នាដៃអក្សរសិល្ប៍មួយចំនួនបានទទួលស្គាល់ថា «អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងពីជីវភាពសង្គម បញ្ហាសង្គម និងអរិយធម៌នៃសង្គមមនុស្ស»។ តើទស្សនៈនេះមានអត្ថន័យដូចម្តេច? ចូរពន្យល់ដោយលើកឧទាហរណ៍ពីក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់ផង។

សេចក្តីអធិប្បាយ

អក្សរសិល្ប៍ជាផ្នែកមួយនៃអរិយធម៌នៃប្រជាជាតិនីមួយៗ ដែលកើតពីស្នាដៃរបស់ការ៉ែអ្នកនិពន្ធគ្រប់សម័យកាល។ ស្នាដៃទាំងនោះរមែងបង្ហាញពីទិដ្ឋភាពសង្គមបើមិនតិចក៏ច្រើនដែរ។ អាស្រ័យហេតុនេះហើយ ទើបអ្នកសិក្សាស្នាដៃអក្សរសិល្ប៍មួយចំនួនទទួលស្គាល់ថា «អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងពីជីវភាពសង្គម»។

តើទស្សនៈខាងលើនេះមានអត្ថន័យយ៉ាងដូចម្តេចខ្លះ?

www.elibraryofcambodia.org

ដើម្បីបំភ្លឺប្រធានខាងលើឱ្យបានច្បាស់លាស់ យើងត្រូវពន្យល់ពាក្យគន្លឹះជាមុនសិន។ ពាក្យថា "អក្សរសិល្ប៍" មានន័យថាជាបទនិពន្ធដែលប្រកបដោយសិល្ប៍វិធី អាចធ្វើឱ្យអ្នកអានអ្នកស្តាប់កើតចេញនូវក្តីរំភើប ដូចជាកំណាព្យ ប្រលោមលោកជាដើម។ ចំណែកពាក្យ "ជីវភាពសង្គម" វិញសំដៅយកការប្រព្រឹត្តទៅ ឬការរស់នៅរបស់មនុស្សក្នុងសង្គម។ ឯពាក្យ "បញ្ហាសង្គម" គឺជាចំណោទមួយចំនួនដែលចោទឡើងក្នុងសង្គមមនុស្ស។ រីឯពាក្យ "អរិយធម៌សង្គម" មានន័យថាជាទិដ្ឋភាពផ្នែកវប្ប ធម៌ទំនៀមទម្លាប់ប្រពៃណី និងសង្គមធម៌។ ហេតុនេះ ទស្សនៈរបស់ប្រធានខាងលើមានន័យថា អក្សរសិល្ប៍គេអាចទុកដូចជាកញ្ចក់ដែលឆ្លុះ បញ្ចាំងឱ្យឃើញពីដំណើរជីវិតរបស់មនុស្សក្នុងសង្គម ក៏ដូចជាបញ្ហាសង្គម ព្រមទាំងទិដ្ឋភាពវប្ប ធម៌និងសង្គមធម៌នៃសង្គមណាមួយទៀតផង។

www.elibraryofcambodia.org

ដូចដែលអត្ថន័យរបស់ប្រធានបានបង្ហាញរួច ហើយនៅខាងលើថា អក្សរសិល្ប៍គឺជាកញ្ចក់ឆ្លុះ បញ្ចាំងឱ្យឃើញអំពីសង្គមរស់នៅរបស់មនុស្ស។ បើទោះបីជាអក្សរសិល្ប៍កើតពីការច្នៃប្រឌិតរបស់ កវី អ្នកនិពន្ធក្តី ក៏ស្នាដៃទាំងនោះរមែងមានតួ ភាពនៃសង្គមមនុស្សដែរ។ យ៉ាងណាមិញបើគេ ពិនិត្យមើលរឿងភូមិតិរច្ឆានរបស់អ្នកនិពន្ធ ឌឹក គាម និងឌៀក អ៊ំ នោះគេនឹងឃើញពីជីវភាពរស់ នៅ និងបញ្ហារបស់អ្នកភូមិក្រាំងលាវ ឃុំក្រាំងលាវ ស្រុករលាម្អៀរ ខេត្តកំពុងឆ្នាំងនៅសម័យអាណា និគមបារាំង។ អ្នកភូមិមានជីវភាពក្រគោកយ៉ាក លំបាកយ៉ាប់យឺន។ មុខរបររបស់ពួកគេគឺការធ្វើ ស្រែ តែត្រូវជួបគ្រោះរាំងស្ងួតចំនួនបីឆ្នាំបន្តបន្ទាប់ គ្នា ធ្វើឱ្យអ្នកភូមិក្រាំងលាវមិនអាចទទួលផល ច្រើនឆ្ងាយនេះទេ។ ជាក់ស្តែងអ្នកភូមិមិនមាន លុយសម្រាប់ទិញទេ គឺមានតែលាយបាយនឹង ក្តួចដើមឈ្វីចម្ហូបប្រហុកប៉ុណ្ណោះ។ បើរំពឹងលើសិប្ប កម្មក្នុងស្រុកក៏ឃើញថាលក់មិនដាច់ ដូចសុវណ្ណ

www.elibraryofcambodia.org

និងអ្នកប៊ីតដ៏ក្លាមឆ្នាំងពីផ្សារកំពុងឆ្នាំងមកផ្ទះវិញ ទាំងគ្មានបានកម្រៃ។

ទន្ទឹមនឹងនេះស្ពានដែរអក្សរសិល្ប៍ក៏បានឆ្លុះបញ្ចាំងពីបញ្ហារបស់សង្គមនៅសម័យណាមួយផងដែរ។ បើគេក្រឡេកមើលទៅរឿងទុំទាវ គេនឹងឃើញថាមណ្ឌលនៅជំនាន់នោះមានជាប់ទាក់ទងនឹងទស្សនៈ "នំចិនធំជាងនាឡិ" ដោយឪពុកម្តាយជាអ្នកសម្រេចក្នុងការរៀបចំជ្រើសរើសគូស្រករឲ្យកូន ឯណាមីខ្លួនពុំមានសិទ្ធិសម្រេចនោះទេ។ ព្រោះតែគំនិតសង្គមនេះហើយទើបនាងទាវហ៊ានប្រឆាំងនឹងម្តាយថា "*លើកែ្ចមលួបនឹងគេ ក្មួនម៉ែ ចំនេះមានស្ពៃ ប្រសស្ងាត់ លើកឲ្យគេទៅទោះ ពីរបី តាមលែងមានកន្ទ្រាំ ទ្រីខ្ញុំ*"។ ដោយសារគំនិតបែបនេះដែរទើបធ្វើឲ្យទុំនិងទាវដែលជាគូរងតំណាងឲ្យស្ថានភាពយុវជនក្រោកឡើងតស៊ូដើម្បីសម្រេចក្នុងការជ្រើសរើសគូស្រករដោយខ្លួនឯង ហ្វូតដល់ត្រូវអស់ជីវិតនៅទីបញ្ចប់។

www.elibraryofcambodia.org

ជាមួយគ្នានេះដែរ អក្សរសិល្ប៍អាចឆ្លុះបញ្ចាំងពីវប្បធម៌របស់សង្គមមួយដែរ។ ភ្ជាប់ រឿងទុំទាវ បានបង្ហាញពីទំនៀមទម្លាប់ខ្មែរនាសម័យលង្វែក។ នៅសម័យនោះ កូនប្រុសគេនិយមឱ្យទៅបួសរៀននៅវត្ត ដូចករណីនេនទុំនិងនេនពេជ្រដែលឪពុកម្តាយបានឱ្យទៅបួសរៀននៅវត្តវិហារធំ ខេត្តបាភ្នំ។ ចំណែកកូនស្រីវិញ តាមទំនៀមគេច្រើនឱ្យចូលម្លប់ ដូចករណីចូលម្លប់របស់នាងទាវជាដើម។ រឿងនេះក៏បានបង្ហាញពីចំណេះ និងជំនាញរបស់កូនប្រុស ដូចជារៀនសូត្រអក្សរសាស្ត្រ លេខនព្វន្ត និងការផលិតគោកសម្រាប់លក់ ដែលនេនទុំនិងពេជ្របានដឹកផលិតផលនេះទៅលក់នៅត្បូងឃ្មុំ។

សរុបមកស្នាដៃអក្សរសិល្ប៍គឺពិតជាកញ្ចក់ដែលអាចឆ្លុះបញ្ចាំងអំពីតថភាពនៃជីវភាពសង្គម បញ្ហាសង្គម ក៏ដូចជាទិដ្ឋភាពវប្បធម៌របស់សង្គមនីមួយៗផងដែរ។

ឆ្លងតាមរយៈខ្លឹមសារខាងលើ យើងអាចសន្និដ្ឋានបានថា ទស្សនៈក្នុងប្រធាននេះពិតជា

www.elibraryofcambodia.org

មានអត្ថន័យសមស្របដូចដែលអ្នកសិក្សាស្ទាដៃ
អក្សរសិល្ប៍អាចទទួលយកបាន។ ដោយសារតែ
អក្សរសិល្ប៍មានតួនាទីដ៏សំខាន់ចំពោះសង្គម
មនុស្សបែបនេះហើយទើបប្រទេសទាំងឡាយ
ដែលរួមទាំងប្រទេសយើងដែរនោះខិតខំជំរុញឱ្យ
មានការលើកតម្កើងវិស័យនេះឱ្យកាន់តែមានវឌ្ឍន
ភាពទៅមុខជានិច្ច។ ហេតុនេះ យើងជាអ្នកសិក្សា
គប្បីខិតខំសិក្សាក្រេបយកចំណេះដឹងផ្សេងៗពី
ស្ទាដៃអក្សរសិល្ប៍នានាឱ្យបានច្រើនសម្រាប់ជា
ទុនក្នុងការសិក្សា ក៏ដូចជាជីវិតរស់នៅប្រចាំថ្ងៃ
ព្រោះអក្សរសិល្ប៍បានផ្តិតជាប់នូវគ្រប់រសជាតិនៃ
ជីវិតមនុស្សជាតិ។

www.elibraryofcambodia.org

ប្រធានគំរូទី៣

អក្សរសិល្ប៍គឺជាមធ្យោបាយដ៏សំខាន់ក្នុងការអប់រំ ទូន្មាន។ ចូរស្រាយបំភ្លឺមតិខាងលើនេះ។

សេចក្តីអធិប្បាយ

នៅគ្រប់សម័យកាល មនុស្សបានបង្កើតស្នាដៃអក្សរសិល្ប៍ទាំងឡាយទោះជាកំណាព្យក្តី ឬអត្ថបទពាក្យរាយក្តី។ កម្រងស្នាដៃទាំងនោះមានមុខងារច្រើនយ៉ាងដូចជាមុខងារសោភ័ណ កម្សាន្ត និងអប់រំជាដើម។ ការអប់រំគឺជាគំនិតដ៏សំខាន់ដែលបង្កប់ក្នុងអក្សរសិល្ប៍ទាំងនោះ។ អាស្រ័យហេតុនេះហើយទើបបានជាគេចាត់ទុកថាអក្សរសិល្ប៍គឺជាមធ្យោបាយយ៉ាងសំខាន់ក្នុងការអប់រំទូន្មាន។

តើទស្សនៈខាងលើនេះមានអត្ថន័យយ៉ាងដូចម្តេចខ្លះ?

ដើម្បីជាជំនួយក្នុងការបកស្រាយមតិខាងលើឱ្យបានស៊ីជម្រៅ យើងគប្បីយល់ន័យពាក្យ "អក្សរ

www.elibraryofcambodia.org

សិល្ប៍" និង"ការអប់រំទូន្មាន"ជាមុនសិន។ អក្សរសិល្ប៍គឺជាបទនិពន្ធដែលប្រកបដោយសិល្ប៍វិធីអាចធ្វើឱ្យអ្នកអានអ្នកស្តាប់កើតចេញនូវក្តីរំភើប។ លោក ភេង ភ័ន់សាត់ បានលើកឡើងថា "អក្សរសិល្ប៍ជាវិជ្ជាស្ងប់ដែលចោទនិងដោះស្រាយបញ្ហាមនុស្សដោយសិល្ប៍វិធីទៅតាមសង្គមនីមួយៗ"។ រីឯការអប់រំទូន្មានវិញ សំដៅដល់ការប្រៀនប្រដៅណែនាំមនុស្សឱ្យធ្វើល្អ ឬឱ្យដើរតាមផ្លូវត្រូវ។

អក្សរសិល្ប៍នៅគ្រប់សម័យកាល ទោះជាអក្សរសិល្ប៍ឫកាណ ឬទំនើបក្តី ក៏ពុំមែនគ្រាន់តែជាគ្រឿងសម្រាប់អានកម្សាន្ត ឬបណ្តាតអារម្មណ៍ដើម្បីកែអផ្សុកប៉ុណ្ណោះទេ តែរមែងមានតួនាទីសម្រាប់អប់រំទូន្មានមនុស្សក្នុងសង្គមទៀតផង។

នៅក្នុងអក្សរសិល្ប៍សម្តី គេតែងតែឃើញមានគំនិតអប់រំទូន្មានជាច្រើនដែលបង្កប់នៅក្នុងសាច់រឿង។ នៅក្នុងរឿងចចក គេឃើញមានគំនិតអប់រំសំខាន់ពីរយ៉ាងគឺមនុស្សអាងអំណាចដែលរំលោក

www.elibraryofcambodia.org

ជិះជាន់គេ និងមនុស្សទន់ខ្សោយ។ ចំពោះអ្នកមាន យសសក្តិអំណាច ត្រូវចៀសវាងការរំលោភជិះ ជាន់អ្នកក្រទន់ខ្សោយ ព្រោះអាចនាំមកនូវគ្រោះ ថ្នាក់ដូចករណីពួកចចកដែលទទួលរងគ្រោះនៅ ចុងបញ្ចប់រឿង។ ចំពោះអ្នកទន់ខ្សោយវិញ រឿង នេះបានអប់រំឱ្យមានសង្ឃឹម និងចេះរកដំណោះ ស្រាយក្នុងជីវិតកុំរង់ចាំសេចក្តីអន្តរាយទៅតាម យថាកម្ម។ ជាតួយ៉ាង តួអង្គកំពឹសបានប្រើប្រាជ្ញា ដើម្បីរំដោះខ្លួនឱ្យរួចផុតពីគ្រោះថ្នាក់ពេលទឹក ត្រាំងគោកអស់។ ចំណែកត្រីក្រាញ់វិញជាតួអង្គ គំរូអង់អាចក្លាហានហ៊ានធ្វើពលិកម្មដើម្បីបុព្វហេតុ ជីវិតសម្ងហាភាព។ បើពិនិត្យមើលរឿងធនញ្ជ័យ វិញ យើងក៏ឃើញពីទស្សនៈអប់រំយ៉ាងច្រើនផង ដែរ។ រឿងនេះបានអប់រំណែនាំមន្ត្រីរាជការក៏ដូច ជាអ្នកមាន កុំឱ្យជិះជាន់គេងប្រវ័ញ្ចប្រជាជនទន់ ខ្សោយក្រខ្សត់។ ជាពិសេសទៀត រឿងនេះបាន អប់រំអ្នកដឹកនាំប្រទេសឱ្យចេះស្រឡាញ់និងរកអ្នក ចេះដឹងមកដាក់ជិតខ្លួន ព្រោះអ្នកចេះដឹងទាំងនោះ

www.elibraryofcambodia.org

អាចជួយយិតយោងជោគវាសនាប្រទេសជាតិនិង
នាំមកនូវសេចក្ដីរុងរឿងដល់ជាតិផងដែរ ដូច
ករណីធនញ្ជ័យបានជួយស្ដេចច្រើនលើកច្រើន
សារក្នុងការដោះស្រាយបញ្ហាប្រទេសជាតិ។ ដើម្បី
ឱ្យស្ដេចចេះរកអ្នកចេះដឹងមកនៅជិតព្រះកាយព្រះ
អង្គ នៅបុនពេលស្លាប់ធនញ្ជ័យបានពោលជាគតិ
ប្រាប់ស្ដេចថា *"បើសោយត្រីព្រួលកុំចោលស្រកា
បើសោយត្រីប្រាកុំចោលស្រកី បើស្ពឹមក្បាលត្រី កុំ
ភ្លេចមួរសណ្ដាន់"*។

ចំណែកច្បាប់ផ្សេងៗរបស់ខ្មែរដែលគេតាក់
តែងឡើងជាកំណាព្យ កំបានផ្ដល់ជាគតិអប់រំជា
ច្រើនប្រការ។ ក្នុងនោះយើងឃើញថាច្បាប់ភេរ
កាលរបស់ឥសីប្រជាប្រិយក្រមង៉ុយបានបង្ក្រប់នូវ
ទស្សនៈអប់រំដូចជាសីលធម៌ក្នុងការរស់នៅ និង
ពលកម្ម ដូចមានល្បះមួយថា៖ *«កុំដេកចាំសំណាង
កុំភ្លេងភ្លាងចាំបុរេ ខំរកកុំទំនេរ រៀនរ៉ិះចេះឱ្យ
គ្រប់»*។ ច្បាប់នេះបានអប់រំបណ្ដុះសីលធម៌ និង

www.elibraryofcambodia.org

ស្មារតីឱ្យមនុស្សខិតខំរក រៀន និងកុំដេកចាំព្រេងវាសនា។

បើពិនិត្យមើលរឿងទំនើបវិញ យើងនឹងឃើញមានការអប់រំច្រើនឡើងៗពីជីវភាពរស់នៅមនុស្សខ្មែរ។ ជាតួយ៉ាងរឿងកុលាបប៉ែលិនដែលជាស្នាដៃរបស់លោក ញ៉ុក ថែម បានបង្ក្រប់នូវគំនិតអប់រំជាច្រើន។ ក្នុងនោះលោកបានផ្តល់តម្លៃដល់ការតស៊ូព្យាយាមចិត្តអំណត់ក្នុងការងារ និងអំពើល្អ ដោយមានចៅចិត្រជាតួអង្គតួយ៉ាង។ ដោយសារកត្តានេះ ចៅចិត្របានក្លាយជាគូគាប់របស់នាងឃុននារីដែលជាកូនរបស់លោកហ្លួងរតនសម្ត្ត។ រីឯរឿងស៊ីមអ្នកបរឡានបានអប់រំយើងឱ្យឃើញពីទុក្ខវេទនារបស់កម្មករមកពីនាយទុនកេងប្រវ័ញ្ច គឺមិនមែនមកពីព្រេងវាសនានោះទេ។ រឿងនេះក៏បានអប់រំជុសកម្មករ កសិករឱ្យយល់ដឹងពីតម្លៃនៃវិជ្ជាដោយឱ្យពួកគេខិតខំរៀន និងបង្កើតជាសមាគមសហជីពដើម្បីជាប្រយោជន៍ដល់ពួកគេទៀតផង។

www.elibraryofcambodia.org

ជារួមមកអក្សរសិល្ប៍បានផ្តល់ជាទស្សនៈអប់រំ ជាច្រើនដល់មនុស្សទាំងឡាយដូចជាសីលធម៌ក្នុងការរស់នៅ ការតស៊ូអំណត់ព្យាយាមដោយមិនដេកចាំព្រេងសំណាង ការប្រព្រឹត្តអំពើល្អដោយចៀសវាងអំពើអាក្រក់ តម្លៃនៃចំណេះវិជ្ជាជាដើម។ គតិអប់រំទាំងនោះបានបង្ហាប់នៅក្នុងសាច់រឿងឬអត្ថបទតាមរយៈសិល្ប៍វិធីរបស់អ្នកនិពន្ធម្នាក់ៗ។ ដោយ សារតែសិល្ប៍វិធីនេះហើយទើបធ្វើឱ្យអ្នកអានអ្នកស្តាប់ទទួលបានគតិអប់រំទាំងមិនដឹងខ្លួន។

ឆ្លងតាមការបកស្រាយខាងលើ យើងឃើញថាអក្សរសិល្ប៍ជាមធ្យោបាយដ៏ចាំបាច់មិនអាចខ្វះបានក្នុងការអប់រំមនុស្សទូន្មានមនុស្សឱ្យបានស្គាល់ពីគតិជាច្រើនក្នុងបទពិសោធជីវិតនៃសម័យកាលដែលកវីឬអ្នកនិពន្ធបានឆ្លងកាត់។ ដូច្នេះ យើងជាកុលបុត្រកុលធីតាខ្មែរទាំងអស់គ្នាគប្បីខិតខំដកស្រង់គតិល្អៗទាំងឡាយដែលមានក្នុងស្នាដៃអក្សរសិល្ប៍របស់បុព្វបុរសយើងសម្រាប់ទុកជាមាគ៌ាក្នុងការត្រិះរិះពិចារណាក្នុងជីវិត

www.elibraryofcambodia.org

ច្បាប់ព្រះរាជសម្ភារបានចែងថា «ខ្លែងហើរដ្ឋិតខ្យល់ នាយថ្មើងដ្ឋិតពលក្សាឱ្យសុខ ទ្រព្យគង់ដ្ឋិតស្រីចេះសំចៃទុក ផ្ទះធំស្រណុកដ្ឋិតភរិយាជា»។ តើទស្សនៈខាងលើនេះមានអត្ថន័យអប់រំយ៉ាងដូចម្តេចខ្លះ?

សេចក្តីអធិប្បាយ

តាមប្រវត្តិអក្សរសាស្ត្រខ្មែរ គេរមែងឃើញកវីនិងអ្នកនិពន្ធដ៏ចំណានៗ ក្នុងនោះមានទាំងព្រះញាតិវង្សផងដែរដែលតែងតែយកព្រះទ័យទុកដាក់ចំពោះវិស័យអក្សរសាស្ត្រ។ យ៉ាងណាមិញព្រះរាជសម្ភារដែលជារាជកវីមួយអង្គដ៏ល្បីល្បាញ បានតាក់តែងកំណាព្យជាច្រើន ជាពិសេសកំណាព្យឧបទេស ពោលគឺកំណាព្យអប់រំទូន្មានៗ។ ក្នុងនោះ ច្បាប់ព្រះរាជសម្ភារបានចែងថា «ខ្លែងហើរដ្ឋិតខ្យល់

www.elibraryofcambodia.org

នាយថ្កើងដ្ឋិតពលរក្សាឱ្យសុខ ទ្រព្យគង់ដ្ឋិតស្រីចេះ
សំចៃទុក ផ្ទះធំស្រណុកដ្ឋិតភរិយាជា»។

តើទស្សនៈខាងលើនេះមានអត្ថន័យអប់រំយ៉ាង
ដូចម្តេចខ្លះ?

ដើម្បីបកស្រាយទស្សនៈខាងលើនេះឱ្យបាន
ពិស្តារ យើងគប្បីយល់ន័យរបស់ពាក្យមួយចំនួន
ជាមុនសិន។ ចំពោះពាក្យ «នាយ»នៅទីនេះសំដៅ
លើថ្នាក់ដឹកនាំគ្រប់ជំពូក។ រីឯពាក្យថា «ពល»មាន
ន័យថា ពលទាហាន អ្នកក្រោមឱវាទ ឬកំជាប្រជា
ពលរដ្ឋតែម្តង។ ចំណែកពាក្យថា«ភរិយាជា»មាន
ន័យថា ប្រពន្ធដែលមានលក្ខណសម្បត្តិជាស្រី
គ្រប់លក្ខណ៍ ឬស្រីដែលប្រកបដោយលក្ខណ
សម្បត្តិល្អប្រសើរ។

ប្រធានខាងលើនេះមានន័យសេចក្តីថា សេច
ក្តីថ្កុំថ្កើងរបស់ថ្នាក់ដឹកនាំអាចកើតឡើងបានគឺ
អាស្រ័យលើអ្នកនៅក្រោមឱវាទរបស់ខ្លួន ចំណែក
ភាពសុខក្សេមក្សាន្តចម្រុងចម្រើននៃក្រុមគ្រួសារ

www.elibraryofcambodia.org

ញែកគឺអាស្រ័យលើស្រីជាកវិយាដែលមានលក្ខណៈ
សម្បត្តិល្អប្រសើរ។

ចំពោះឃ្លា "ខ្លែងហើរដ្ឋិតខ្យល់" គឺមានន័យ
សំដៅលើខ្លែងជាសម្ភារៈសម្រាប់មនុស្សបង្ហោះ
ដើម្បីកម្សាន្តលេង។ គេច្រើនធ្វើខ្លែងដោយឫស្សី
ចិតជាមួយនឹងក្រណាត់ជាផ្ទាំងឬក្រដាសផ្សេងៗ
ហើយមានខ្សែយកទៅបង្ហោះនៅរដូវដែលមាន
ខ្យល់ធ្លាក់។ ហេតុដូចនេះហើយបានជាគេឃើញ
ក្មេងភាគច្រើនលេងនៅរដូវរំហើយ។ ហេតុនេះ
ខ្លែងអាចហើរបានគឺត្រូវពឹងខ្យល់ជាចាំបាច់។

ចំណែកឃ្លា "នាយផ្ទាំងដ្ឋិតពលរក្សាឱ្យសុខ"
គឺលោកប្រៀបប្រដូចខ្លែងទៅនឹងនាយ ហើយ
ប្រដូចខ្យល់ទៅនឹងពល ពោលគឺខ្លែងត្រូវពឹងខ្យល់
ឯនាយត្រូវពឹងពល។ នាយឬថ្នាក់ដឹកនាំអាច
ចម្រុងចម្រើនទៅបានត្រូវមានការចូលរួមពី
សំណាក់អ្នកនៅក្រោមបង្គាប់ ឬប្រជាជនទាំងអស់
គ្នា។ ជាក់ស្តែងនៅសម័យសង្គមរាស្ត្រនិយម គេ

www.elibraryofcambodia.org

តែងទទួលស្គាល់ថា ភាពរុងរឿងថ្កុំថ្កើងនៅសម័យ
នោះបានមកពីសមត្ថភាពដឹកនាំរបស់ព្រះបាទ
នរោត្តមសីហនុដោយមានការចូលរួមពីរដ្ឋាភិបាល
និងប្រជារាស្ត្រទាំងអស់ដែលពេញចិត្តបម្រើជាតិ
ឥតរាថយ។ បើក្រឡេកមកមើលអក្សរសិល្ប៍វិញ
យើងក៏ឃើញចំណុចបែបនេះដែរ។ ជាតួយ៉ាង
តាមរយៈរឿងកុលាបម៉ែលិន លោកហ្លួងរតនៈ
សម្ត្ថិអាចមានកេរ្តិ៍ឈ្មោះឧត្តមប្រពៃក៏ព្រោះតែ
មានការជួយជ្រោមជ្រែងពីសំណាក់កម្មករដូចជា
ចៅចិត្រជាដើម។ បន្ថែមពីលើនេះការតស៊ូប្រឆាំង
នឹងរេស៊ីដង់ប៉ារដេសដែលបានលាតត្រដាងក្នុង
រឿងភូមិតិរច្ឆាន ជួននិងនៅរាចទទួលជោគជ័យក៏
ត្រូវពឹងផ្អែកទៅលើកម្លាំងអ្នកក្លាហានទាំង២០នាក់
ព្រមទាំងប្រជាជននៅភូមិក្រាំងលាវផងដែរ។

ចំណែកឃ្លាដែលពោលថា "ទ្រព្យគង់ជ្ជិតស្រី
ចេះសំចៃទុក ផ្ទះធំស្រណុកជ្ជិតការិយាជ" គឺសំដៅ
ទៅលើឥទ្ធិពលរបស់ស្ត្រីដែលជាមេផ្ទះចេះរៀបចំ

www.elibraryofcambodia.org

ទុកដាក់គ្រប់គ្រងផ្ទះសម្បែងឱ្យមានសិរីសួស្តី
កិត្តិយស និងសុភមង្គលនៅក្នុងក្រុមគ្រួសារ។ នេះ
បានន័យថា ស្រីជាអ្នករក្សាទុកនូវទ្រព្យសម្បត្តិ
ដែលស្វាមីរកបានមកប្រគល់ឱ្យនាងហើយ
ប្រសិនបើនាងមិនចេះរៀបចំទុកដាក់ទេនោះ នឹង
ធ្វើឱ្យគ្រួសារមិនរីកចម្រើន។ ដូច្នេះស្រីជាមេផ្ទះចាំ
បាច់ត្រូវមានលក្ខណៈសម្បត្តិល្អប្រសើរ ពោលគឺ
ស្រីគ្រប់លក្ខណ៍គប្បីមានទាំងចរិយាសម្បត្តិនិង
វិជ្ជាសម្បត្តិដូចជាការងារផ្ទះនិងការងារដទៃទៀត
ព្រមទាំងការចេះគ្រប់គ្រងផ្ទះសម្បែង ការអប់រំកូន
ចៅ និងការដោះស្រាយបញ្ហាដទៃទៀតដើម្បីឱ្យ
គ្រួសារមានសុភមង្គល។ តាមរយៈអក្សរសិល្ប៍
រឿងមាយើង មាណពអាចមានកេរ្តិ៍ឈ្មោះនិង
ជីវភាពរុងរឿងទៅបានអាស្រ័យដោយភរិយាទី២
ជាស្រីគ្រប់លក្ខណ៍ដែលបានជួយផ្ទុងផ្តើមដឹកនាំ
គ្រប់កិច្ចការរបស់មាណពតាំងពីមាណពទៅរក
ឧសរហូតដល់បានក្លាយជាអាមាត្ររបស់ស្តេច
ហើយចុងក្រោយត្រូវបានព្រះរាជាផ្តល់កិត្តិយសថា

www.elibraryofcambodia.org

ជា "មាយើង" គឺមារបស់ស្តេចទៀតផង។ ជីវភាពគ្រួសារមាយើងរុងរឿងបានក៏ព្រោះប្រពន្ធល្អជាហេតុធ្វើឱ្យញាតិមិត្តពឹងពាក់ស្ទាក់អាស្រ័យរាប់រកច្រើនរាប់មិនអស់។ បើពិនិត្យមើលប្រវត្តិសាស្ត្រខ្មែរវិញ គេអាចដឹងបានថាព្រះបាទជ័យវរ្មនទី៧ មានព្រះតេជ្ជិសព្ធរុងរឿងល្បីសុះសាយបានក៏ដោយ សារតែមានការចូលរួមគាំទ្រពីព្រះនាងឥន្ទ្រទេវីជាមហេសីដែលប្រកបដោយបញ្ញាញាណនិងចំណេះដឹងប្រៅប្រៃ។ ចំណុចនេះស្របនឹងសុភា សិតខ្មែរមួយបានពោលថា *"សំណាងយោងដី ស្រីយោងប្រុស"*។

សរុបមក ភាពរុងរឿងរីកចម្រើនរបស់មេដឹកនាំគឺអាស្រ័យលើកម្លាំងរបស់អ្នកតូចតាចដែលនៅក្រោមឱវាទ មិនខុសពីសុភមង្គលនៅក្នុងក្រុមគ្រួសារអាចកើតឡើងបានដោយសារតែភរិយាដែលមានលក្ខណសម្បត្តិល្អប្រសើរ។

ឆ្លងតាមការបកស្រាយខាងលើនេះ យើងអាចសន្និដ្ឋានទ្រឹទ្ធិទស្សនៈរបស់ប្រធានខាងលើបានថា

www.elibraryofcambodia.org

ជាគតិល្អសម្រាប់អប់រំសង្គមទាំងមូល ជាពិសេស ថ្នាក់ដឹកនាំឱ្យយកចិត្តទុកដាក់និងឱ្យតម្លៃលើអ្នកក្រោមឱវាទខ្លួន ពោលគឺអប់រំឱ្យបុគ្គលម្នាក់ៗចេះផ្លាស់ប្តូរយោបល់គ្នាក្នុងការសម្រេចចិត្តធ្វើអ្វីមួយ។ បន្ថែមលើនេះ ទស្សនៈនេះក៏នាំឱ្យសង្គមយល់ពីតម្លៃនៃស្ត្រីដែលជាកម្លាំងចលករដ៏សំខាន់ក្នុងគ្រួសារក៏ដូចជាសង្គមជាតិ។ ដូច្នេះក្នុងនាមយើងជាអ្នកសិក្សាគួរយកចិត្តទុកដាក់និងស្វែងយល់ឱ្យបានច្បាស់ពីអ្នកដឹកនាំក៏ដូចជាអ្នកនៅក្រោមឱវាទគឺសុទ្ធតែមានតួនាទីសំខាន់ក្នុងការស្ថាបនាជាតិឱ្យបានរុងរឿង។ ការយល់បែបនេះទើបធ្វើឱ្យខ្លួនយើងក្តី គ្រួសារក្តី សង្គមជាតិក្តីទទួលបាននូវភាពរុងរឿង។

www.elibraryofcambodia.org

ព្រះពុទ្ធទ្រង់បានទូន្មានថា «ចូរកុំទ្រទ្រង់ភ្លើងចំណង់ដោយអំពើអាក្រក់ឡើយ»។ ចូរអ្នកវិភាគបម្រាមមួយឃ្លាខាងលើនេះ។

សេចក្តីអធិប្បាយ

ព្រះពុទ្ធសាសនាដែលជាសាសនាបង្កើតឡើងដោយព្រះពុទ្ធអង្គ មានទ្រឹស្តីជាច្រើនសម្រាប់អប់រំទូន្មានដល់ពុទ្ធបរិស័ទឱ្យវៀរចាកអំពើអាក្រក់ ហើយបែរមកប្រព្រឹត្តតែអំពើល្អប្រចាំជីវិតរស់នៅ។ ក្នុងសេចក្តីទូន្មានទាំងនោះក៏មានបញ្ញត្តិមួយចំនួនដែលហាមប្រាមមិនឱ្យមនុស្សប្រព្រឹត្តអំពើមិនល្អ ព្រោះជាមូលហេតុនាំទៅរកសេចក្តីវិនាស។ ហេតុនេះហើយទើបគេឃើញមានបម្រាមមួយឃ្លាថា"ចូរកុំទ្រទ្រង់ភ្លើងចំណង់ដោយអំពើអាក្រក់ឡើយ"។

www.elibraryofcambodia.org

តើបញ្ញត្តិមួយឃ្លានេះមានអត្ថន័យយ៉ាងដូចម្តេចខ្លះ?

ដើម្បីបានជាជំនួយដល់ការបកស្រាយ យើងគប្បីយល់ន័យរបស់ពាក្យមួយចំនួនជាមុនសិន។ ពាក្យ"ភ្លើង"ក្នុងទីនេះសំដៅដល់កំហឹងដែលពាក្យនៅក្នុងព្រះពុទ្ធសាសនាថាទោស:។ រីឯពាក្យ"ចំណង់" ភ្លាយមកពីពាក្យចង់ ពោលគឺសំដៅដល់ការចង់បានឬចង់ធ្វើជាដើម។ ទស្សន:របស់ប្រធានខាងលើនេះចង់មានន័យថា ការមានជីវិតរស់នៅមនុស្សម្នាក់ៗចូរកុំនាំគ្នាទ្រទ្រង់ភ្លើងកំហឹងដែលកើតចេញពីចំណង់ ដោយប្រព្រឹត្តអំពើអាក្រក់នោះឡើយ។

អ្នកកាន់ព្រះពុទ្ធសាសនា ក៏ដូចជាអ្នកសិក្សាផ្នែកពុទ្ធសាសនាតែងតែកត់សម្គាល់ឃើញថា អ្នកទ្រទ្រង់ភ្លើងចំណង់ដោយអំពើអាក្រក់ រមែងលង់ផុងខ្លួនក្នុងមហិច្ឆតាគ្មានដែនកំណត់ ហើយដោយ

www.elibraryofcambodia.org

សារការដុតពេលនៃភ្លើងចំណង់នេះហើយ ទើបធ្វើ
ឱ្យមនុស្សធ្លាក់ក្នុងសេចក្តីវិនាសអន្តរាយ។ ក្នុង
ទស្សនវិជ្ជាពុទ្ធសាសនា លោភ:គឺសេចក្តីលោភ
លន់ ទោស:គឺកំហឹង និងមោហ:គឺសេចក្តីវង្វេង
ដែលនាំឱ្យមនុស្សធ្លាក់ក្នុងទុក្ខជាយថាហេតុ។ នៅ
ពេលដែលមនុស្សវង្វេងដោយភ្លើងចំណង់ មនុស្ស
តែងហ៊ានប្រព្រឹត្តអំពើមិនល្អដែលនាំអាត្មាទៅរក
សេចក្តីទុក្ខ។ ដោយសារការលោភលន់ពន់
ប្រមាណទើបធ្វើឱ្យមនុស្សល្អទៅជាអាក្រក់ហើយ
ហ៊ានប្រព្រឹត្តផ្ទុយនឹងច្បាប់សង្គមដូចជា ការកេង
ប្រវ័ញ្ចទ្រព្យអ្នកដទៃ ការប្រព្រឹត្តបទឧក្រិដ្ឋនានា
និងការចរាចរណ៍គ្រឿងញៀនជាដើម។ អំពើទាំង
នេះសុទ្ធតែជាហេតុនាំទៅរកសេចក្តីវិនាសទាំង
ឡាយ។ ជាតួយ៉ាងអ្នកនិពន្ធខ្មែរបានបំផុសឆ្លុះ
បញ្ចាំងទស្សនៈនេះតាមរយៈស្នាដៃអក្សរសិល្ប៍នា
នា។ ក្នុងនោះ រឿងព្រះវេស្សន្តរដែលជារឿងស្ថិត

www.elibraryofcambodia.org

ក្នុងចលនាអក្សរសិល្ប៍ពុទ្ធនិយម បានបង្ហាញពី
វិនាសកម្មកើតឡើងដូចករណីព្រាហ្មណ៍ជូជកនៅ
នគរកលិङ្គរាស្ត្រ ដោយសារតែមហិច្ឆតាអាក្រក់
របស់គាត់ ទើបត្រូវទទួលមរណៈដោយបែកពោះ
ស្លាប់ ព្រោះល្មោភស៊ី។ ចំណែកនៅក្នុងរឿងទុំទាវ
ព្រះបទុមត្ថេរសោមបានបង្ហាញពីទារុណកម្ម
និរាសកម្ម និងសោកនាដកម្មកើតដល់អរជូននិង
គ្រួសារព្រោះតែការទ្រទ្រង់ភ្លើងចំណង់ក្នុងអំពើអា
ក្រក់។ ដោយអាងអំណាចជាស្តេចគ្រាញ់នៅ
ត្បូងឃ្មុំ អរជូនបានពង្រាត់នាងទាវចេញពីទុំមក
រៀបការនឹងម៉ឺនងួនដែលជាកូនប្រុសរបស់ខ្លួន។
មិនតែប៉ុណ្ណោះអរជូនក៏បានបញ្ជាមនុស្សជាដៃជើង
របស់ខ្លួនឱ្យទៅសម្លាប់ទុំជាប្តីនាងទាវ ដើម្បីបំបិទ
មាត់បំបាត់ដានទៀតផង។ មូលហេតុនេះហើយ
ទើបធ្វើឱ្យអរជូន និងក្រុមគ្រួសារ ព្រមទាំងញាតិកា
ទាំងប្រាំពីរសន្តានត្រូវព្រះបាទភាមាសម្រេចវិនិច្ឆ័យ

www.elibraryofcambodia.org

ទោសយ៉ាងទារុណបំផុត។ បើពិនិត្យមើលរឿងកុលាបប៉ែលិនវិញ យើងក៏សង្កេតឃើញករណីនេះដែរ។ លោកបាឡាត់ស្រុកសង្កែ និងថៅកែជាន់ក៏ប្រព្រឹត្តរំលោភដោយតណ្ហាដឹកមុខដែរ គឺគាត់ចង់បាននាងឃុននារី ចង់បានមាសពេជ្រទាំងគ្រាប់ៗ របស់លោកហ្លួងរតនសម្ប្បត្តិ ក៏ប៉ុន្តែពួកគេត្រូវទទួលគ្រោះថ្នាក់ដល់ក្យ៉ាយជីវិត។

សរុបមក ការទ្រទ្រង់ភ្លើងកំហឹងដែលកើតចេញពីចំណង់ដោយការប្រព្រឹត្តអំពើអាក្រក់ទាំងឡាយ គឺជាហេតុនាំទៅរកសេចក្តីអន្តរាយនៅក្នុងជីវិត។

តាមការបកស្រាយរួចមកហើយ ធ្វើឱ្យយើងអាចសន្និដ្ឋានបានថា ទស្សនៈរបស់ប្រធានខាងលើពិតជាមានអត្ថន័យអប់រំដ៏ល្អប្រសើរឱ្យមនុស្ស រៀនចាកនូវការប្រព្រឹត្តអំពើមិនល្អដើម្បីមហិច្ឆតារបស់ខ្លួន។ យើងជាជនជាតិខ្មែរ គប្បីបន្តការសិក្សា

www.elibraryofcambodia.org

រៀនសូត្រតាមទស្សនៈទូន្ទានល្អៗដែលអាចជាមាគ៌ាជីវិតដ៏ប្រសើរនៅក្នុងពេលបច្ចុប្បន្ននេះ និងទៅអនាគត។

www.elibraryofcambodia.org

ប្រធានគំរូទី៦

តន្ត្រី និងចម្រៀង ជាព្រលឹងរបស់ជនជាតិខ្មែរ។ ចូរពន្យល់។

សេចក្តីអធិប្បាយ

ជនជាតិនីមួយៗសុទ្ធតែមានទំនៀមទម្លាប់ប្រពៃណីអត្តសញ្ញាណដែលជាព្រលឹងជាតិមួយ ដែលមានទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួនផ្សារភ្ជាប់ជាមួយតន្ត្រី និងចម្រៀងតាំងពីចាប់កំណើតរហូតស្លាប់ទៅវិញ។ ទម្លាប់ប្រតិបត្តិចំពោះតន្ត្រី និងចម្រៀងនេះបានក្លាយជាព្រលឹងរបស់ជាតិខ្មែរ ព្រោះខ្មែរគ្រប់រូបបានចេះច្រៀង និងចេះតន្ត្រីខ្លះៗទៀតផង។ ហេតុនេះហើយទើបគេថា "តន្ត្រី និងចម្រៀង ជាព្រលឹងរបស់ជនជាតិខ្មែរ"។

www.elibraryofcambodia.org

តើទស្សនៈខាងលើមានអត្ថន័យខ្លឹមសារយ៉ាងណា?

វត្ថុមួយឬរបស់មួយអាចចាត់ទុកជាព្រលឹង ឬក្លាយទៅជាព្រលឹងរបស់អ្វីផ្សេងទៀតបាន ទាល់តែវត្ថុឬរបស់នោះជាទីពេញនិយម និងត្រូវបានគេយកមកអនុវត្តជាប្រចាំនៅគ្រប់កាលៈទេសៈហើយវាមានសារៈសំខាន់ចាំបាច់ទៀតផងក្នុងការរួមចំណែកអភិវឌ្ឍ និងបង្កើតភាពរីករាយ។

ជាការពិតណាស់ តន្ត្រីនិងចម្រៀង គឺជាព្រលឹងរបស់ជនជាតិខ្មែរ ព្រោះតន្ត្រីនិងចម្រៀងគឺជាវត្ថុម្យ៉ាងដែលមានសារៈសំខាន់ក្នុងការជួយឱ្យមនុស្សមានសេចក្ដីសុខសូប៉ក្នុងអារម្មណ៍ជួយឱ្យពួកគេមានភាពសប្បាយរីករាយ, ភាពចាំបាច់របស់តន្ត្រីនិងចម្រៀងនេះហើយដែលញ៉ាំងឱ្យជនជាតិខ្មែរយកវាមកប្រតិបត្តិតាំងពីវ័យក្មេងរហូតដល់ចាស់ ដូចនៅពេលជាទារកយំ ចាស់ៗ ឬម្តាយ

www.elibraryofcambodia.org

ទាំងឡាយតែងតែច្រៀងបំពេរកូនទៅតាមចង្វាក់
នានាដែលគាត់ចេះយ៉ាងពីរោះ ទោះបីគ្មានតន្ត្រី
ពិតប្រាកដកំដរកំដោយ ក៏បំពេរដោយថ្នាក់ថ្នម
លួងលោម ដើម្បីឱ្យកូនបានសូប់អារម្មណ៍។ នៅ
ពេលទារកកើតចិត្តមួហ្មង អ្នកមើលតែងតែខំរក
ទំនុកច្រៀងលួងលោមឱ្យវារីករាយឡើងវិញ។ នៅ
ពេលទារកចេះក្រឡាប់ គេតែងតែច្រៀងប្រលែង
លេងឱ្យប្រឹងរើផ្ងារឡើងវិញ។ នៅពេលទារកចេះ
អង្គុយ គេតែងច្រៀងប្រលែងដោយដាក់ទារកឱ្យ
អង្គុយលើខ្នងជើង ហើយដៃទាំងពីរកាន់ដៃទារក
រួចលើកជើងយឹកយោកជាចង្វាក់មួយ គឺ"យឹក
យោក ស្រូវមួយត្រឡោក ក្ងោកពាំអស់"។ ពេល
ទារកចេះកម្រើកដៃជើង គេតែងក្តាប់លាងដៃ
ដើម្បីឱ្យទារកគ្រាប់តាមដោយទំនុក "ចាប់ចាបៗ"។
ពេលទារកប្រឹងរៀនដើរលេង ដើម្បីពង្រឹងទឹកចិត្ត
ទារកឱ្យក្លាហានមិនកិតភ័យគេច្រៀងទំនុក "តាក់

www.elibraryofcambodia.org

ទីងតែតៗ" ដើម្បីឱ្យទារកសប្បាយភ្លេចខ្លួនប្រឹងងើបឈរឡើង។ នៅពេលកុមារ ក្នុងវ័យនេះកុមារតែងតែសម្រាកកម្សាន្តជាមួយល្បែងផ្សេងៗដូចជាល្បែងបិទមុខបិទពួន ល្បែងនេះគេច្រៀងថា "ប៊ីប៉ក់ ស៊ីសំបកមិនចោលគ្រាប់"។ នៅពេលចប់បើចុងបទទៅលើអ្នកណា អ្នកនោះមានសិទ្ធិរត់ពួន។ គេធ្វើរបៀបនេះដល់អស់គ្នា ហើយអ្នកចុងក្រោយគេគឺជាអ្នកចាំទី។ ចំពោះការលេងល្បែងប្រជាប្រិយក៏គេមានច្រៀងផងដែរ ដូចជាល្បែងលាក់កន្សែង ល្បែងបូតសណ្តែក ល្បែងចាប់ក្ងន ខ្លែងជាដើម។ នៅពេលធំពេញវ័យគេធ្វើពិធីបំបួសនាគ ពិធីរៀបអាពាហ៍ពិពាហ៍ជាដើម គេតែងត្រូវការតន្ត្រីកំដរជានិច្ច រហូតពិធីបុណ្យផ្សេងៗទៀតដូចជាពិធីបុណ្យចូលឆ្នាំ បុណ្យឡើងផ្ទះ បុណ្យសុំទឹកភ្លៀង ជាដើមក៏ត្រូវការតន្ត្រីកំដរដែរ។ នៅពេលឈឺថ្កាត់ ពេលចាំបាច់គេក៏ត្រូវការភ្លេងដែរដូចជាលេងភ្លេងអារក្ស

www.elibraryofcambodia.org

សម្រាប់ថ្វាយអារក្ស។ នៅពេលស្លាប់ គេធ្វើបុណ្យ ក៏គេត្រូវការភ្លេងកំដរដូចគ្នាដែរ។ បើគេសង្កេត មើលពិធីឆ្លងវ័យក្នុងសង្គមខ្មែរ នឹងឃើញថាតន្ត្រី និងចម្រៀងជារបស់ចាំបាច់ក្នុងជីវិតខ្មែរ។

រួមសេចក្តីមកឃើញថា តន្ត្រី និងចម្រៀងពិត ជាព្រលឹងរបស់ជនជាតិខ្មែរ ព្រោះតាំងពីកើតរហូត ស្លាប់ ខ្មែរទាំងឡាយសុទ្ធតែបានចេះចាំ និងតែង តែប្រើតន្ត្រីជានិច្ចក្នុងការកំដរពិធីផ្សេងៗ ទៅតាម ទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួន។

ឆ្លងតាមការបកស្រាយខាងលើឃើញថា មតិ ប្រធានមានអត្ថន័យយ៉ាងល្អ ព្រោះមតិនេះបាន ដាស់សតិកូនខ្មែរឱ្យស្គាល់ច្បាស់នូវអត្តសញ្ញាណ របស់ខ្លួនដែលមានលក្ខណៈសម្ផ្ទរបែប ហើយ ខិតខំថែរក្សា ពង្រឹង និងពង្រីកបន្ថែមទៀត ដើម្បី ចូលរួមកសាងជាតិឱ្យចម្រុងចម្រើនដូចកាល សម័យរុងរឿងនៃយើង។

www.elibraryofcambodia.org

> មតិមួយចំនួនបានអះអាងថា «បុព្វបុរសខ្មែរជាវីរជន មានឧត្តមគតិ ហ៊ានធ្វើពលិកម្មដើម្បីបុព្វហេតុជាតិ មាតុភូមិ»។ ផ្អែកតាមស្នាដៃអក្សរសិល្ប៍នានាដែលមានរួចមកហើយ ចូរអ្នកស្រាយបំភ្លឺទស្សនៈនេះ។

សេចក្តីអធិប្បាយ

ប្រវត្តិសាស្ត្របានកត់ត្រាចារឹកឱ្យឃើញជាសក្ខីភាពរួចមកហើយថា នៅគ្រប់ជំនាន់បុព្វបុរសជាតិតែងធ្វើការតស៊ូស្វិតស្វាញក្រាញនៀលក្នុងការប្រឆាំងនឹងបច្ចាមិត្តឈ្លានពានគ្រប់ប្រភេទ ដើម្បីបុព្វហេតុការពារបូរណភាពដែនដី ជាប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់។ ដោយសារមានភ្ជាប់ទំនាក់ទំនងបែបនេះហើយ ទើបមានមតិខ្លះអះអាងថា "ប្រធាន"។

www.elibraryofcambodia.org

តើបុព្វបុរសខ្មែរជាវីរជនហ៊ានធ្វើពលិកម្ម ដើម្បីបុព្វហេតុជាតិយ៉ាងដូចម្តេចខ្លះ?

. ដើម្បីឱ្យការបកស្រាយប្រធានប្រកបដោយភាពរលូន យើងគួរយល់ពាក្យមួយចំនួនជាមុនសិន។ ពាក្យបុព្វបុរស សំដៅយកបុរស ឬមនុស្សជំនាន់ដើម ដល់ពួកជនដែលប្រកបដោយភាពអង់អាចក្លាហាន ហ៊ានធ្វើអ្វីៗគ្រប់យ៉ាងជាប្រយោជន៍ដល់សង្គមជាតិ។ ឯពាក្យ ឧត្តមគតិនោះគឺជាការលះបង់រហូតដល់យកជីវិតទៅប្តូរក៏សឹងមាន។ មតិរបស់ប្រធានមានអត្ថន័យតម្រូវឱ្យធ្វើការស្រាយបំភ្លឺប្រកបដោយភស្តុតាងបញ្ជាក់ថាខ្មែរជំនាន់ដើមជាមនុស្សដែលប្រកបដោយទឹកចិត្តអង់អាចក្លាហាន ហ៊ានធ្វើការលះបង់គ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិមាតុភូមិ។

ដូចដែលទស្សនៈវិស័យរបស់ប្រធានបានលើកឡើងរួចមកហើយខាងលើថា វីរបុរសជាតិ គឺ

www.elibraryofcambodia.org

ជាអ្នកដែលមានឆន្ទៈមនសិការដ៏ខ្ពង់ខ្ពស់របស់
ជាតិមាតុភូមិដែលបានផ្តល់កំណើតឱ្យខ្លួនរស់។
អ្នកនិពន្ធក៏ដូចជាកវីខ្មែរក៏បានបង្ហាញគំរូឧត្តមគតិ
នេះតាមរយៈស្នាដៃអក្សរសិល្ប៍នានាដូចដែលគេ
បានឃើញរួចមកហើយនូវតួអង្គជាវីរជន។ បើគេ
មើលមកក្នុងរឿងរាមកេរ្តិ៍ នោះគេនឹងឃើញយ៉ាង
ជាក់ច្បាស់អំពីឧត្តមភាពរបស់ស្តេចស្វានៅឯខាស
ខិនបុរី នោះគឺពាលីដែលបានធ្វើពលិកម្មគ្រប់យ៉ាង
ដើម្បីការពារពលរដ្ឋស្វារបស់ខ្លួនកុំឱ្យស្លាប់ដោយ
ឥតន័យ ដោយសារកំណែនរបស់ព្រះរាម ដើម្បី
ការពារបូរណភាពអធិបតេយ្យភាពនៃបុរីខាស់ខិន
មិនឱ្យធ្លាក់ជាអាណានិគមរបស់ព្រះរាម ព្រោះតែ
យ៉ាងនេះហើយទើបពាលីត្រូវពលីដោយសរដែល
ព្រះរាមបាញ់ពីក្រោយខ្នង។ ជាមួយគ្នានេះដែរ បើ
គេមើលទៅនគរលង្កាឯនោះវិញ គេឃើញពីឧត្តម
គតិរបស់មេទ័ពយក្សឈ្មោះកុម្ភកាណ៌។ កុម្ភកាណ៌

www.elibraryofcambodia.org

ដែលនាំពលរេហ៍យក្សមកកាន់សមរភូមិ មិនដើម្បី
បុព្វហេតុការពារអំណាចឱ្យក្រុងរាជណាចក្រនោះ
ទេ តែដើម្បីកិត្យានុភាពជាតិយក្សទាំងមូល។ បើ
ទោះបីជាព្រះរាមបញ្ជូនយក្សឈ្មោះពិភេកឱ្យបញ្ចុះ
បញ្ចូលកុម្ភកាណ៌ឱ្យឈប់ចម្បាំងដោយសន្យាថានឹង
ដំឡើងឋានៈឱ្យស្មើនឹងព្រះលក្ស្មណ៌ក៏ដោយ ក៏
កុម្ភកាណ៌ស្ងៀមស្ងាត់លើសមរភូមិដោយមិនព្រម
ឱ្យសត្រូវខ្ចីដៃដើម្បីប្រល័យជាតិឯងនោះឡើយ។
បើមើលមកក្នុងចលនារឿងភូមិតិរច្ឆានវិញ ក៏
ឃើញថាក្រុមរួកត្លាហាននៅភូមិក្រាំងលាវ ដែល
ដឹកនាំដោយជួននិងនៅ សុទ្ធសឹងជាខ្មែរ
ប្រកបដោយឆន្ទៈមនសិការក្នុងការតស៊ូដើម្បីការ
រស់នៅប្រកបដោយភាពជាអ្នកជា។ អ្នកទាំងនោះ
មិនមែនមិនដឹងសោះទេថា *"បើយើងសម្លាប់គេបាន
មួយ គេនឹងសម្លាប់យើងវិញពីដប់ទៅម្ភៃនាក់"* ។
បើទោះជាយ៉ាងនេះក្តីកំហុសកំណត់ដាច់ខាតនៅតែតស៊ូ

www.elibraryofcambodia.org

ដើម្បីបញ្ចប់ទារុណកម្ម និរាសកម្ម សោកនាដកម្ម
របស់របស់ប្រជាជនខ្មែរនៅក្នុងខេត្តកំពុងឆ្នាំង
សម័យនោះអ្នកតស៊ូនៅក្នុងរឿងខាងលើបាន
បាត់បង់កាយក្លាយទៅជាដែនដីអស់ទៅហើយក៏
ពិតមែន តែកិត្តិយសកេរ្តិ៍ឈ្មោះ និងដួងព្រលឹង
របស់គេនៅរស់ជាអមត:ក្នុងសន្ធានចិត្តកូនខ្មែរគ្រ
ប់ៗជំនាន់។ បើមើលមកក្នុងអត្ថបទ "ពាក្យមួយ
គ្រាប់" ដែលដកស្រង់ចេញពីសៀវភៅ "អាចារ្ય
ហែមចៀវវីរបុរសជាតិ" លោក គង់ សម្ភារ បានធ្វើ
ការបំផុសឆ្លុះឱ្យឃើញអំពីវីរជនខ្មែរ គឺព្រះគ្រូអាចា
រ្យហែមចៀវ ទោះបីលោកជាសង្ឆក៏គង់ធ្វើការតស៊ូ
ដោយមិនស្តាយជីវិតជន្ម ដើម្បីបុព្វហេតុជាតិរបស់
ខ្លួន។ លោកគ្រូបានសុគតនៅពន្ធនាគារកោះ
ក្រឡាចក្នុងព្រះជន្ម៤៥វស្សា ក្រោមការធ្វើទារុណ
កម្មរបស់ពួកអាណានិគមបារាំងជំនាន់នោះ។ ក្នុង
រឿងរ៉ាវដូចគ្នានេះដែរ ក្រឡាហោមគង់ក៏ជាវីរជន

www.elibraryofcambodia.org

ក៏សុទ្ធតែបានតស៊ូប្តូរសង្ហារប្រឆាំងនឹងការធ្វើបាប
របស់សត្រូវ ទីបំផុតត្រូវបានបារាំងចងផ្ទោបខ្លួន
លោកទៅនឹងបំពង់ផ្សែងកប៉ាល់រហូតទាល់តែ
ក្សិណក្ស័យអាយុជីវិត។

ដូចនេះបើនិយាយឱ្យខ្លីក្នុងអត្ថន័យជាសរុប
ទៅឃើញថា មនុស្សម្នាខ្មែរជំនាន់ដើមតែងតែបាន
តម្កល់ឆន្ទៈមនសិការដ៏ខ្ពង់ខ្ពស់ជាមួយនឹងឧត្តម
គតិស្នេហាជាតិដ៏ជ្រាលជ្រៅ ដោយហ៊ានធ្វើ
ពលិកម្មគ្រប់យ៉ាង រហូតដល់ហ៊ានបរិច្ចាគសង្ហារ
ដើម្បីកិត្យានុភាពរបស់ជាតិ ជាប្រយោជន៍ដល់
មនុស្សគ្រប់ជំនាន់។

តាមការបកស្រាយរៀបរាប់រឿងរ៉ាវរួចបកខាង
លើ ធ្វើឱ្យយើងអាចសន្និដ្ឋានបានថាទស្សនៈរបស់
ប្រធានពិតជាបានផ្សារភ្ជាប់នឹងតថភាពមួយ។
យើងដែលជាខេមរជនត្រូវបន្តរៀនសូត្រយកតាម
ឧត្តមគតិ តាមគំរូវីរភាពរបស់ដូនតា ដើម្បីជាគុណ

www.elibraryofcambodia.org

ប្រយោជន៍ក្នុងកិច្ចការពារ ក៏ដូចជាការកសាងជាតិ
មាតុភូមិរបស់យើងឱ្យសម្បូរសប្បាយ ចូរធ្វើការស្ដុក
ស្ដម្ភដូចសម័យមហានគរបុរាណ។

www.elibraryofcambodia.org

ទស្សនៈខ្លះលើកឡើងថា "ជនលះបង់សេចក្ដីសុខផ្ទាល់ខ្លួនដើម្បីជាតិ ត្រូវបានចាត់ទុកជាវីរជន"។ តើឃ្លានេះមានអត្ថន័យដូចម្ដេច? ចូរពន្យល់។

សេចក្ដីអធិប្បាយ

ជនទាំងឡាយតែងតែធ្វើអ្វីៗដើម្បីសេចក្ដីសុខផ្ទាល់ខ្លួន ប៉ុន្តែក៏មានជនមួយចំនួនដែលហ៊ានធ្វើអ្វីៗទាំងអស់យ៉ាងក្លាហាន ដោយហ៊ានលះបង់នូវសេចក្ដីសុខផ្ទាល់ខ្លួន ដើម្បីបុព្វហេតុជាតិមាតុភូមិរបស់ខ្លួន។ ដោយសារវីរភាពនេះហើយ ទើបមានទស្សនៈមួយ លើកឡើងថា "ជនលះបង់សេចក្ដីសុខផ្ទាល់ខ្លួនដើម្បីជាតិ ត្រូវបានចាត់ទុកជាវីរជន"។

តើទស្សនៈខាងលើមានអត្ថន័យយ៉ាងណា?

ដើម្បីងាយស្រួលក្នុងការបកស្រាយ ជាដំបូងយើងគួរគប្បីយល់ពាក្យវីរជនជាមុនសិន។ វីរជនគឺ

www.elibraryofcambodia.org

សំដៅទៅលើជនទាំងឡាយដែលមានចិត្តរឹងប៉ឹង ក្លាហាន ហ៊ានធ្វើអ្វីៗទាំងអស់ដើម្បីជាតិមាតុភូមិ ទោះបីអាយុសង្ខារកំពុងស្គាយស្រណោះដែរ។

រីឯជនទាំងឡាយតែងលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីជាតិដោយគ្មានស្គាយស្រណោះ សេចក្តីសុខផ្ទាល់ខ្លួនមានមូលដ្ឋានធំៗ ដូចជាអាយុជីវិត កិត្តិយស បុណ្យសក្តិ ទ្រព្យសម្បត្តិ និងចំណងគ្រួសារជាដើម។ ជនទាំងឡាយណាដែលហ៊ានលះបង់នូវអ្វីៗទាំងនេះបានត្រូវចាត់ទុកជាវីរជន។ ជាក់ស្តែង បើគេក្រឡេកមើលក្នុងប្រវត្តិសាស្ត្រខ្មែរ ក៏ឃើញមានជនជាច្រើនដែលបានចាត់ទុកជាវីរជន ដូចជាក្រឡាហោមគង់ អាចារ្យស្វា ពោធិ៍ កំបោរ អាចារ្យហ៊ីមចៀវ សុទ្ធតែជាវីរជននៅសតវត្សទីដប់ប្រាំបួន និងសតវត្សទីម្ភៃ។ ជនទាំងនេះ បានលះបង់នូវអ្វីៗគ្រប់បែបយ៉ាង ដើម្បីប្រឆាំងនឹងការជិះជាន់សង្កត់សង្កិនរបស់ពួកអាណានិគម

www.elibraryofcambodia.org

និយមបារាំង ហើយទាមទារឯករាជ្យសេរីភាពជូនជាតិខ្មែរ ពិសេសលោកអាចារ្យហែមចៀវ លោកបានដឹកនាំធ្វើបាតុកម្មប្រឆាំងបារាំងដែលចង់បំបាត់អក្សរសាស្ត្រខ្មែរ រហូតបារាំងចាប់ផ្សឹកបញ្ជូនទៅដាក់គុកនៅកោះត្រឡាច ហើយបានបាត់បង់ជីវិតនៅទីនោះទាំងវ័យក្មេង។ ចំពោះការទាមទារឯករាជ្យនេះ ព្រះបាទនរោត្តមសីហនុព្រះអង្គបានលះបង់សេចក្តីសុខរបស់ទ្រង់ពីក្សត្រនៅក្នុងវាំង ទៅរត់ចូលរយោបាយ ធ្វើការតស៊ូតាមបែបការទូតប្រឆាំងនឹងបារាំង ដោយព្រះអង្គបានទៅទាក់ទងនឹងប្រទេសជាមិត្តឱ្យគាំទ្រ និងគាបសង្កត់ទៅលើប្រទេសបារាំង ដើម្បីឱ្យដកនឹមត្រួតត្រាចេញពីកម្ពុជា។ ដោយវីរភាពរបស់ព្រះអង្គ បារាំងក៏សុខចិត្តប្រគល់ឯករាជ្យឱ្យខ្មែរជាស្ថាពរនៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំមួយពាន់ប្រាំបួនរយហាសិបបី។ បើក្រឡេកមើលសម័យក្រោយអង្គរ គេកំបាន

www.elibraryofcambodia.org

ឃើញឧកញ៉ាមឿងដែលបានធ្វើតណ្ដាកម្មដ៏អស្ចារ្យ
គឺធ្វើអត្តឃាតដើម្បីទៅកែនទ័ពខ្មោចមកជួយច្បាំង
ដើម្បីការពារទឹកដីឱ្យនៅគង់វង្ស ជៀសផុតពីការ
ឈ្លានពានរបស់ពួកសៀម។ ចំណែកក្នុងអក្សរ
សិល្ប៍វិញ យើងឃើញមានតួអង្គខ្លះដែលអាចចាត់
ទុកជាវីរជនដែរ ដូចរឿងភូមិតិរច្ឆាន ជួននិងនៅត្រូវ
បានប្រជាជនខ្មែរចាត់ទុកជាវីរជន ព្រោះទង្វើរបស់
ពួកគេធ្វើឡើងដើម្បីប្រឆាំងនឹងបារាំង សង្គ្រោះ
ប្រជាជនអ្នកខេត្តកំពុងឆ្នាំងឱ្យរួចផុតពីការជិះជាន់
របស់បារាំងម្នាក់ឈ្មោះ បារដេស ដូចជួនពោលថា
"ខ្ញុំចង់សម្លាប់បារាំងកំណាចពេលនេះគឺក្នុងនាម
ខ្មែរម្នាក់ដែលមិនសុខចិត្តនឹងអំពើជិះជាន់ឃ្លាង
អមនុស្សធម៌ពីសំណាក់បារាំង"។ នៅបានពោល
បន្ថែមថា "រឿងនេះមិនមែនឆាកកំប្លែងទេ គឺមានស្លាប់
មានរស់ មានស៊ីមានសង ព្រោះបារាំងគេមាន
អំណាចលើខ្មែរយើង...។ ដូចនេះបើបងប្អូនណា

www.elibraryofcambodia.org

ហ៊ានស្ម័គ្រចិត្តសម្លាប់បារ៉ាំងឈ្មោះបារដេសនេះ ត្រូវតែតាំងចិត្តជាមុនឱ្យស្រេចថា អញសម្លាប់បារ៉ាំង បារ៉ាំងនឹងសម្លាប់អញវិញ"។ ចំពោះនាងនី នាងប៉ីក៏បានរួមចំណែកក្នុងបុព្វហេតុសិទ្ធិសេរីភាព និងយុត្តិធម៌ជូនប្រជាជនខ្មែរដែរ ដោយនាងបានប្រើសម្ព័ន្ធាយប្រហារលើបារដេសយ៉ាងក្លាហាន។ ក្នុងរឿងគូលីកំណែន ម៉ឹងសុខចិត្តលះបង់មុខតំណែងដ៏ខ្ពង់ខ្ពស់ សង្ឃរាជដ៏ឧត្តម រត់ចូលព្រៃដើម្បីតស៊ូប្រឆាំងនឹងពួកអាណានិគមនិយមបារ៉ាំងរហូតដល់ពិការដៃម្ខាង។ រ៉ែងយ៉ីម (ឧបាសកខ្ចីចជើង) ក៏បានបញ្ចេញវីរភាពដើម្បីបុព្វហេតុជាតិយ៉ាងខ្លាំងក្លាដែរ។ លោកបានចល័តទ័ពលំនៅជាញឹកញាប់ ព្រោះតែគេចពីការតាមចាប់របស់បារ៉ាំង ពីបន្ទាត់នៅកម្ពុជាក្រោម បន្ទាត់នៅកម្ពុជាកណ្តាល ដើម្បីរៀបចំផែនការរំដោះជាតិ។ បើមើលនៅក្នុងរឿងរាមកេរ្តិ៍ មានវីរជនស្នេហាជាតិជាច្រើន គួយ៉ាង

www.elibraryofcambodia.org

ពាលី កុម្ភការណ៍ ឥន្ទជិត ដើម្បីជាតិសុខចិត្តស្លាប់ ដោយមិនព្រមចុះញ៉ូមនឹងសត្រូវ សុខចិត្តច្បាំងលុះតំណាក់ឈាមចុងក្រោយ ទោះដឹងថាច្បាំងមិនឈ្នះក៏ដោយ។

រួមសេចក្តីមក ជនម្នាក់នឹងក្លាយជាវីរជនទៅបាន លុះត្រាតែជននោះសុខចិត្តលះបង់សេចក្តីសុខផ្ទាល់ខ្លួន ហើយខិតខំធ្វើរឿងទាំងអស់ដើម្បីបុព្វហេតុជាតិ បុព្វហេតុប្រជាជន ពោលគឺគិតពីផលប្រយោជន៍រួមជាធំ ដោយហ៊ានលះបង់រហូតដល់ជីវិតទៀតផង។

ឆ្លងតាមការស្រាយរួចមកឃើញថា ទស្សនៈរបស់ប្រធានមានអត្ថន័យជ្រាលជ្រៅប្រសើរ ព្រោះវាបានអប់រំក្រើនរំលឹកដល់សាធារណជនទាំងឡាយឱ្យហ៊ានលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីសេចក្តីសុខរបស់មនុស្សជាតិ និងសង្គមជាតិទាំងមូល។ ហេតុនេះ យើងជាកុលបុត្រខ្មែរគ្រប់រូបគប្បី

www.elibraryofcambodia.org

ធ្វើអ្វីជាឧត្តមប្រយោជន៍ទោះតិចក្តីច្រើនក្តីសម្រាប់
ជាតិមាតុភូមិ ហើយបើមិនបានសាងប្រយោជន៍
ជាតិទេនោះ គួរកុំបំផ្លាញកេរដូនតា ឬរបស់ជាតិ។

www.elibraryofcambodia.org

> គេលើកឡើងថា "ព្រះពុទ្ធសាសនាមានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចស្ថាបនាលទ្ធិប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គមខ្មែរនាពេលបច្ចុប្បន្ន"។ ចូរស្រាយបំភ្លឺទស្សនៈនេះ។

សេចក្តីអធិប្បាយ

ក្នុងសង្គមខ្មែរបច្ចុប្បន្ន ប្រជាជនភាគច្រើននៅតែមានជំនឿគោរពទៅលើព្រះពុទ្ធសាសនា ព្រោះសាសនានេះបានលើកតម្លៃមនុស្ស មានគោលទ្រឹស្តីសំខាន់ៗអប់រំមនុស្សឱ្យដើរក្នុងផ្លូវល្អ ដើម្បីរួមចំណែកក្នុងការស្ថាបនាសង្គមឱ្យរីកចម្រើន។ យ៉ាងនេះហើយទើបបានជាគេលើកឡើងថា "ព្រះពុទ្ធសាសនាមានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចស្ថាបនាលទ្ធិប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គមខ្មែរនាពេលបច្ចុប្បន្ន"។

www.elibraryofcambodia.org

តើទស្សនៈនេះមានអត្ថន័យ និងខ្លឹមសារយ៉ាងណាខ្លះ?

ដើម្បីសម្រួលដល់ការបកស្រាយប្រធាន យើងគួរយល់ពាក្យមួយចំនួនជាមុនសិន។ ពាក្យព្រះពុទ្ធសាសនាមានន័យថា ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដើម្បីឆ្ពោះទៅរកសេចក្តីសុខ។ ឯពាក្យសំខាន់មានន័យថា ដែលចាំបាច់មិនអាចខ្វះបាន។ រីឯលទ្ធិប្រជាធិបតេយ្យមានន័យថា លទ្ធិដែលគេចាត់ទុករាស្ត្រជាធំ ហើយមេដឹកនាំកើតចេញពីការបោះឆ្នោតរបស់រាស្ត្រ និងមានការគោរពសិទ្ធមនុស្ស។ ចំណែកវឌ្ឍនភាព គឺភាពរីកចម្រើនរុងរឿង។ ន័យប្រធានបានសេចក្តីថា ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធមានតួនាទីចាំបាច់មិនអាចខ្វះបានក្នុងកិច្ចស្ថាបនាសង្គមខ្មែរ និងការបង្កើតឱ្យមានការគោរពសិទ្ធិមនុស្ស ដើម្បីឱ្យសង្គមមានការរីកចម្រើន។

www.elibraryofcambodia.org

ជាការពិតណាស់ ព្រះពុទ្ធសាសនាបានសម្ពះ
ចូលប្រទេសខ្មែរតាំងពីយូរមកហើយព្រមទាំងចាក់
ឫសយ៉ាងមាំនៅក្នុងខួរក្បាលខ្មែរគ្រប់រូបភាព។
ការដែលប្រជាជនមានជំនឿបែបនេះ ដោយសារ
លទ្ធិព្រះពុទ្ធសាសនាប្រៀបបាននឹងយានដ៏ឧត្តុង្គ
ឧត្តមអាចជួយសង្គមខ្មែរឱ្យឆ្ពោះទៅដល់ត្រើយ
សុភមង្គលបាន ព្រោះគោលទ្រឹស្តីពុទ្ធសាសនា
បានបង្កើតជីវិតអប់រំមនុស្សយ៉ាងសម្បូរបែប ដូច
ជាព្រះពុទ្ធសាសនាអប់រំមនុស្សថា "ធ្វើល្អបានល្អ
ធ្វើអាក្រក់បានអាក្រក់ ធ្វើបុណ្យបានបុណ្យ" ពោល
គឺត្រូវតែសាងចិត្តឱ្យស្អាតបរិសុទ្ធ ទូលំទូលាយ មិន
បៀតបៀន មិនគុំគួនព្យាបាទ ហើយប្រកាន់ខ្ជាប់នូវ
ព្រហ្មវិហារធម៌ បំបាត់អំពើហិង្សា ដើម្បីឱ្យសង្គមរីក
ចម្រើនស្ថិតក្នុងសន្តិភាព។

ជាងនេះទៅទៀតដើម្បីឱ្យលទ្ធិប្រជាធិបតេយ្យ
ដំណើរការល្អ ហើយសង្គមខ្មែរមានការអភិវឌ្ឍ

www.elibraryofcambodia.org

គ្មានការកាប់សម្លាប់គឺគេត្រូវការជាចាំបាច់នូវទ្រឹស្តី
ព្រះពុទ្ធសាសនាដូចជា *បាណាតិបាតា* មានន័យ
ថា កុំប្រមាថ កុំសម្លាប់ជីវិតអ្នកដទៃ ត្រូវឱ្យតម្លៃ
គ្រប់ជីវិតមនុស្សសត្ត។ មនុស្សទាំងអស់សុទ្ធតែ
ស្រឡាញ់ជីវិតគ្រប់គ្នា យ៉ាងណាមិញក្នុងច្បាប់
សិទ្ធិមនុស្សបានចែងថា គ្មាននរណាហ៊ានដកហូត
ជីវិតនរណាម្នាក់បានឡើយ ហើយសិទ្ធិរស់រាន
មានជីវិតជាសិទ្ធិចម្បងបំផុតដែលមនុស្សមានតាំង
ពីកំណើត។ លើសពីនេះទៀតព្រះពុទ្ធសាសនា
មានឱវាទថា មនុស្សទាំងអស់សុទ្ធតែជាភាតរជន
យ៉ាងណាមិញក្នុងលទ្ធិប្រជាធិបតេយ្យមានន័យថា
មនុស្សគ្រប់ជាតិសាសន៍ទាំងអស់មិនត្រូវប្រកាន់
វណ្ណៈ ពណ៌សម្បុរ ជាតិសាសន៍ ភេទនោះទេ ទើប
សង្គមមានការរីកចម្រើន និងមាននិរន្តរភាព។
ម្យ៉ាងវិញទៀត ជម្រកព្រះពុទ្ធសាសនា គឺវត្តអារាម
ទាំងឡាយជាកន្លែងសម្រាប់បណ្តុះបណ្តាល

www.elibraryofcambodia.org

មនុស្សខ្មែររាប់សិបនាក់នៅស្នើរគ្រប់សម័យកាល ឱ្យមានចំណេះដឹង ព្រោះវត្តអារាមជាសាលាពហុ បច្ចេកទេស និងជាអ្នកថែរក្សាវប្បធម៌ប្រពៃណី ព្រលឹងខ្មែរ។ វត្តអារាមបានជួយជនក្រីក្រ សិស្ស និស្សិតក្រីក្រ ក្មេងកំព្រាអនាថា បានពឹងពាក់ស្នាក់ អាស្រ័យរាប់សិបនាក់តាំងពីរស់នៅរហូតស្លាប់ក៏ មាន។ ឥឡូវវត្តអារាមបានក្លាយជារមណីយដ្ឋាន យ៉ាងប្រណីតសម្រាប់ទេសចរជាតិ និងអន្តរជាតិ ចូលមកទស្សនាកម្សាន្តទៀតផង។ តួយ៉ាងវត្តភ្នំ វត្ត ព្រះកែវមរកត វត្តឧណ្ណាលោមជាដើម។ គេឃើញ ព្រះពុទ្ធសាសនាបានជួយជំរុញលទ្ធិប្រជា ធិបតេ យ្យ ដោយបង្កប់ការអប់រំជាច្រើនក្នុងពេលព្រះ សង្ឆសម្តែងធម៌ទេសនាម្តងៗ។ វត្តអារាមសព្វថ្ងៃ បានផ្តល់ជាជម្រកដល់សិស្សនិស្សិតក្រីក្រមកពីទី ឆ្ងាយឱ្យស្នាក់នៅយ៉ាងសមរម្យ។ បើគេក្រឡេក មើលក្នុងស្នាដៃអក្សរសិល្ប៍រឿងគូលីកំណែន គេ

www.elibraryofcambodia.org

នឹងបានឃើញពីសារៈសំខាន់នៃព្រះពុទ្ធសាសនា ដូចជាលឹមបានស្នាក់នៅ និងរៀនសូត្រក្នុងវត្ត អារាមរហូតក្លាយជាមនុស្សល្អត្រឹមត្រូវ។ នាងហោងក្រោយពេលស្លាប់ទៅបានយកទៅទុកនៅឯវត្តដើម្បីងាយស្រួលក្នុងការធ្វើបុណ្យទាន។

រួមសេចក្តីមកលទ្ធិប្រជាធិបតេយ្យព្រះពុទ្ធសាសនាបានអប់រំមនុស្សឱ្យធ្វើល្អ ធ្វើអ្វីដែលជាប្រយោជន៍សម្រាប់មនុស្សផងគ្នា បានសេចក្តីថាបង្កើតភាពយោគយល់គ្នាចេះស្តាប់អ្នកដទៃ គោរពមតិភាគច្រើន ជាហេតុធ្វើឱ្យប្រជាធិបតេយ្យកើតឡើង ហើយក៏បានជំរុញឱ្យមានការអភិវឌ្ឍទទឹមគ្នានោះដែរ។

ឆ្លងតាមការបកស្រាយមកខាងលើឃើញថាទស្សនៈរបស់ប្រធានមានអត្ថន័យ និងខ្លឹមសារល្អប្រពៃណាស់ ព្រោះព្រះពុទ្ធសាសនាជាគោលគ្រឹះរបស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ នៅ

www.elibraryofcambodia.org

ពេលដែលខ្មែរចេះប្រតិបត្តិលទ្ធិប្រជាធិតេយ្យ និងគោរពសិទ្ធិមនុស្សហើយពេលនោះសង្គមពិតជាមានវឌ្ឍនភាពជាក់ជាមិនខាន។ ដូចនេះយើងជាពុទ្ធសាសនិកជំនាន់ក្រោយត្រូវប្រតិបត្តិលទ្ធិព្រះពុទ្ធសាសនាឱ្យបានខ្ជាប់ខ្ជួន និងប្រព្រឹត្តឱ្យបានត្រឹមត្រូវទើបធ្វើឱ្យយើង ព្រមទាំងសង្គមជាតិមានសន្តិភាព និងមានការរីកចម្រើន។

www.elibraryofcambodia.org

គេថា "ការដណ្តើមមុខតំណែងជាការងាយស្រួល តែការរក្សាមុខតំណែងទើបជាការលំបាក" ចូរស្រាយបំភ្លឺដោយលើកឧទាហរណ៍ពីក្នុងអក្សរសិល្ប៍មកបញ្ជាក់ផង។

សេចក្តីអធិប្បាយ

មនុស្សគ្រប់រូបតែងប្រាថ្នាចង់រស់នៅសុខស្រួល មានកិត្តិយស និងមានអំណាច ពោលគឺរស់នៅក្នុងមុខតំណែងមួយ សមរម្យ។ បញ្ហាមុខតំណែងជាបញ្ហាស្មុគស្មាញបំផុតដែលធ្វើឱ្យមនុស្សពិបាកនឹងថែរក្សាវាឱ្យនៅគង់វង្ស ប៉ុន្តែមុខតំណែងនេះងាយនឹងបានមកប្រសិនបើមនុស្សអ្នកនិងដណ្តើមយក។ ដូចនេះហើយទើបមានមតិមួយពោលថា "ការដណ្តើមមុខតំណែងជាការងាយស្រួល តែការរក្សាមុខតំណែងទើបជាការលំបាក"។

www.elibraryofcambodia.org

តើទស្សនៈខាងលើនេះមានអត្ថន័យដូចម្តេចខ្លះ?

ដើម្បីងាយស្រួលដល់ការបកស្រាយ ជាបឋមតម្រូវឲ្យយល់ពាក្យ *ដណ្តើមយក មុខតំណែង* និង *រក្សាជាមួយ*សិន។ ដណ្តើមយក គឺប្រជែងយកវាយប្រយុទ្ធយក។ ឯពាក្យមុខតំណែង គឺសំដៅលើមុខងារដែលត្រូវបានតែងតាំងឲ្យគ្រប់គ្រងកន្លែងណាមួយ។ ចំណែកឯពាក្យរក្សា មានន័យថា ធ្វើឲ្យនៅគង់វង្សល្អ។ បានសេចក្តីថា ការប្រជែងយកមុខងារដែលត្រូវបានតែងតាំងឲ្យគ្រប់គ្រងកន្លែងណាមួយ គឺជាការមិនលំបាកពេកទេ តែការធ្វើឲ្យគង់វង្សល្អនូវមុខងារដែលត្រូវបានតែងតាំងឲ្យគ្រប់គ្រងកន្លែងណាមួយនោះទើបជាការលំបាក។

ជាការពិត មនុស្សត្រូវការដណ្តើមយកមុខតំណែង ពីព្រោះមុខតំណែងតែងបានមកដោយសារការមានសមត្ថភាពខ្ពស់។ ចំណុចនេះគេអាច

www.elibraryofcambodia.org

ព័ន្ធ៍ណ្ឍក្នុងប្រវត្តិសាស្ត្រក៏ឃើញថា ស្តេចភាគច្រើន
ដែលបានឡើងសោយរាជ្យក៏ដោយ ខ្លួនមាន
ចំណេះ និងសមត្ថភាព បានវាយយកមុខតំណែង
ឬប្រកាសមុនពីណែងរបស់ខ្លួនតែម្តង។ ជាក់ស្តែង
ក្នុងរឿងតេជាយ៉ាត ស្តេចសម្រែអាងខ្លួនចេះយុទ្ធ
គុន ក៏បានបះបោរប្រកាសខ្លួនជាស្តេចតែម្តង។
ម្យ៉ាងទៀតមុខតំណែងតែងបានមកដោយសារការ
ប្រើល្បិចពិសពុលដណ្តើមយកតាមមធ្យោបាយ
ផ្សេងៗ មានក្តៅត្រជាក់ជាដើម។ ឥឡូវ ក្នុងរឿង
ក្រុងសុភមិត្ត ដើម្បីអំណាចមុខតំណែង ក្រុង
អសុភមិត្តជាប្អូនបានប្រើល្បិចពិសពុលធ្វើរដ្ឋ
ប្រហារបណ្តេញក្រុងសុភមិត្តជាបងឱ្យចេញពី
តំណែងជាព្រះរាជ ហើយខ្លួនបានឡើងទៅអង្គុយ
លើរាជបល្ល័ង្ក ដោយឥតអៀនខ្មាស់។ លើសពីនេះ
ទៅទៀតនោះ មុខតំណែងតែងបានមកពីការវាយ
ដណ្តើមយកដោយប្រើកម្លាំងកាយ កម្លាំងចិត្ត និង

www.elibraryofcambodia.org

ប្រាជ្ញា។ បើគេក្រឡេកមើលក្នុងរឿងរាមកេរ្តិ៍ក៏បាន
ឃើញយ៉ាងច្បាស់ថា តំណែងរបស់ទ្ធភីក៏បានមក
ដោយការវាយដណ្តើមយកពីឪពុកមហិង្សារាជ
ហ្ជតបានជោគជ័យ។ ទ្ធភីក៏ជំនួសកន្លែងឪពុក
ហើយបន្តបេសកកម្មដូចឪពុកទៀត។ មិនតែ
ប៉ុណ្ណោះមុខតំណែងខ្លះអាចបានមកដោយសារ
ជំនួយពីអ្នកដទៃ ដូចជាសុគ្រីព។ សុគ្រីពដែលបាន
មុខតំណែងជាស្តេចសោយរាជ្យនៅខាស់ខិនបុរី ក៏
ដោយសារមានព្រះរាមជួយជ្រោមជ្រែង គឺព្រះរាម
បានជួយសម្លាប់ពាលីជាបង និងផ្តល់អំណាចឱ្យ
សុគ្រីពតែម្តង។ ក្រៅពីនេះមុខតំណែងក៏អាចបាន
មកដោយសារការចេះលុតក្រាបវាយអែបស៊ីអប ឬ
ចំណាយទ្រព្យទិញទៀតផង។ ជាក់ស្តែងនៅក្នុង
រឿងគ្ងលីកំណែន ពូជាន់បានក្លាយជាមេឃុំគោក
ចំបក់ ក៏ព្រោះពូជាន់ពូកែអែបអបយកចិត្តថ្លើមរាជ

www.elibraryofcambodia.org

ការនៅសម័យនោះរួមផ្សំនឹងទ្រព្យផង រាជការក៏
សម្រេចតែងតាំងពួជាន់ជំនួសតាកឹមទៅ។

ការដណ្តើមមុខតំណែងមិនសូវពិបាកទេ ប៉ុន្តែ
ការរក្សាមុខតំណែងទើបជាការលំបាក ព្រោះមុខ
តំណែងដែលយើងចង់បានអ្នកឯទៀតក៏ចង់បាន
ដែរ។ នេះជាមហិច្ឆតា ជាបញ្ហារបស់មនុស្សទូ
ទៅ។ ជាក់ស្តែងនៅក្នុងសង្គ្រាមគេតែងឃើញ
មនុស្សទាំងឡាយខិតខំប្រជែងគ្នាវាយប្រយុទ្ធគ្នា
ឬបង្កើតជាគណបក្សដើម្បីបោះឆ្នោតដណ្តើម
តំណែងជានាយករដ្ឋមន្ត្រី ប្រធានាធិបតី ប្រមុខរដ្ឋ
ជាដើម។ បន្ថែមលើនេះទៀតគេពិបាកនឹងគេចឱ្យ
ផុតពីកត្តាដើម្បីឡើងកាន់តំណែង ដោយហេតុថា
លកក្រោយតែងតែរុញច្រានលកមុខឱ្យខ្ជប់ច្រាំង
រស់មានសកម្មភាពតទៅទៀត។ គួយ៉ាងមហិច្ឆា
រាជក្នុងរឿងរាមកេរ្តិ៍ដែលតែងតែគំរាមកំហែងកាប់
សម្លាប់អ្នកដទៃសូម្បីតែកូនប្រុសឯងក៏មិនទុកដែរ

www.elibraryofcambodia.org

ប៉ុន្តែក្រោយមកកំ្ពុជាកាត់ដៃទ្ធ ក៏ជាកូនរបស់ខ្លួន។ ម្យ៉ាងវិញទៀតមុខតំណែងអាចគង់វង្សបានទាល់តែអ្នកនោះចេះគ្រប់គ្រងមានទេពកោសល្ស និងសមត្ថភាពគ្រប់គ្រាន់។ ជនដែលមានសមត្ថភាពគ្រប់គ្រាន់ទាល់តែជននោះមានវិជ្ជាសម្ផត្តិ ពោលគឺមានចំណេះគ្រប់មុខ មានចរិយាធម៌ គឺមានសីលធម៌ មនុស្សធម៌ ចិត្តនឹងនរ និងគិតបានវែងឆ្ងាយ។ ដូចនៅក្នុងរឿងព្រះអាទិត្យថ្មី ព្រះបាទនរោត្តមសីហនុព្រះអង្គអាចរក្សាតំណែងបានគង់វង្ស និងធ្វើឱ្យប្រទេសរីកចម្រើន ក៏ដោយព្រះអង្គមានវិជ្ជាសម្ផត្តិយ៉ាងមុតមាំ និងរឹងប៉ឹងដែលគ្មានមេដឹកនាំណាប្រៀបជាមួយព្រះអង្គបានឡើយ។

រួមសេចក្ដីមកការដណ្ដើមយកមុខតំណែង គឺជាការងាយស្រួលពីព្រោះកត្តានេះរាចរកើតឡើងក្រោមរូបភាពជាច្រើនយ៉ាងដែលមិនសូវមានភាពធ្ងន់ធ្ងរទេ។ ចំណែកការរក្សាមុខតំណែងទើបជា

www.elibraryofcambodia.org

ការលំបាក ព្រោះបញ្ហានេះទាមទារនូវសមត្ថភាពខ្ពស់មានចំណេះក្នុងការគ្រប់គ្រង ហើយពោរពេញទៅដោយទេពកោសល្យទៀតផង។ ហេតុនេះ ហើយអ្វីដែលយើងចង់បានគេក៏ចង់បានដែរ។

ឆ្លងតាមការបកស្រាយខាងលើ យើញថាពំនោលរបស់ប្រធានផ្តល់ជាគតិដ៏ល្អសម្រាប់អប់រំមនុស្សចេះស្វែងរក និងរក្សាមុខតំណែងរបស់ខ្លួនឱ្យគង់វង្ស។ ដូចនេះដើម្បីឈានទៅរកមុខតំណែងប្រសើរបានមនុស្សគ្រប់រូបត្រូវខិតខំរៀនសូត្រ ហាត់ពត់លត់ដំឱ្យបានល្អប្រសើរទើបអាចរកសុភមង្គលល្អឃើញ។

www.elibraryofcambodia.org

មតិខ្លះថា "នៅក្នុងសង្គមខ្មែរ ស្ត្រីគឺជាអ្នកកំណត់ភាពគង់វង្ស និងភាពរីកចម្រើនរបស់សង្គមជាតិ"។ ចូរស្រាយបំភ្លឺ។

សេចក្តីអធិប្បាយ

តាំងពីអតីតកាលរហូតដល់បច្ចុប្បន្ន សង្គមខ្មែរនៅគង់វង្ស និងរីកចម្រើនកំដោយសារតែមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋគ្រប់ស្រទាប់ ក្នុងនោះស្ត្រីគឺជាកម្លាំងចលករដ៏សំខាន់ក្នុងការការពារ និងកសាងសង្គមដោយមិនអាចខ្វះបាន។ ហេតុនេះហើយទើបមានមតិខ្លះពោលថា "នៅក្នុងសង្គមខ្មែរស្ត្រីគឺជាអ្នកកំណត់ភាពគង់វង្ស និងភាពរីកចម្រើនរបស់សង្គមជាតិ"។

តើទស្សនៈខាងលើនេះមានអត្ថន័យយ៉ាងដូចម្តេចខ្លះ?

www.elibraryofcambodia.org

ដើម្បីងាយស្រួលក្នុងការបកស្រាយនូវមតិ
របស់ប្រធាន ជាបឋមយើងគួរយល់ពាក្យស្ត្រី
គង់វង្ស និងរីកចម្រើនជាមុនសិន។ ស្ត្រីគឺសំដៅលើ
មនុស្សស្រីទូទៅ។ រីឯពាក្យគង់វង្សមានន័យថា
ស្ថិតស្ថេរចីរកាលមិនបាត់បង់។ ចំណែកឯពាក្យរីក
ចម្រើន គឺសំដៅលើការវិវត្តឡើងឈានទៅរកភាព
រុងរឿង។ នេះបានសេចក្ដីថា នៅក្នុងសង្គមខ្មែរ
មនុស្សស្រីជាអ្នកកំណត់ភាពស្ថិតស្ថេរគង់វង្ស និង
ការវិវត្តឈានឡើងទៅរកភាពរុងរឿងរបស់សង្គម
ជាតិ។

ពិតមែនហើយនៅក្នុងសង្គមខ្មែរ ស្ត្រីពិតជាអ្នក
កំណត់ភាពគង់វង្ស និងភាពរីកចម្រើនរបស់សង្គម
ដោយហេតុថាស្ត្រីបានចូលរួមការពារ និងកសាង
សង្គមខ្មែរយ៉ាងមុះមុតនៅគ្រប់សម័យកាល។ ភាព
គង់វង្សរបស់សង្គមតែងកើតឡើងពីការការពារ
របស់ស្ត្រី ដូចជាស្ត្រីបានការពារទឹកដីប្រឆាំងនឹង

www.elibraryofcambodia.org

បរទេសឈ្លានពាន។ គ្ងយ៉ាងរឿងព្រលឹងប្រាសាទ
បន្ទាយស្រីរបស់លោកទ្រីជីហ្ងត បានបង្ហាញពីគំរូវីរ
ភាពដ៏អង់អាចក្លាហានរបស់ស្ត្រីខ្មែរប្រឆាំងនឹងការ
ឈ្លានពានរបស់បរទេស។ ស្ត្រីក៏ជាអ្នកការពារ
សន្តិសុខជូនសង្គមជាតិប្រឆាំងនឹងជនបះបោរ
ទៀតផង។ ជាក់ស្តែង ជំទាវស្រែននៅក្នុងរឿង
តេជោយ៉ត បានចេញទៅកម្ចាត់ជនបះបោរគឺស្តេច
សម្រែ ធ្វើឱ្យសង្គមមានសន្តិសុខល្អវិញ។ ស្ត្រីក៏ជា
អ្នកការពារអត្តសញ្ញាណជាតិ ភាពថ្លៃថ្នូររបស់ជាតិ
ប្រឆាំងនឹងការជិះជាន់របស់បរទេស ដែលតែង
មើលងាយខ្មែរ។ ជាក់ស្តែងនៅក្នុងរឿងភូមិតិរច្ឆាន
នាងនីនាងប៉ីបានចេញមុខការពារជាតិខ្មែរយ៉ាង
ខ្លាំងក្លាប្រឆាំងការជិះជាន់ និងការមើលងាយរបស់
បារាំង។ ក្រៅពីនេះស្ត្រីក៏ជាអ្នកការពារប្រពៃណីដ៏
ល្អរបស់ខ្មែរផងដែរ ដូចជាករណីនាងហេងក្នុង
រឿងគ្ងលីកំណែនជាដើម។ នាងហេងបានរក្សាភក្តី

www.elibraryofcambodia.org

ភាពរបស់ខ្លួនឱ្យនៅស្អាតបរិសុទ្ធទុកជូនចំពោះ
លឹមជាគូដណ្តឹងដោយមិនខ្លាចការគំរាមកំហែង
របស់មេឃុំជាន់ឡើយ។

លើសពីនេះទៅទៀតភាពរីកចម្រើនរបស់
សង្គមតែងកើតឡើងចូលរួមកសាងរបស់ស្ត្រីតាម
រយៈសកម្មភាពផ្សេងៗ ដូចជាធ្វើជាអ្នកដឹកនាំ
គ្រួសារឱ្យមានជីវភាពធូរធារ និងមានកិត្តិយសខ្ពង់
ខ្ពស់។ ដូចនៅក្នុងរឿងមាយើង នាងគ្រប់លក្ខណ៍
ប្រពន្ធទ័ពរបស់មាណពបានណែនាំឱ្យមាណពជា
ប្តីឱ្យមានការចេះដឹង ចេះរកស៊ីជួញដូរ និងបាន
បង្ហាញប្តីរហូតក្លាយជាមន្ត្រីទៀតផង។ បន្ថែមពីលើ
នេះស្ត្រីក៏ជាគ្រូបង្រៀន ជាអ្នកកសាងវប្បធម៌ជាតិ
យ៉ាងល្អ្ីល្អ្ាញដូចជាព្រះនាងឥន្ទ្រទេវី។ ព្រះនាង
ជាគ្រូ ជាកវីម្នាក់ និងជាសាកលវិទ្យាធិការិនីដ៏ឆ្នើម
នៅសម័យអង្គរ ដែលបានបញ្ចេញអស់កម្លាំង
កាយចិត្ត ដើម្បីកសាងប្រទេសឱ្យល្អ្ីល្អ្ាញនៅ

www.elibraryofcambodia.org

សម័យនោះ។ ស្ត្រីក៏ជាអ្នកដឹកនាំអភិវឌ្ឍមូលដ្ឋានផងដែរមានជាអាទិ៍អ្នកស្រីបូរ។ ក្រោមការដឹកនាំរបស់អ្នកស្រីបូរ ភូមិខ្សាច់ពោយ ត្រូវបានកែប្រែមុខមាត់ និងមានការអភិវឌ្ឍគួរជាទីមោទន: គឺប្រជាជនពីដើមមិនចេះអក្សរ បានចេះដឹងយល់សព្វបែបយ៉ាង ផ្លូវថ្នល់ពីដើមក្រហេងក្រហូងឥឡូវប្រែជាស្អាត។ ស្ត្រីក៏ជាពាណិជ្ជករដ៏ស្វាហាប់ផងដែរ។ អ្នកមីង អ៊ី-ណា អ្នកមីងជាពាណិជ្ជករមួយរូបខិតខំរកស៊ីចិញ្ចឹមគ្រួសារដោយមិនផ្តេកផ្តួលលើប្តីឡើយ។ គាត់បានជួញដូរសព្វបែបយ៉ាងតាំងពីរបស់តូចតាចឡើងទៅរហូតជីវភាពគ្រួសារបានសមរម្យ ហើយកូនៗរបស់គាត់សុទ្ធតែបានរៀនចេះដឹងគ្រប់គ្នា។

សរុបមកភាពគង់វង្ស និងភាពរីកចម្រើនរបស់សង្គមពិតជាកើតក្រោមការបញ្ចេញអស់កម្លាំង

www.elibraryofcambodia.org

ប្រាជ្ញាស្មារតីក្នុងការការពារសង្គមជាតិនៅគ្រប់
កាល:ទេស:។

តាមការបកស្រាយខាងលើយើញថា ពំនោល
របស់ប្រធានពិតជាមានខ្លឹមសារល្អសម្រាប់អប់រំ
មនុស្សទាំងឡាយឱ្យយើញពីគុណសម្បត្តិរបស់
ស្ត្រី ហើយត្រូវជៀសវាងការប្រើអំពើហិង្សាទៅលើ
ស្ត្រី ព្រោះក្នុងសង្គមខ្មែរស្ត្រីជាអ្នកមានគុណ និង
ចាំបាច់មិនអាចខ្វះបានក្នុងការធ្វើឱ្យសង្គមស្ថិត
ស្ថេរ និងរីកចម្រើន។ ក្នុងនាមយើងជាពលរដ្ឋខ្មែរ
យើងត្រូវនាំគ្នាលើកតម្កើងតម្លៃរបស់ស្ត្រីទាំងអស់
គ្នា។

www.elibraryofcambodia.org

សុភាសិតខ្មែរចែងថា "សម្តីជាឯក លេខជាទោ អក្សរជាត្រី"។ ចូរពន្យល់។

សេចក្តីអធិប្បាយ

ចំណេះវិជ្ជាមានតម្លៃណាស់។ ការយល់ពីតម្លៃនៃចំណេះវិជ្ជា ជាហេតុនាំឱ្យមនុស្សនាំគ្នាពាក់ពព្ងនខំរកកន្លែងសិក្សារៀនសូត្រ ប៉ុន្តែគេម្នាក់ៗពុំអាចចេះសព្វមុខវិជ្ជានោះទេ អ្នកខ្លះពូកែខាងអក្សរសាស្ត្រ ខ្លះពូកែខាងវិទ្យាសាស្ត្របច្ចេកទេស ខ្លះទៀតពូកែខាងនយោបាយ។ ចំណុចទាំងបីនេះត្រូវគេចាត់ថ្នាក់ខុសគ្នាជាលំដាប់លំដោយ សមដូចសុភាសិតខ្មែរចែងថា "សម្តីជាឯក លេខជាទោ អក្សរជាត្រី"។

www.elibraryofcambodia.org

តើសុភាសិតនេះមានអត្ថន័យយ៉ាងដូចម្តេចខ្លះ?

សម្តីបានដល់ការនិយាយស្តី ការប្រើភាសារ ស័ព្ទ ដូចជាការយោសនាដែលសព្វថ្ងៃគេនិយមនិយាយថាធ្វើនយោបាយ។ អ្នកធ្វើនយោបាយត្រូវចេះវិជ្ជាខាងនយោបាយ។ វិជ្ជាផ្នែកនេះជាវិជ្ជាចម្បងដឹកនាំគេទាំងឡាយទៅរកអ្វីដែលហៅថាសេចក្តីសុខ និងការរីកចម្រើន។ អ្នកនយោ-បាយជាមនុស្សមានល្បិចមានកលឧបាយល្អ ដឹកនាំប្រទេសមិនឱ្យធ្លាក់រណ្តៅដោយគេចេះសម្លឹងឃើញអនាគតវែងឆ្ងាយ គឺមិនមើលឃើញតែចុងច្រមុះឡើយ។ នរណាឈ្លាសវៃជាងសុភាទន្សាយក្នុងរឿងព្រេងខ្មែរ។ សុភាទន្សាយអាចចាត់ទុកជាអ្នកនយោបាយជើងឆើតមួយរូប។ គេឃើញថាបើទន្សាយជាប់ក្ងុនខ្លួនឯង ដូចជាធ្លាក់

www.elibraryofcambodia.org

អណ្តូង ជាប់គូថនឹងគល់ត្រាច ក្រពើចង់ស៊ីជា
ដើម សុភាទន្សាយតែងបានប្រើសម្តីជាកលដោះ
ខ្លួនឱ្យរួចមួយគ្រាសិន។ បើគេពឹងពាក់វិញ សុភា
ទន្សាយតែងឆ្លៀតរកចំណេញ បើជារឿងស្លាប់
រស់ធំដុំវិញ សុភាទន្សាយបានប្រើនយោបាយ
ខ្ពស់ បោកប្រាស់តែម្តង។ ដូចករណី សុភា
ទន្សាយបានយកស្លឹកឈើដែលដង្កូវស៊ីមកអាន
ឱ្យហ្វូងចចកកំពុងបាចត្រីកំពិសស្លាប់ ធ្វើឱ្យសត្វ
ទាំងនោះភ័យចលាចលគ្រប់ៗគ្នា។ ទន្សាយជា
អ្នកនយោបាយរកផលខ្លួនផង និងសម្រាប់អ្នក
ដទៃផង។ ក្នុងរឿងធនញ្ជ័យ ធនញ្ជ័យបានក្លាយ
ជាអ្នកមានទ្រព្យ ហើយអាចជួយជាតិឱ្យចេញ
ផុតពីការចង់លេបត្រាប់ពីសំណាក់ប្រទេសចិន
ដោយសារតែធនញ្ជ័យចេះប្រើសម្តីបោកប្រាស់
យ៉ាងសមហេតុផល។ តាជូជកក្នុងរឿងព្រះ

www.elibraryofcambodia.org

ដ្ឋសន្ត្រគាត់បានរួចផុតពីការចង់ប្រហាររបស់ជាតិបុត្រដោយសារតែថ្ម៉ូមាត់របស់គាត់។ ដូចនេះការចេះប្រើសម្ភីថ្ម៉ូ មាត់ទោះប៉ីដើម្បីផលប្រយោជន៍រួមក្តី ឯកជនក្តី គឺជាចំណេះឯកពោលគឺមានតម្លៃជាចម្បង។

ចំពោះបញ្ហាលេខជាទោ គឺបានដល់ចំណេះរាប់គុណគូរទិញដូរវាល់ថ្ងៃជាលេខ ប៉ុន្តែបើជ្រៅជាងនេះគឺចំណេះស្យង់ និងតិចនិច។ ចំណេះនេះជាវិជ្ជាអនុវត្តត្រិះរិះរកសម្ភារៈឱ្យមនុស្សប្រើប្រាស់ធ្វើគ្រឿងម៉ាស៊ីននានាជំនួសមនុស្ស ប៉ុន្តែចំណេះខាងលេខ ខ្មែរយើងមានពាក្យចំអកថា "ចេះពេករបេះក្បាច់" បានសេចក្តីថាចំណេះខាងស្យង់ក៏អាចឱ្យកើតជាទោសបានដែរ បើប្រើមិនត្រឹមត្រូវ ដូចជាវិនាសកម្មបណ្តាលពីស្យង់នេះជាដើម។ ដូចនេះចំណេះខាងលេខអាចជាគុណ

www.elibraryofcambodia.org

ដល់មនុស្ស ហើយក៏អាចជាទោសផងដែរពោល គឺជាអាវុធមុខពីរ។ ភមានតម្លៃ ប៉ុន្តែភអាចទាញមនុស្សទៅរកនរកបានដូចគ្នា។ ជាក់ស្តែងដូចជាថ្នាំពេទ្យផ្តល់គុណសម្បត្តិដល់មនុស្ស ជួយការពារ និងអាចព្យាបាលជំងឺផ្សេងៗឱ្យជាសះស្បើយ ប៉ុន្តែថ្នាំពេទ្យក៏ជាអ្នកសម្លាប់ជីវិតមនុស្សយ៉ាងសាហាវផងដែរ។ ដោយហេតុនេះ ទើបគេចាត់ទុកចំណេះខាងលេខមានប្រយោជន៍ត្រឹមលេខពីរ។

ចំណែកអក្សរជាត្រី គឺសំដៅទៅលើចំណេះខាងអក្សរសាស្ត្រ វេយ្យាករណ៍ អក្សរសិល្ប៍ ប្រវត្តិសាស្ត្រជាដើម ទាំងអស់នេះជាចំណេះខាងអក្សរ។ គេធ្លាប់និយាយថា ជាចំណេះខាងប្រាជ្ញា ការបិនប្រសប់ បណ្តុះបណ្តាលការត្រិះរិះពិចារណា រកសុចរិត យុត្តិធម៌ រកល្អអាក្រក់ជា

www.elibraryofcambodia.org

ដើម។ តើចំណេះខាងអក្សរសាស្ត្របម្រើសង្គម ឬទេ? ជាចម្លើយ គឺវាបានបម្រើសង្គមដូច ចំណេះខាងវិទ្យាសាស្ត្រតិចនិច និងនយោបាយ ដែរ ប៉ុន្តែដោយហេតុថាចំណេះនេះជាចំណេះ ខាងថា ពុំមែនជាចំណេះខាងធ្វើ ម្ល៉ះហើយ លោកចាត់ថ្នាក់ជាត្រី គឺចំណេះមានតម្លៃដូចគ្នា បន្ទាប់ពីចំណេះនយោបាយ និងលេខ។

រួមសេចក្ដីមក ចំណេះនយោបាយ ស្សង់តិច និច និងអក្សរសាស្ត្រ គឺចំណេះទាំងបីនេះត្រូវ ពឹងពាក់គ្នាទៅវិញទៅមក។ អ្នកនយោបាយដឹក នាំអ្នកស្សង់បង្កើតសម្ភារ: ហើយអ្នកអក្សរ សាស្ត្រជាអ្នកកសាងវប្ផធម៌។ ដូចនេះចេះសម្ដី ចេះលេខ ចេះអក្សរ អាចទៅបម្រើសង្គមជាតិ ឱ្យបានជួបសេចក្ដីសុខ សេចក្ដីចម្រើនបានយ៉ាង ល្អបំផុត។

www.elibraryofcambodia.org

តាមការបកស្រាយរួចមកហើយឃើញថា សុភាសិតខាងលើពិតជាមានតម្លៃជ្រាលជ្រៅ ព្រោះវាជាមេរៀន ជាត្រីវិស័យដឹកនាំមនុស្សឱ្យ ឆ្ពោះទៅរកត្រើយសុភមង្គលតាមបំណងប្រាថ្នា រៀងៗខ្លួន។ ដូចនេះយើងត្រូវខិតខំរៀនសូត្រ គ្រប់មុខវិជ្ជាដើម្បីឈានទៅសម្រេចបំណង ប្រាថ្នាដែលខ្លួនចង់បានក្នុងពេលបច្ចុប្បន្ន និង ទៅអនាគត។

www.elibraryofcambodia.org

ប្រធានគំរូទី១៣

បញ្ហាអើសគូស្រករជាបញ្ហាសំខាន់ក្នុងជីវិតរបស់មនុស្សគ្រប់រូប។ ចូរពន្យល់។

សេចក្តីអធិប្បាយ

ក្នុងការរស់នៅមិនថាមនុស្ស ឬសត្វទេ កាលណាធំពេញវ័យគេត្រូវតែជ្រើសរើសដៃគូ ឬគូស្រករ ដើម្បីបន្តពូជពង្សវង្សត្រកូល។ បញ្ហាអើសគូស្រករជាបញ្ហាចាំបាច់ ហើយស្មុគស្មាញ ព្រោះថាបើជ្រើសរើសត្រូវវានឹងកើតមានសុភមង្គល តែបើជ្រើសរើសខុស វានឹងនាំឱ្យគេគ្មានសុភ-មង្គល។ ហេតុនេះហើយបញ្ហាអើសគូស្រករជាបញ្ហាសំខាន់ក្នុងជីវិតរបស់មនុស្សគ្រប់រូប។

តើបញ្ហាអើសគូស្រករមានសារៈសំខាន់ដូចម្តេចខ្លះចំពោះមនុស្សគ្រប់រូប?

www.elibraryofcambodia.org

ដើម្បីសម្រួលដល់ការបកស្រាយប្រធាន ជាដំបូងយើងគប្បីយល់ន័យឃ្លា *រើសគូស្រករ* និងពាក្យ*សំខាន់* ជាមុនសិន។ រើសគូស្រករសំដៅដល់ការរើសបុរស ឬនារីដែលគេស្រឡាញ់មកធ្វើជាប្តី ឬប្រពន្ធ។ ឯពាក្យ*សំខាន់* មានន័យថាមានសារប្រយោជន៍ ឬចាំបាច់មិនអាចខ្វះបាន។

មតិប្រធានបានសេចក្តីថា បញ្ហារើសបុរសនារីដែលគេស្រឡាញ់ពេញចិត្តមកធ្វើជាប្តី ឬប្រពន្ធ គឺជាបញ្ហាដែលមានសារប្រយោជន៍ក្នុងជីវិតមនុស្សគ្រប់រូប។

ជាការពិតហើយបញ្ហារើសគូស្រករជាបញ្ហាសំខាន់ចំពោះមនុស្សគ្រប់រូប ព្រោះមនុស្សប្រុសស្រីកាលណាធំពេញវ័យត្រូវតែរើសដៃគូមួយដើម្បីរៀបការបន្តពូជពង្សវង្សត្រកូល ដោយសារតែមនុស្សគឺជាកោសិការបស់សង្គម។ មនុស្ស

www.elibraryofcambodia.org

ដែលពេញវ័យហើយចេះតែគេចមិនព្រមរៀប
ការ ឬដើរស្វែងរកគូ គេអាចនិយាយ[illegible]ធម្ម
ជាតិ។ ម្យ៉ាងទៀត ការរើសគូស្រក[illegible]ការ:
សំខាន់ខុសពីការធ្វើស្រែចំការ។ ការធ្វើស្រែចំ
ការអាចខុសមួយឆ្នាំត្រូវមួយឆ្នាំ ប៉ុន្តែការរើសគូ
ស្រករវិញបើរើសខុសគឺខុសមួយជីវិត។ ដូចនេះ
ដើម្បីរើសគូស្រករឱ្យបានត្រឹមត្រូវ គេត្រូវតែពិនិ
ត្យមើលឱ្យគ្រប់ជ្រុងជ្រោយ ពិសេសត្រូវពិនិត្ស
មើលផៅ សន្ដាន ព្រោះថាបើគេរើសយកក្រូច
គេនឹងបានផ្លែក្រូច បើរើសយកស្វាយគេនឹងបាន
ផ្លែស្វាយ ហើយក៏ដូចជាសុភាសិតខ្មែរចែងថា
"ធ្វើស្រែឱ្យមើលស្មៅ ទុកដាក់កូនចៅឱ្យមើ
ផៅសន្ដាន"។ ការរើសគូស្ករនេះច្រើនផ្អែ
តាមការយល់ឃើញ និងការឱ្យតម្លៃរបស់មនុ
ម្នាក់ៗ។ បញ្ហានេះបើគេក្រឡេកមើលតាមរយ:

www.elibraryofcambodia.org

អក្សរសិល្ប៍ គេនឹងឃើញយ៉ាងច្បាស់អំពីរបៀប
និងការឱ្យតម្លៃក្នុងការរើសគូស្រករ។ ក្នុងរឿងទុំ
ទាវ ការរើសគូស្រករ គឺផ្អែកទៅតាមការឱ្យតម្លៃ
លើទ្រព្យសម្បត្តិ និងបុណ្យសក្តិជាធំ។ ជាក់ស្តែ
ង ម្តាយទាវបានលើកទាវ និងផ្តាច់នាងទាវពីទុំ
ក៏ព្រោះទុំមានទ្រព្យតិច និងបុណ្យសក្តិតូចតាច
ផ្ទុយពីម៉ឺនងួនកូនអរជូនដែលមានទាំងទ្រព្យស
ម្បត្តិ និងអំណាច។ រឿងផ្ការស្រពោន ការរើសគូ
ស្រករបានផ្អែកតាមការឱ្យតម្លៃរបស់ទ្រព្យជាធំ
ដែរ។ យាយនួនបានផ្តាច់នាងវិធាវីដែលជាគូដ
ណ្តឹងតាំងពីតូចរបស់ប៊ុនធឿនមករៀបការ
ជាមួយនឹងណៃសិតជាកូនអ្នកមានទ្រព្យស្តុកស្ត
ម្ភ ក្រោយពីគ្រួសារប៊ុនធឿនធ្លាក់ខ្លួនក្រ។
ចំណែកក្នុងរឿង កូលាបប៉ែលិនវិញ ការរើសគូ
ស្រករបានផ្អែកលើការស្រឡាញ់ពេញចិត្តលើ

www.elibraryofcambodia.org

សមត្ថភាព និងការភ្ជាក់រលឹកជួយគ្នា។ នាងឃុន
នារីមានរូបស្អាត មានទ្រព្យច្រើនហើយឆ្នើងឆ្មៃ
ចំណែកវៀចិត្តមានរូបរាងស្គមស្គាំង ក្រីក្រ តែ
មានចំណេះដឹង និងមានសមត្ថភាពការងារខ្ពស់។ គេទាំងពីរអាចយកគ្នាជាប្តីប្រពន្ធបាន
ដោយនាងឃុននារីបានកែប្រែខ្លួនមិនប្រកាន់
ណ្ណៈ ឯវៀចិត្រក៏បានខិតខំធ្វើការងារដោយយក
ចិត្តទុកដាក់។ រឿងរាមកេរ្តិ៍ការរើសគូស្រករផ្អែក
លើការឱ្យតម្លៃលើសមត្ថភាពកូនប្រុសជាធំ។
ព្រះបាទជនកបានធ្វើពិធីជ្រើសរើសសុណិសា
ដោយមិនបានគិតដល់ ណ្ណៈ ឬទ្រព្យសម្ប
ត្តិឡើយ គឺឱ្យតែមានសមត្ថភាពលើកធ្នូជ័យរួច
នឹងក្លាយជាបុត្រសុណិសារបស់ទ្រង់ហើយ។
ព្រះរាមមានសមត្ថភាពខ្ពស់ជាងគេ អាចលើកធ្នូ

www.elibraryofcambodia.org

រួចទើបបាននាងសិតាជាកញ្ញាល្អផ្ការ៉ាប់គេលើត្រៃ
ភពមកធ្វើជាមហេសី។

សរុបមក ការរើសគូស្រករពិតជាបញ្ហា
សំខាន់ក្នុងជីវិតមនុស្សគ្រប់រូប ព្រោះបញ្ហានេះ
ជាកិច្ចមួយក្នុងការស្វែងរកសេចក្តីសុខឱ្យខ្លួនឯង
គ្រួសារ និងសង្គមជាតិ ដែលទាមទារជាចាំបាច់
នូវការពិនិត្យឱ្យបានល្អិតល្អន់ទៅតាមចិត្តគំនិត
និងឧត្តមគតិ។

ឆ្លងតាមការបកស្រាយរួចមកហើយឃើញ
ថា ការរើសគូស្រករពិតជាមានសារៈសំខាន់ ពី
ព្រោះបញ្ហានេះជាបច្ច័យដំបូងដែលនាំមនុស្សឱ្យ
ឈានចូលសង្គមពិតប្រាកដបានជោគជ័យ ឬ
ទទួលបរាជ័យក្នុងជីវិត។ បើការរើសគូស្រកនេះ
ប្រកបដោយភាពល្អិតល្អន់គ្រប់ជ្រុងជ្រោយ
ពេលនោះសុភមង្គលពិតជាកើតមានជាក់ជាមិន

www.elibraryofcambodia.org

ខានសម្រាប់រូបគេ ក្រុមគ្រួសារ និងសង្គមជាតិ
ផងដែរ។ ដូច្នេះយើងជាសិស្សានុសិស្សត្រូវតែ
គិតពីបញ្ហានេះឱ្យបានច្បាស់មុននឹងសម្រេចចិត្ត
ជ្រើសរើសនរណាម្នាក់មកធ្វើជាគូអនាគត។

www.elibraryofcambodia.org

គេឱ្យតម្លៃថា "ខ្មែរជាជាតិសាសន៍ពោរពេញដោយគំនិតជាតិនិយម និងគំនិតមាតុភូមិនិយម"។ ចូរស្រាយបំភ្លឺ។

សេចក្តីអធិប្បាយ

ប្រជាជននៃប្រទេសនីមួយៗតែងតែគោរពស្រឡាញ់ប្រទេសជាតិរបស់ខ្លួនរៀងៗខ្លួន ដោយសារប្រទេសជាតិជាអ្នកផ្តល់កំណើត និងផ្តល់សេចក្តីសុខឱ្យខ្លួន។ ប្រជាជនខ្មែរក៏តែងតែបណ្តុះទឹកចិត្តស្រឡាញ់ប្រទេសជាតិរបស់ខ្លួនគ្រប់ៗគ្នា។ ហេតុនេះហើយទើបគេថា "ខ្មែរជាជាតិសាសន៍ពោរពេញដោយគំនិតជាតិនិយម និងគំនិតមាតុភូមិនិយម"។

www.elibraryofcambodia.org

តើគំនិតជាតិ និងមាតុភូមិនិយមរបស់ខ្មែរ
មានដូចម្តេចខ្លះ?

ការស្រាយបង្ហាញបញ្ជាក់ប្រធានគ្រាយស់
ពាក្យជាតិសាសន៍ គំនិតជាតិនិយម និងមាតុ
ភូមិនិយមជាមុនសិន។ ពាក្យជាតិសាសន៍ គឺជា
អ្នកមានពូជអំបូរ ឬញាតិសណ្ដានតែមួយ។ ឯ
ពាក្យគំនិតជាតិនិយម គឺគំនិតជាប់ជំពាក់ ចូល
ចិត្តទៅនឹងកេរដំណែលរបស់ខ្លួនដែលមានពី
កំណើត។ រីឯពាក្យមាតុភូមិនិយម គឺសំដៅលើ
ការជាប់ជំពាក់លើទឹកដីកំណើតរបស់ខ្លួន។

ទស្សនៈប្រធានកំណត់ថា ខ្មែរទាំងអស់គ្នា
ជាអ្នកមានចិត្តជាប់ជំពាក់មិនដាច់ទៅនឹងជាតិ
របស់ខ្លួន រួមទាំងអ្វីៗដែលមានកន្លងមកជាកេរ
ដំណែលរបស់ខ្លួន។

www.elibraryofcambodia.org

តាមការសង្កេតឃើញថា ខ្មែរជាអ្នកមានគំនិតជាតិនិយមដោយសារជាអ្នកស្រឡាញ់ពេញចិត្តជាតិខ្លួន ស្រឡាញ់ពេញចិត្តប្រវត្តិខ្លួន ស្រឡាញ់ពេញចិត្តស្នាដៃដែលខ្លួនបានបង្កើត ស្រឡាញ់ពូជសាសន៍ និងទឹកដីរបស់ខ្លួន។ ទន្ទឹមនឹងការស្រឡាញ់ពេញចិត្តនេះ បានជំរុញឱ្យមានការកសាងប្រវត្តិសាស្ត្រ មានលក្ខណៈជាក់លាក់ និងល្អប្រសើរ ខិតខំកសាងជាតិសាសន៍ ឬពូជសាសន៍ កសាងស្នាដៃលទ្ធកម្ម និងវប្បធម៌អរិយធម៌ មានភាសាអក្សរសិល្ប៍ជាដើម។ គេចេះជួយជំរុញការកសាងទឹកដី និងការគ្រប់គ្រងឱ្យមានសាមគ្គីភាព សមភាព មានការប្រវាស់ដៃគ្នា ចេះជួយយកអាសាគ្នា។ ក្រៅពីនេះ ខ្មែរតែងតែថែរក្សា និងការពារសញ្ញាតនាស្រឡាញ់ដ៏ជ្រាលជ្រៅនេះ បានប្រែក្លាយជាការ

www.elibraryofcambodia.org

កសាងថែរក្សា និងការពារយ៉ាងសកម្មបំផុតដូច
ជា វប្បធម៌ អរិយធម៌ មានការកសាងថ្មីប្រឌិត
ឱ្យមានលក្ខណៈវិសេសវិសាលសុក្រឹតពិសេសពី
ជាតិដទៃដែលកំណត់ថាជាអត្តសញ្ញាណខ្លួន
ដូចជាភាសា អក្សរសិល្ប៍ សិល្ប: និងប្រពៃណី
ដ៏សម្បូរបែប។ ស្ថាបត្យកម្មទំនើបៗ និងមាន
លក្ខណៈល្អវិសេសវិសាល ដូចជាប្រាសាទ
បុរាណ និងមានរចនាសម្ព័ន្ធគ្រប់គ្រងសមស្រប
តាមទស្សនៈវិស័យ និងលក្ខណៈពិសេសរបស់
ជាតិខ្លួន។ ប្រជាជនខ្មែរបានរក្សាការពារសម្បត្តិ
ជាតិទាំងលទ្ធកម្ម និងធម្មជាតិឱ្យគង់វង្សបន្ត
មរតករហូតមកដល់បច្ចុប្បន្ន ពិសេសហ៊ានបូជា
ជីវិតដើម្បីបុព្វហេតុជាតិ។ គំនិតជាតិនិយមនេះ
ផ្តោតលើការកសាង និងការពារមិនឱ្យបាត់បង់
នូវអ្វីដែលប្រទេសជាតិយើងមាន។ ចំណែកឯ

www.elibraryofcambodia.org

គំនិតមាតុភូមិនិយមរបស់ខ្មែរវិញ គឺការភ្ជាប់ឬ
ជំពាក់សម្ពន្ធនាជ្រាលជ្រៅទៅនឹងជីវភាពរស់
នៅរបស់មនុស្សដូចជាទឹកដីកំណើតមាន
អំណោយផល មានអាកាសធាតុល្អ មានធម្ម
ជាតិស្រស់បំព្រង មានព្រៃភ្នំ សត្វ មច្ឆា ជាតិ
ទន្លេ ស្ទឹង សមុទ្រ ឆ្នេរសមុទ្រ ដោយស្រឡាញ់
នឹករឭកចំពោះធម្មជាតិ និងមរតកដូនតា ហើយ
ថែរក្សាឱ្យបានស្ថិតស្ថេរ។ តាមរយៈប្រវត្តិសាស្ត្រ
ជាតិបង្ហាញថា ខ្មែរបានបង្កើតឱ្យមានជាតិ ទឹកដី
វប្បធម៌ អរិយធម៌ដ៏ល្អផ្ទូរផង់ជារបស់ខ្លួន ដែល
កើតមានតាំងពីយូរលង់មកហើយ ពោលគឺតាម
រយៈព្រះនាងលីវយី ហ៊ុនទៀន និងមហាក្សត្រ
ខ្មែរគ្រប់ៗជំនាន់ ពិសេសបានបូជាអាយុជីវិត
ការពារអធិបតេយ្យភាព និងបូរណភាពទឹកដី
បានទៀតផង។

www.elibraryofcambodia.org

សរុបសេចក្ដីមក គំនិតជាតិនិយមស្ថិតលើការកសាងឱ្យមានការអភិវឌ្ឍខ្ពង់ខ្ពស់។ ឯគំនិតមាតុភូមិនិយមវិញ គឺការភ្ជាប់សញ្ជាតនានឹករលឹក និងថែរក្សាមាតុភូមិឱ្យបានគង់វង្ស។

ដូច្នេះ ទស្សនៈប្រចានមានអត្ថន័យជ្រាលជ្រៅ ដោយឱ្យតម្លៃខ្ពស់ទៅលើប្រជាជនខ្មែរ និងផ្ដល់ការអប់រំល្អសម្រាប់ខ្មែរគ្រប់ៗរូប បំពាក់បំប៉ននូវមនសិការស្នេហាជាតិមាតុភូមិពិត និងការពារឱ្យបានគង់វង្ស។ ដូចនេះយើងជាពលរដ្ឋខ្មែរម្នាក់ៗត្រូវចូលរួមកសាង និងការពារជាតិមាតុភូមិឱ្យរីកចម្រើន និងគង់វង្សជារៀងរហូត។

www.elibraryofcambodia.org

ប្រធានគំរូទី១៤

តើធនញ្ជ័យ ស៊ីម និងចៅចិត្រ មានលក្ខណសម្បត្តិ វិសេសវិសាលរួមគ្នាអ្វីខ្លះ ដែលអាចឱ្យយើងត្រូវ យកមកប្រតិបត្តិនោះ? ចូរបង្ហាញ។

សេចក្តីអធិប្បាយ

អក្សរសិល្ប៍ដែលយើងបានសិក្សារាល់ថ្ងៃ បានបង្ហាញសកម្មភាពតួអង្គជាច្រើនមានលក្ខណៈល្អអាក្រក់ទៅតាមប្រភេទនៃតួអង្គ និងដំណើររឿងពិសេសអក្សរសិល្ប៍ក្នុងកម្មវិធីសិក្សាសព្វថ្ងៃនេះ។ ហេតុនេះធនញ្ជ័យ ស៊ីម និងចៅចិត្រមានលក្ខណៈពិសេសរួមគ្នាច្រើនណាស់ ដែលអាចឱ្យយើងយកមកប្រតិបត្តិតាមបាន។

តើអ្នកទាំងបីមានលក្ខណៈល្អវិសេសវិសាលរួមគ្នា ដែលគួរឱ្យយើងប្រតិបត្តិតាមយ៉ាងណាខ្លះ?

www.elibraryofcambodia.org

មុននឹងរកឃើញលក្ខណៈរួមគ្នារបស់អ្នកទាំងបីនាក់នោះបាន យើងគួរយល់ន័យពាក្យ"លក្ខណសម្បត្តិវិសេសវិសាល" និងពាក្យ"ប្រតិបត្តិ"សិន។ ពាក្យ "លក្ខណៈសម្បត្តិវិសេសវិសាល" គឺមានន័យថាការគ្រប់ព្រមដោយលក្ខណៈល្អប្រសើរ។ រីឯពាក្យ "ប្រតិបត្តិ" មានន័យថាធ្វើតាម, គោរពតាម, ប្រតិបត្តិតាម ដើម្បីសេចក្តីសុខ។ អត្ថន័យប្រធាននេះចង់បញ្ជាក់ប្រាប់យើងថា គ្រូអង្គទាំងបីលក្ខណៈល្អដូចគ្នាសម្រាប់ឱ្យយើងយកមកអនុវត្តតាម។

តាមការសិក្សាស្នាដៃអក្សរសិល្ប៍ទាំងនេះ បានបញ្ជាក់ពីសកម្មភាពគ្រូអង្គទាំងបី គឺអ្នកទាំងបីមានលក្ខណៈសម្បត្តិដ៏ល្អវិសេសវិសាលរួមគ្នាច្រើនជំពូកណាស់។ គ្រូអង្គធនញ្ជ័យ សុីម ចៅចិត្ត ដែលយើងបានស្គាល់រួចមកហើយតាមដំណើររឿង អ្នកទាំងនោះមានចំណេះដឹងរួមទាំងសមត្ថភាពគ្រប់គ្រាន់ក្នុងការដោះស្រាយដំណើរជីវិត

www.elibraryofcambodia.org

របស់គេម្នាក់ៗ ឈានដល់សុភមង្គល ដែលជាបំណងនិងសេចក្ដីត្រូវការរបស់មនុស្សទូទៅ។ សកម្មភាពរបស់ធនញ្ជ័យ ក៏ដូចស៊ីម និងចៅចិត្ត ដែរ ពួកគេមានចំណេះដឹងនិងប្រាជ្ញាតទល់នឹងឧបសគ្គដែលខ្លួនជួបប្រទះ។ រាល់ចំណេះដឹងរបស់គេនោះ គឺជាចំណេះដឹងមួយដែលមានក្រឹត្យក្រមច្បាស់លាស់។ ចំពោះសមត្ថភាពគេទាំងបីវិញ បើពិនិត្យទៅតាមរឿងដែលបានសិក្សាវិញនោះ ក៏មិនខុសគ្នាដែរ។ រាល់បញ្ហាដែលកើតមានចំពោះគេ គឺគេអាចដោះស្រាយបាន ទោះបីមានការប៉ុនប៉ងមិនល្អពីអ្នកដទៃក៏ដោយ។

ធនញ្ជ័យ ស៊ីម ចៅចិត្តមិនរើសអើងការងារ និងមានស្មារតីទទួលខុសត្រូវខ្ពស់ គេធ្វើការងារអ្វីមួយដោយមិនរើសមិនប្រកាន់ឡើយ ពិសេសគឺគេមានស្មារតីទទួលខុសត្រូវខ្ពស់ ស្គាល់តម្លៃពេលវេលាច្បាស់ក្នុងការធ្វើការ ហើយការប្រព្រឹត្តរបស់

www.elibraryofcambodia.org

គេសុទ្ធតែបានសម្រេចផល ជាតួយ៉ាងសកម្មភាព
របស់ធនញ្ជ័យ ដែលអាចធ្វើឱ្យសេដ្ឋី នាម៉ុន ស្ដេច
ខ្មែរ ស្ដេចចិនខ្លាចចំពោះប្រាជ្ញានិងកោតសរ
ស្ងៃងរាល់សកម្មភាពរបស់គេ។ ចំពោះស៊ីមវិញ គេ
បានធ្វើឱ្យថៅកែ និងពួកកម្មករស្គាល់គេច្បាស់ថា
ជាអ្នកមានលក្ខណៈត្រឹមត្រូវល្អ គោរពម៉ោងពេល
ដឹងតួនាទីជាកម្មករ ហើយពួកកម្មករតែងធ្វើតាម
ស៊ីម រៀនសូត្រពីស៊ីមរហូតបានមើលឃើញពីការ
គាបសង្កត់ជិះជាន់ក្នុងសង្គមពីសំណាក់ពួកថៅកែ
ឈ្មោកធំ។ ចំណែកថៅចិត្រវិញក៏មានលក្ខណៈ
សម្បត្តិល្អច្រើនណាស់ដែរ ដូចជាមានសមត្ថភាព
ការងារ មានស្មារតីទទួលខុសត្រូវខ្ពស់ និងមិនចេះ
រើសអើង។ ថៅចិត្រជាកម្មករមួយរូបដែលស្គាល់
ច្បាស់ពីតួនាទី និងហានៈរបស់ខ្លួន។ ការងារទាំង
អស់សុទ្ធតែលុះដោយដំបូន្មានរបស់ឪពុកគេដែល

www.elibraryofcambodia.org

មុននឹងស្លាប់បានផ្តាំដល់គេ។ គេបានចាត់ទុកជីវិត ជាការតស៊ូ។

ជារួម ធនញ្ជ័យ ស៊ីម ចៅចិត្ត បានបង្ហាញពីស្មារតីតស៊ូខ្ពស់ ហ៊ានលះបង់អ្វីៗដើម្បីសេចក្តីសុខផ្ទាល់ខ្លួន គ្រួសារ ពិសេសជាតិទាំងមូល។ រាល់ការងារមិនមែនជាការងាយស្រួលនោះទេ សុទ្ធតែត្រូវការការតស៊ូអំណត់ខន្តីទាំងអស់ ទើបសម្រេចនូវលទ្ធផលបាន មិនមែនចេះតែធ្វើៗ ហើយសម្រេចផលនោះទេ តែសម្រាប់អ្នកទាំងបីគេមានសមត្ថ-ភាពគ្រប់គ្រាន់ដើម្បីធ្វើការងារទាំងនោះ។

ឆ្លងតាមការស្រាយបំភ្លឺខាងលើយើញថាអ្នកទាំងបីមានលក្ខណៈល្អសម្រាប់យើងយកជាគម្រូតាម ព្រោះគេមានស្មារតីតស៊ូ ហើយហ៊ានលះបង់អ្វីៗទាំងអស់ដើម្បីគ្រួសារ និងប្រទេសជាតិ។ ហេតុនេះយើងទាំងអស់គ្នាគួរយកតម្រាប់តាមអ្នកទាំងបីដើម្បីអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន។

www.elibraryofcambodia.org

ប្រធានគំរូទី១៦

រឿងកុលាបប៉ែលិនជារឿងឧត្តមគតិ។ ចូរបង្ហាញ។

សេចក្តីអធិប្បាយ

រាល់ស្នាដៃអក្សរសិល្ប៍សុទ្ធតែបានបង្ក្រប់នូវអត្ថន័យយ៉ាងជ្រាលជ្រៅ។ ក្នុងនោះក៏មានរឿងកុលាបប៉ែលិនផងដែរ ដែលជាស្នាដៃនិពន្ធរបស់លោក ញ៉ុក ថែម។ ដោយសារតម្លៃនៃរឿងនេះ គេក៏បានបញ្ចូលរឿងនេះក្នុងកម្មវិធីសិក្សាផងដែរ។ តាមការវិភាគលើផ្នែករឿងទាំងមូលមានទស្សនៈខ្លះយល់ឃើញថា "រឿងកុលាបប៉ែលិនជារឿងឧត្តមគតិនិយម"។

តើលក្ខណៈត្រង់ណាខ្លះដែលបញ្ជាក់ថារឿងកុលាបប៉ែលិនជារឿងឧត្តមគតិនិយមនោះ?

ដើម្បីវិភាគឱ្យបានច្បាស់លាស់ថា រឿងកុលាបប៉ែលិនជារឿងឧត្តមគតិត្រង់ណានោះយើងគួរ

www.elibraryofcambodia.org

យល់ពាក្យ"ឧត្តមគតិ"សិន។ ពាក្យ "ឧត្តមគតិ" មានន័យថា គំនិតដ៏ប្រសើរខ្ពង់ខ្ពស់ឧត្តុងឧត្តម។

បើយោងទៅតាមការសិក្សា និងបានពន្យល់ពាក្យបញ្ជាក់រួចមកហើយឃើញថា រឿងកុលាបប៉ែលិនជារឿងមានគំនិតប្រសើរខ្ពង់ខ្ពស់បំផុត។ រឿងនេះបានអប់រំមនុស្សឱ្យមានចិត្តកតញ្ញូចំពោះមាតាបិតា។ គេអាចមើលឃើញត្រង់ថា ចៅចិត្តគោរពស្រឡាញ់តាចឹម ហើយរឿងនេះលោកបានអប់រំមនុស្សឱ្យមានការតស៊ូក្នុងឆាកជីវិត។ ជាក់ស្តែងចៅចិត្តខិតខំតស៊ូធ្វើការងាររហូតបានសម្រេច ពិសេសបានក្លាយខ្លួនជាកូនប្រសាថៅកែ ឫងនៅប៉ែលិន។ ចំពោះរឿងនេះទៀតសោតក៏បានអប់រំមន្ត្រីរាជការឱ្យចេះតស៊ូ និងក្លាហាន។ ដូចករណីលោកបាឡាត់ខ្ទះភាពក្លាហាន ពេលចោរប្លន់រត់ជ្រកក្រោមរថយន្ត ពិសេសបានអប់រំអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភឱ្យចេះបន្ទន់ខ្លួន

www.elibraryofcambodia.org

ហើយរាប់អានអ្នកក្រ។ លោកហ្លួងវ៉ាតសម្ផត្តិជា ថៅកែតូ្ឍង តែគាត់ទទួលស្គាល់តម្លៃកម្មករដូចជា ចៅចិត្រជាកូនប្រសា។ រឿងនេះក៏បានអប់រំនារីជា កូនអ្នកមានទ្រព្យសម្ផត្តិកុំឱ្យប្រកាន់ខ្លួនតម្កើងបួក ការជ្រុលពេក។ ករណីដូចនាងឃុននារី ដែលជា ចៅហ្វាយស្រីរបស់ចៅចិត្រ ប៉ុន្តែសុខចិត្តទទួល យកកម្មករជាគូអនាគត ដោយនាងយល់ពីតម្លៃ និងបុគ្គលិកលក្ខណៈល្អរបស់ចៅចិត្រ។ លក្ខណៈ ពិសេសមួយទៀតនោះគឺរឿងនេះបានអប់រំឱ្យ មនុស្សចេះសាមគ្គីគ្នា ដូចជាពួកកម្មករជីកតូ្ឍង ទាំងអស់រួមគ្នាវាយចោរជាដើម។

រួមសេចក្ដីមករឿងកុលាបប៉ែលិនពិតជារឿង មួយ ដែលមានលក្ខណៈឧត្តុងឧត្តមផ្ទែកឧត្តមគតិ ប្រាកដមែន។

តាមការបកស្រាយរួចមកហើយបានបង្ហាញ ឱ្យឃើញថាពំនោលខាងលើពិតជាល្អប្រសើរ

www.elibraryofcambodia.org

ព្រោះបានអប់រំឱ្យយើងយល់ពីតម្លៃនៃឧត្តមគតិ
ដែលអ្នកនិពន្ធបានបង្ក្រប់ក្នុងសាច់រឿង។ នៅគ្រប់
ស្នាដៃអក្សរសិល្ប៍សុទ្ធតែមានបំណងអប់រំមនុស្ស
និងសង្គមឱ្យបានល្អ និងមានភាពរីកចម្រើន។ដូច
នេះយើងជាកុលបុត្រកុលធីតា គោងតែខិតខំ
សិក្សាវិភាគស្នាដៃអក្សរសិល្ប៍ខ្មែរឱ្យបានស៊ីជម្រៅ
ដើម្បីទាញយកខ្លឹមសារ និងអត្ថន័យធ្វើជាបទ
ពិសោធក្នុងជីវិត ដើម្បីការរីកចម្រើនក្នុងគ្រួសារ
និងសង្គម។

www.elibraryofcambodia.org

ទស្សនៈខ្លះពោលថា "បើមានតែទ្រព្យសម្បត្តិមួយមុខ
មិនគ្រប់គ្រាន់ទេ លុះត្រាតែមានចំណេះប្រាជ្ញាទៀត
ទើបអាចគ្រប់គ្រាន់"។ ចូរពន្យល់ដោយលើក
ឧទាហរណ៍ពីក្នុងអក្សរសិល្ប៍មកបញ្ជាក់ផង។

សេចក្តីអធិប្បាយ

បនុស្សកើតមករស់ក្នុងសង្គមរមែងតែងតែចង់
បានកេរ្តិ៍ឈ្មោះល្អប្រសើរ និងមានធនធានសម្ប
រុងរឿង ដើម្បីលើកតម្កើងជីវភាពរស់នៅរបស់គេ។
អាស្រ័យដូចនេះហើយ ទើបមានទស្សនៈមួយ
ពោលថា "បើមានតែទ្រព្យសម្បត្តិមួយមុខមិនគ្រប់គ្រាន់
ទេ លុះត្រាតែមានចំណេះប្រាជ្ញាទៀតទើបអាចគ្រប់
គ្រាន់"។

តើទស្សនៈខាងលើមានអត្ថន័យយ៉ាងណាខ្លះ?
ហើយឆ្លុះបញ្ចាំងក្នុងអក្សរសិល្ប៍ខ្មែរយ៉ាងណាខ្លះ?

www.elibraryofcambodia.org

មុននឹងស្រាយបំភ្លឺរកអត្ថន័យនៃពំនោលខាងលើនេះថាមានន័យយ៉ាងណានោះ យើងគួរយល់ពាក្យមួយចំនួនជាមុនសិន។ ពាក្យ "ទ្រព្យសម្បត្តិ" សំដៅទៅលើធនធានសព្វសារពើ ជាតម្រូវការរបស់មនុស្ស។ រីឯពាក្យ "ចំណេះប្រាជ្ញា" មានន័យថា ចំណេះដឹងប្រកបដោយភាពឈ្លាសវៃ។ ចំពោះអត្ថន័យរបស់ប្រធានខាងលើបានសេចក្តីថា បើមានតែធនធានមួយមុខវាមិនគ្រប់គ្រាន់ទេ លុះត្រាតែមានចំណេះដឹងលើផ្នែកបច្ចេកទេស ឬវិជ្ជាជីវៈណាមួយទើបគ្រប់គ្រាន់។

យោងតាមការសិក្សាស្នាដៃរឿង និងការរស់នៅក្នុងសង្គម យើងសង្កេតឃើញថា គ្រប់រឿង និងរាល់សកម្មភាពរស់នៅរបស់មនុស្សក្នុងសង្គមបានបញ្ជាក់ច្បាស់ថា បើមានតែទ្រព្យសម្បត្តិពិតជាមិនគ្រប់គ្រាន់ឡើយ។ យ៉ាងណាមិញក្នុងរឿងឪពុកក្មេកវើសកូនប្រសា គាជាឪពុកក្មេកជាអ្នកមាន

www.elibraryofcambodia.org

ទ្រព្យសម្បត្តិ ប៉ុន្តែគ្មានចំណេះដឹងធ្វើឱ្យគាត់ចាញ់លើកំណេះទីពីរ។ ចំពោះរឿងធនញ្ជ័យវិញ សេដ្ឋីព្រះរាជ ស្តេចចិនជាអ្នកដែលពោរពេញទៅដោយទ្រព្យសម្បត្តិស្តុកស្តម្ភ ប៉ុន្តែគ្មានចំណេះដឹងទៅជាលូងខ្លៅ ធ្វើឱ្យខ្លួនគេចាញ់ប្រៀបល្បិចប្រាជ្ញារបស់ធនញ្ជ័យទៅវិញ។

សរុបសេចក្តីមកន័យសេចក្តីខាងលើពិតជាត្រឹមត្រូវ បើមានតែទ្រព្យសម្បត្តិមិនគ្រប់គ្រាន់ទេ ដូចមានបញ្ជាក់ក្នុងរឿងខាងលើនេះស្រាប់ ហេតុនេះក្នុងសង្គមមនុស្សក៏មិនអាចគ្រប់គ្រាន់ដែរ បើមនុស្សមានតែទ្រព្យសម្បត្តិនោះ។

បើមានតែទ្រព្យសម្បត្តិមិនគ្រប់គ្រាន់នោះ តើមានអ្វីទៀតទើបគ្រប់គ្រាន់?

ដូច្នេះដើម្បីឱ្យគ្រប់គ្រាន់នោះយើងត្រូវមានទាំងទ្រព្យសម្បត្តិ ទាំងចំណេះវិជ្ជាផងទើបមនុស្សនោះមានលក្ខណៈល្អត្រឹមត្រូវបាន។ ឆ្លងតាមការ

www.elibraryofcambodia.org

សិក្សាស្នាដៃរឿងជាច្រើនកន្លងមកឃើញថា បើមានទាំងទ្រព្យសម្បត្តិ ទាំងចំណេះវិជ្ជាផងពិតជាប្រសើរណាស់។ ដូចក្នុងរឿងកុលាបប៉ៃលិន លោកហ្លួងរតនសម្បត្តិមានទាំងទ្រព្យសម្បត្តិ មានទាំងចំណេះដឹងធ្វើឱ្យគាត់រស់នៅក្នុងភាពសុខស្រួលប្រកបដោយសុភមង្គល។ រឿងស៊ីមអ្នកបរឡាន លោកធំជាមន្ត្រីមួយរូបដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ទោះបីគាត់ជួបបញ្ហាខ្លះក៏ដោយ ក៏អាចធ្វើឱ្យលោករស់នៅបានដោយស្រួលដែរ។

រួមសេចក្តីមក បើមានតែទ្រព្យសម្បត្តិមួយមុខពិតជាមិនគ្រប់គ្រាន់ទេ ទាល់តែមានចំណេះដឹងថែមទៀតទើបបានគ្រប់គ្រាន់។

ពំនោលខាងលើពិតជាមានអត្ថន័យល្អ ព្រោះបានអប់រំយើងឱ្យស្វែងរកចំណេះវិជ្ជាជាធំ។ ទ្រព្យសម្បត្តិអាចរលាយបាត់បង់បាន ប៉ុន្តែបើយើងមាន

www.elibraryofcambodia.org

ទ្រព្យសម្បត្តិហើយមានចំណេះវិជ្ជាជាគ្រឹះទៀត
នោះនឹងធ្វើឱ្យយើងជួបនូវភាពជ្ពុំថ្កើងរុងរឿងក្នុង
សង្គមគ្រួសាររហូតសង្គមជាតិទៅថ្ងៃអនាគត។

www.elibraryofcambodia.org

ប្រធានគំរូទី១៨

ក្នុងច្បាប់កេរកាលថ្មី កវីក្រមង៉ុយលើកឡើងថា "គួរស្គាយកេរ្តិ៍ម៉ែ ឪ កិរិយាត្រូវគួរខំត្រាប់ កិរិយាណាខុសច្បាប់ គួរក្រលាប់ក្រលាស់ចោល"។ ចូរពន្យល់។

សេចក្តីអធិប្បាយ

លោកតាកិរម្យភាសាអ៊ូ ហៅង៉ុយ ជាកវីប្រជាប្រិយមួយរូបផ្ទែកចម្រៀងសារ[illegible]ឆ្ងាយគាត់បានធ្វើឱ្យប្រជាពលរដ្ឋខ្មែរយើងតែងនិយមចូលចិត្ត និងស្តាប់ការទូន្មានរបស់គាត់។ ក្នុងនោះច្បាប់កេរកាលថ្មីរបស់កវីក្រមង៉ុយបានលើកឡើងថា "គួរស្គាយកេរ្តិ៍ម៉ែ ឪ កិរិយាត្រូវគួរខំត្រាប់ កិរិយាណាខុសច្បាប់ គួរក្រលាប់ក្រលាស់ចោល"។

តើទស្សនៈខាងលើមានអត្ថន័យយ៉ាងណា?

ដើម្បីស្វែងរកអត្ថន័យរបស់ទស្សនៈប្រធានខាងលើនោះបាន យើងត្រូវដឹងឱ្យច្បាស់ថា កេរ្តិ៍

www.elibraryofcambodia.org

មានន័យយ៉ាងណា។ កេរ្តិ៍នៅទីនេះមានន័យថា
កេរ្តិ៍ឈ្មោះ កិត្តិយស ឬភាពល្អីល្អាញ។

ឃ្លាថា «គួរស្គាយកេរ្តិ៍ម៉ែ» ចង់បញ្ជាក់ថា មុន
នឹងធ្វើអ្វីមួយយើងត្រូវចេះគិតខ្លាចប៉ះពាល់ដល់វង្ស
ត្រកូល គ្រួសារ ឬពូជពង្សខ្មែរយើង ហើយក៏ត្រូវ
ចេះស្គាយអ្វីដែលជាប្រការល្អ ដើម្បីកុំឱ្យអាប់ឱន
កិត្តិយសដល់គ្រួសារ និងជាតិខ្លួន។ កាលណា
យើងធ្វើអ្វីមួយល្អឬមិនល្អ មនុស្សដែលនៅជុំវិញ
យើង មិនមែនវាយតម្លៃតែលើយើងម្នាក់នោះទេ គឺ
គេអាចគិតដល់ពូជពង្សយើងទៀតផង។ ដូចមាន
សុភាសិតខ្មែរមួយពោលទុកមកថា «សម្តីសជាតិ
មារយាទសពូជ»។

ចំពោះឃ្លា «កិរិយាត្រូវឱ្យខំគ្រាប់» មានន័យថា
បើយើងចង់ត្រងគ្រាប់តាមនរណាម្នាក់គប្បីគ្រាប់
តាមអ្វីដែលល្អ កុំគ្រាប់តាមអ្វីដែលមិនល្អ។ រាល
កិរិយាល្អទាំងអស់នេះហើយយើងត្រូវអនុវត្តតាម

www.elibraryofcambodia.org

ដើម្បីឱ្យមានកេរ្តិ៍ឈ្មោះល្អប្រសើរ។ ខ្មែរជាទូទៅ តែងចាំរត់មាត់នូវសម្តីមួយឃ្លាថា «ពុតគ្រូកុំត្រាប់ ច្បាប់គ្រូឱ្យយក»។ ឃ្លានេះមិនខុសពីឃ្លាខាងលើ ឡើយ គឺចង់ឱ្យបុគ្គលទាំងអស់ចេះត្រងត្រាប់អ្វី ដែលល្អ ទើបជាគំរូល្អសម្រាប់អនាគត។

ចំណែក «កិរិយាណាខុសច្បាប់ គួរក្រលាប់ក្រ លាស់ចោល» មានសេចក្តីថា កិរិយាដែលខុស មានអំពើអសីលធម៌ភ្លើតភ្លើន សម្តីព្រហើនកោង កាច ការប្រព្រឹត្តអំពើអបាយមុខ និងការខ្ជិល ច្រអូសមិនខិតខំធ្វើការ ឬខិតខំរៀនសូត្រ។ កិរិយា ខុសទាំងអស់នេះយើងត្រូវបោះបង់ចោល ព្រោះវា អាចនាំឱ្យមានទុក្ខទោសដល់ខ្លួន។

សរុបសេចក្តីមក ពំនោលរបស់កវីក្រមង៉ុយពិត ជាចង់ធ្វើឱ្យយើងចេះធ្វើអ្វីដោយប្រកាន់យកតែ អំពើល្អជានិច្ច។

www.elibraryofcambodia.org

យោងតាមការអះអាងរបស់ប្រធានខាងលើ ពិតជាមានអត្ថន័យល្អណាស់ ព្រោះជាការទ្ធានដល់មនុស្សគ្រប់ៗរូបឱ្យចេះពិចារណាមុននឹងធ្វើអ្វីមួយដើម្បីកុំឱ្យប៉ះពាល់ដល់កិត្តិយសគ្រួសារ ក៏ដូចសង្គមយើងទាំងមូល។ ដូចនេះយើងជាអ្នកសិក្សាគោងស្វែងយល់ឱ្យបានច្បាស់នូវច្បាប់ផ្សេងៗជាប្រយោជន៍សម្រាប់ខ្លួន និងសង្គមជាតិ។

www.elibraryofcambodia.org

បុរាណខ្មែរបានពោលជាសុភាសិតមួយថា "តក់ៗ ពេញបំពង់"។ ចូរបំភ្លឺដោយលើកបញ្ហាក្នុងសង្គម និងអក្សរសិល្ប៍ដែលបានសិក្សារួចមកបញ្ជាក់។

សេចក្តីអធិប្បាយ

ការរស់នៅក្នុងសង្គម មនុស្សយើងតែងតែមានគោលដៅមួយសម្រាប់អនាគតរបស់ខ្លួន។ ដូចនេះ ដើម្បីសម្រេចគោលដៅនោះម្នាក់ៗតែងតែខិតខំធ្វើការទៅតាមសមត្ថភាពរៀងៗខ្លួន ប៉ុន្តែជាញឹកញយគេពុំសូវបានទៅដល់គោលដៅរបស់គេដោយជោគជ័យឡើយ ដូច្នេះដើម្បីជំនួយដល់ការសម្រេចគោលដៅនោះដោយជោគជ័យ បុរាណខ្មែរយើងបានលើកជាច្បាប់សុភាសិតមួយទុន្មានថា "តក់ៗ ពេញបំពង់"។

តើសុភាសិតនេះមានអត្ថន័យដូចម្តេច?

www.elibraryofcambodia.org

ដើម្បីជាជំនួយក្នុងការស្រាយសុភាសិតខាងលើ យើងគួរយល់ពាក្យពេចន៍ក្នុងសុភាសិតនេះជាមុនសិន។ ពាក្យ "តក់ៗ" ក្នុងទីនេះគឺសំដៅទៅលើតំណក់ទឹកត្នោតដែលស្រក់ចេញពីផ្ការត្នោត។ រីឯពាក្យ "បំពង់" គឺជាឧបករណ៍ដែលគេយកទៅដាក់ ឬយកទៅត្រងទឹកត្នោតនោះឯង។ ចំពោះអត្ថន័យនៃសុភាសិតខាងលើចង់បញ្ជាក់ពីការស្រក់បំពេញនៃទឹកត្នោតក្នុងបំពង់ និងភ្ជាប់ទៅនឹងការព្យាយាមធ្វើការងារអ្វីមួយរបស់មនុស្សក្នុងជីវិតមុននឹងទទួលបានជោគជ័យ ពោលគឺអាស្រ័យដោយភាពអំណត់ព្យាយាមខន្ដីនេះឯង។

ជាការពិតណាស់ នៅប្រទេសកម្ពុជាត្នោតជារុក្ខជាតិមានអត្ថប្រយោជន៍ជាច្រើន និងសម្ស្ររបំផុតជាពិសេសនៅតាមជនបទស្រុកស្រែចម្ការ។ ប្រជារាស្ត្រខ្មែរយល់ឃើញថា ដើមត្នោតមានសារៈសំខាន់ណាស់ ព្រោះវាអាចផ្ដល់ប្រយោជន៍ច្រើន

www.elibraryofcambodia.org

ប្រការសម្រាប់ការរស់នៅរបស់ប្រជាជនខ្មែរ។ ប្រយោជន៍សំខាន់មួយក្នុងចំណោមប្រយោជន៍ជាច្រើននោះគឺ គេអាចទាញយកទឹកធ្វើជាស្ករបាន។ បើយើងពិនិត្យមើលសកម្មភាពអ្នកយកទឹកត្នោតធ្វើស្ករ ហាក់ដូចជាមានលក្ខណៈវែងឆ្ងាយណាស់ ទម្រាំបានជាស្ករ។ ដំបូងយើងឃើញគេគាបនិងចិតក្ដាត្នោតដើម្បីយកទឹកដមដំផ្អែមសម្រក់ចូលក្នុងបំពង់មួយតំណាក់ម្តងៗ។ តាមយើងមើលឃើញទិដ្ឋភាពនេះពិតជាគិតថាបំពង់នោះពុំអាចពេញបានទេ ដោយឃើញវាស្រក់តិចណាស់ តែគួរឱ្យយើងភ្ញាក់ផ្អើលដោយសារគេត្រង់ពេលល្ងាចមួយយប់ដល់ព្រឹកឡើងបំពង់ក៏ពេញប្រៀប។ តែយើងមិនគួរឆ្ងល់ហួសទេ ព្រោះការស្រក់នេះពិតមែនតែតិចមែនតែវាទៀងទាត់ពុំមានពេលអាក់ខានទេ។ ដូចនេះ ភាពទៀងទាត់នៃតំណក់ទឹកទោះជាតិចតួចក្ដី យូរទៅគង់អាចពេញបំពង់បាន។

www.elibraryofcambodia.org

ចំពោះអត្ថន័យនៃការអប់រំវិញ តំណក់ទឹកគ្នាតប្រៀបបានទៅនឹងអំពើអ្វីមួយដែលយើងកំពុងធ្វើ ឯបំពង់គឺប្រៀបដូចគោលដៅដែលយើងចង់បាន។ តែបើតំណក់ទឹកគ្នាតដែលស្រក់ចូលក្នុងបំពង់ពុំទៀង ឬស្រក់ហើយឈប់នោះ បំពង់ក៏មិនអាចពេញបានដែរ។ អាស្រ័យដូចនេះបើយើងធ្វើអ្វីមួយពុំទៀងទាត់ ឬបានបន្តិចឈប់ ព្រោះយល់ឃើញថាលំបាកស្មុគស្មាញ និងឃើញលទ្ធផលតិចតួចនោះ ពិតជាពុំអាចសម្រេចដល់គោលដៅរបស់យើងឡើយ។ ភាពទៀងទាត់នៃតំណក់ទឹកគ្នាតគឺជាភ័ស្តុតាងនៃសេចក្តីព្យាយាមអំណត់អត់ធន់ខន្តីរបស់មនុស្ស។ ជាទូទៅមនុស្សយើងច្រើនមានចិត្តតក់ក្រហល់ចង់បានអ្វីមួយឱ្យទាន់ហាន់ ហើយកាលណាមិនបានទាន់ចិត្តទេ អាចនឹងអស់សង្ឃឹម ស្វាក់ស្ងើរ ហើយមានអ្នកខ្លះទៀតបោះបង់ចោលការតស៊ូភ្លាមតែម្តង។ ទាំងនេះ

www.elibraryofcambodia.org

ហើយជាគំនិតខុសឆ្គងមួយគួរឱ្យសោកស្តាយបំផុត។ យើងក៏បានដឹងហើយថាអ្វីៗគឺអាស្រ័យលើមនុស្សជាអ្នកធ្វើ ហើយកម្លាំងនិងប្រាជ្ញារបស់មនុស្សមានព្រំដែនកំណត់។ ដូច្នេះដើម្បីទទួលបានលទ្ធផលជោគជ័យល្អប្រសើរ ទីមួយគេត្រូវធ្វើ ទីពីរត្រូវមានចិត្តអំណត់ព្យាយាមខន្ដីទើបបានសម្រេច។ យ៉ាងណាមិញអ្នកសិក្សា ដើម្បីសម្រេចគោលដៅរបស់ខ្លួនគេត្រូវមានចំណេះដឹងគ្រប់គ្រាន់ក្នុងការប្រឡងយកសញ្ញាបត្រក្នុងដំណាច់ឆ្នាំសិក្សានីមួយៗ ដោយមានការព្យាយាមអំណត់រៀនសូត្រម្តងបន្ដិចៗជាប្រចាំ។ នេះមិនខុសពីជាងសំណង់ដែលត្រូវបំពេញព្យាយាមសាងសង់រៀបឥដ្ឋបន្ដិចម្តងៗ មុននឹងបង្កើតបានជាផ្ទះមួយដ៏ល្អឆើតឆាយបាន ឬក៏ប្រៀបដូចកណ្ដៀរ ដោយសារការព្យាយាម ពួកវាទទួលបានលទ្ធផលដ៏ស្តុកស្តម្ភគឺដំបូកធំមួយ។ សត្វចាបខំធ្វើសំបុកដោយវា

www.elibraryofcambodia.org

ព្យាយាមញ៉ាំទងស្មៅមួយទងម្តង១ បង្កើតបានជាសំបុកដ៏ល្អសម្រាប់ជាទីជម្រករបស់ពួ។

ចំពោះអត្ថបទអក្សរសិល្ប៍យើងវិញ ដូចជាក្នុងរឿងមាយើង។ មាយើងព្យាយាមហ្វឹកហាត់តាមប្រពន្ធគ្រប់លក្ខណ៍ជានិច្ច ទីបំផុតបានក្លាយជាសេនាឯករបស់ស្តេចរហូតស្តេចឱ្យដារថា "មាយើង"។ មិនខុសអ្វីពីការព្យាយាមធ្វើការងារដោយអំណត់របស់ចៅចិត្តក្នុងរឿងកុលាបប៉ែលិន គឺទីបំផុតចៅចិត្តទទួលបានជោគជ័យក្នុងជីវិតរបស់ខ្លួន គឺប្រែក្លាយពីកម្មករមកជាកូនប្រសារបស់លោកហ្លួងរតនសម្ផត្តិ។ ចំណែកឯរឿង ធនញ្ជ័យនោះវិញក៏បានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ការព្យាយាមរបស់ធនញ្ជ័យក្នុងការផ្ចាញ់ផ្ចាលលោកសេដ្ឋី ទីបំផុតបានទទួលជោគជ័យមែន។

សរុបសេចក្ដីមកឃើញថា រាល់ការងារទាំងអស់ពិតជារកចសម្រេចដល់គោលដៅដោយជោគ

www.elibraryofcambodia.org

ជ័យបាន។ បើគេខិតខំធ្វើវាដោយអំណត់ព្យាយាម។ ផ្ទុយទៅវិញការខ្ជះខ្ជាយសេចក្ដីព្យាយាមអំណត់អត់ធន់ គឺមិនខុសពីទឹកត្នោតដែលស្រក់មិនទៀងទាត់នោះទេ ហេតុនេះគេពុំអាចឈានទៅរកជោគជ័យបានឡើយនៅក្នុងការងាររបស់ខ្លួន។

រួមសេចក្ដីមកឃើញថា សុភាសិតខ្មែរខាងលើពិតជាមានខ្លឹមសារក្នុងការអប់រំមនុស្សជាតិបានល្អប្រាកដមែន។ សុភាសិតនេះមានន័យល្អជាសកលសម្រាប់ឱ្យមនុស្សជាតិយកមកពិចារណា និងអនុវត្ត ពិសេសអ្នកសិក្សាទទួលបាននូវបទពិសោធដ៏ល្អក្នុងការរស់នៅ។ យើងជាអ្នកសិក្សាត្រូវស្វែងយល់ពីសុភាសិតនេះ ដើម្បីជាវិភាគទានដល់យើងឱ្យមានការព្យាយាមអត់ធន់ក្នុងការសិក្សាក្រេបយកចំណេះដឹង និងការប្រតិបត្តិការងារទាំងឡាយប្រកបដោយភាពជោគជ័យក្នុងការរស់នៅ។

www.elibraryofcambodia.org

ប្រធានគំរូទី២០

គេពោលថា "ដើម្បីអភិវឌ្ឍជាតិខ្មែរសព្វថ្ងៃ រដ្ឋត្រូវយកចិត្តទុកដាក់ និងកែច្នៃវិស័យសិប្បកម្ម"។ ចូរស្រាយបំភ្លឺ។

សេចក្តីអធិប្បាយ

ជាតិខ្មែរគឺជាជាតិដែលមានប្រពៃណីខាងសិប្បកម្មយ៉ាងចំណាស់ និងល្បីល្បាញនៅតំបន់អាស៊ីប៉ែកអាគ្នេយ៍តាំងពីយូរណាស់មកហើយ ប៉ុន្តែសព្វថ្ងៃជាតិខ្មែរបានចុះអន់ថយដោយសារតែមិនគិតដល់វិស័យសិប្បកម្ម។ ហេតុនេះហើយទើបមានមតិខ្លះពោលថា "ដើម្បីអភិវឌ្ឍជាតិខ្មែរសព្វថ្ងៃ រដ្ឋត្រូវយកចិត្តទុកដាក់ និងកែច្នៃវិស័យសិប្បកម្ម"។

តើមតិនេះមានអត្ថន័យដូចម្តេច?

www.elibraryofcambodia.org

ដើម្បីងាយស្រួលដល់ការបកស្រាយ ជាបឋម គប្បីយល់ពាក្យ "អភិវឌ្ឍ" យកចិត្តទុកដាក់ កែច្នៃ និងវិស័យសិប្បកម្មជាមុនសិន។ "អភិវឌ្ឍ"មានន័យ ថា ធ្វើឲ្យរីកចម្រើន។ ឯពាក្យ "យកចិត្តទុកដាក់" មានន័យថាគិតគូរដល់។ រីឯពាក្យ"កែច្នៃ"មានន័យ ថា រើធ្វើឡើងឲ្យស្រួលបានល្អ។ ចំណែកឯពាក្យ "វិស័យសិប្បកម្ម"សំដៅលើកិច្ចការដែលធ្វើដោយ ដៃ។ មតិប្រធានមានន័យថា ដើម្បីធ្វើឲ្យរីកចម្រើន ដល់ជាតិ ខ្មែរសព្វថ្ងៃ រដ្ឋត្រូវគិតគូរ និងរើធ្វើឡើង ឲ្យបានល្អផ្នែកកិច្ចការដែលធ្វើដោយដៃ។

ពិតមែនហើយដើម្បីអភិវឌ្ឍជាតិខ្មែររដ្ឋត្រូវយក ចិត្តទុកដាក់ និងកែច្នៃវិស័យសិប្បកម្ម គឺត្រូវណែនាំ សិប្បករឲ្យខិតខំផលិត ហើយធានារកទីផ្សារឲ្យ សិប្បករអាចលក់ផលិតផលបាន ពិសេសត្រូវធានា លើតម្លៃទំនិញដែលសិប្បករផលិតបាន ដើម្បីឲ្យ ពួកគេមានភាពកក់ក្តៅ និងខិតខំផលិតទៀត។

www.elibraryofcambodia.org

លើសពីនេះ រដ្ឋត្រូវណែនាំ និងបង្ហាត់បង្ហាញដល់
សិប្បករពីរបៀបផលិតដើម្បីឲ្យត្រូវតាមស្តង់ដារ ឬ
ចំណង់ចំណូលចិត្តអតិថិជន ទើបធ្វើឲ្យសិប្បកម្ម
នោះទទួលបានជោគជ័យ។ ម្យ៉ាងទៀត រដ្ឋត្រូវ
ណែនាំសិប្បករទាំងអស់ទម្លាប់ប្រើឧបករណ៍វិទ្យា
សាស្ត្រសម្រាប់បង្កើនទាំងចំនួន និងគុណភាពឲ្យ
កាន់តែទំនើបទាន់សម័យដូចបណ្តាប្រទេសជឿន
លឿនលើសកលលោក។ បន្ថែមលើនេះ រដ្ឋត្រូវ
សម្រួលដល់សិប្បករដូចជា ចេញអាជ្ញាបណ្ណដើម្បី
ឲ្យសិប្បករអាចប្រកបអាជីវកម្មបានដោយឥតភ័យ
ខ្លាច ហើយរដ្ឋមិនត្រូវបង្កភាពអសកម្មដល់សិប្បករ
ឡើយ ដូចជារកលេសនេះលេសនោះ ដើម្បីបាន
លុយកាក់ ឬគំរាមកំហែងដើម្បីយកផលប្រយោជន៍
ផ្ទាល់ខ្លួននោះទេ។ ក្រៅពីនេះ រដ្ឋត្រូវលុបបំបាត់
ភាពអសកម្មទាំងឡាយឲ្យអស់ដោយផ្តន្ទាទោស
ដល់ជនដែលបានប្រព្រឹត្តល្មើសទៅតាមច្បាប់។

www.elibraryofcambodia.org

ការយកចិត្តទុកដាក់ និងកែច្នៃវិស័យសិប្បកម្ម
របស់រដ្ឋ ពិតជាមានសារៈសំខាន់ក្នុងការអភិវឌ្ឍ
ជាតិខ្មែរសព្វថ្ងៃ ព្រោះវិស័យសិប្បកម្មបានបង្កើត
ការងារ និងមុខរបរឲ្យមនុស្សជាច្រើន ដោយបាន
ជួយកាត់បន្ថយវិបត្តិឥតការងារធ្វើ ឬភាពក្រីក្រ
របស់ប្រជាពលរដ្ឋ។ ការមានមុខរបរធ្វើឲ្យគេអាច
កសាង សេដ្ឋកិច្ចគ្រួសារក៏ដូចជាសេដ្ឋកិច្ចរដ្ឋឲ្យរីក
ចម្រើន តាមរយៈការលក់ផលិតផលឲ្យទេសចរក្នុង
ស្រុក និងក្រៅស្រុក។ កាលណា សិប្បករលក់
ទំនិញបានច្រើន រដ្ឋក៏ងាយស្រួលប្រមូលពន្ធដែរ។
ម្យ៉ាងទៀតសិប្បកម្មទាំងឡាយបានជួយផ្សព្វ
ផ្សាយពីសក្តានុពលប្រពៃណីជាតិដល់ទេសចរ
ជាតិ និងអន្តរជាតិឱ្យបានដឹងនិងស្គាល់តាមរយៈ
ផលិតផលទាំងឡាយ ដែលភ្ញៀវទាំងនោះបាន
ទិញនៅតាមទីផ្សារក្តី ឬតាមរមណីយដ្ឋានក្តី។ ជាក់
ស្តែង ដោយការយកចិត្តទុកដាក់ និងកែច្នៃវិស័យ

www.elibraryofcambodia.org

សិប្បកម្មរបស់រដ្ឋ បានជំរុញឲ្យវិស័យសិប្បកម្មរក្សា
បានប្រពៃណីរបស់ខ្លួន និងរីកចម្រើនមាននៅស្ទើរ
គ្រប់ខេត្តក្រុង ដូចជាសិប្បកម្មគ្រឿងឈើនៅខេត្ត
សៀមរាប, សិប្បកម្មគ្រឿងថ្មនៅខេត្តពោធិ៍សាត់
កំពុងចាម កំពត កំពុងធំ, សិប្បកម្មគ្រឿងមាស
ប្រាក់នៅខេត្តកណ្តាល, សិប្បកម្មតម្បាញនៅខេត្ត
កំពុងចាម តាកែវ កណ្តាល និងសិប្បកម្មឆ្នាំងដីនៅ
ខេត្តកំពុងឆ្នាំង។ ការរីកចម្រើនវិស័យសិប្បកម្មបាន
ធ្វើឲ្យប្រជាពលរដ្ឋខ្មែរភាគច្រើនមានការងារធ្វើ
មានមុខរបរចិញ្ចឹមជីវិត អាចទាញកម្រៃបានងាយពី
ការលក់ផលិតផលទាំងឡាយដល់ភ្ញៀវទេសចរ
ក្នុងនិងក្រៅស្រុក។ តាមរយៈវត្ថុអនុស្សាវរីយ៍ដែល
ភ្ញៀវបានទិញ បានធ្វើឲ្យភ្ញៀវជាតិ និងអន្តរជាតិ
យល់យ៉ាងច្បាស់ពីប្រពៃណីដ៏ល្អ ភាពឧស្សាហ៍
ព្យាយាមរបស់ជនជាតិខ្មែរក្នុងរបរចិញ្ចឹមជីវិត ដូច
ជាតម្បាញហូលជាមួង ពិសេសការតម្បាញនាំង

www.elibraryofcambodia.org

ដែលមានភាពស្មុគស្មាញ និងលំបាកច្រើនក្នុងការ
បង្កើត។ ចំណែកនៅក្នុងអក្សរសិល្ប៍ក៏បានបង្ហាញ
ពីសិប្បកម្មនេះដែរ ដូចជារឿងទុំទាវ បានធ្វើឲ្យគេ
ស្គាល់ផលិតផលមួយគឺគោកតាមរយៈតួអង្គទុំនិង
ពេជ្រដែលបានដើរលក់ជាហ្វូរហែ តាំងពីខេត្តព្រៃ
វែងរហូតដល់ត្បូងឃ្មុំខេត្តកំពុងចាម។ រីឯរឿងភូមិ
គិរច្ឆានក៏បានធ្វើឲ្យគេដឹងពីសិប្បកម្មធ្វើឆ្នាំងដី ក្ដម
របស់អ្នកខេត្តកំពុងឆ្នាំង។ នៅសម័យនោះ សិប្ប
កម្មធ្វើក្ដមឆ្នាំងជាមុខរបរមួយបន្ទាប់បន្សំគ្រាន់ជួយ
សម្រួលជីវភាពប៉ុណ្ណោះ។ សាច់រឿងក៏បានបង្ហាញ
ផងដែរថា ការធ្វើជំនួញក្ដមឆ្នាំងនៅពេលនោះមិន
មានដំណើរការល្អទេ គឺដោយសារតែអាជ្ញាធរមិមូល
ដ្ឋានបង្ក្ដេឡ្ងៃ។ នៅពេលអ្នកសុវណ្ណ និងអ្នកប៊ុត
បានដឹកក្ដមឆ្នាំងទៅលក់នៅខេត្តកំពុងឆ្នាំងក៏មាន
ការរំខានពីក្រុមប៉ូលិស ដូចជាម្ដងរកលិខិតសម្គាល់
ខ្លួន ម្ដងទារភាស៊ី(ជាស៊ី) ម្ដងមកជាកពីន័យ ដែល

www.elibraryofcambodia.org

ជំរុញឲ្យអ្នកសុវណ្ណ និងអ្នកប៊ីតដឹករបស់របរទៅផ្ទះ
ញ្ញទាំងអស់សង្ឃឹម។

សរុបមក ការយកចិត្តទុកដាក់និងកែច្នៃវិស័យ
សិប្បកម្មពីរដ្ឋ គឺជាកត្តាសំខាន់និងមិនអាចខ្វះបាន
ក្នុងការធ្វើឲ្យប្រទេសជាតិរីកចម្រើន។ នៅពេល
ដែលវិស័យសិប្បកម្មចម្រើនជឿនលឿន វាក៏ធ្វើឲ្យ
មនុស្សមានការងារ មានប្រាក់ចំណូល និងធ្វើឲ្យ
ជាតិខ្មែរមានកេរ្តិ៍ឈ្មោះល្បីលើឆាកអន្តរជាតិដែរ។
ពេលនោះហើយដែលប្រទេសខ្មែរស្គាល់ភាពរុង
រឿងដូចអារ្យប្រទេសលើពិភពលោក។

ឆ្លងតាមការបកស្រាយខាងលើរួចមក មតិ
របស់ប្រជាជនមានអត្ថន័យល្អប្រសើរណាស់ ព្រោះ
មតិនេះបានជាសំណូមពរតឿអ្នកដឹកនាំ ក៏ដូចជាប្រជា
ជនខ្មែរឲ្យស្គាល់ពីតម្លៃនិងប្រយោជន៍នៃសិប្បកម្ម
ខ្មែរ ហើយយកចិត្តទុកដាក់ និងកែច្នៃវិស័យសិប្ប
កម្ម ដោយខ្ជិតខ្ជាបង្កើតឲ្យរីកច្រើន ដើម្បីធ្វើឲ្យ

www.elibraryofcambodia.org

ប្រទេសខ្មែរស្គាល់ភាពសម្បូរសប្បាយជានិរន្តន៍។
ដូចនេះ យើងជាសិស្សានុសិស្សត្រូវខិតខំស្វែង
យល់ពីវិស័យសិប្បកម្មនេះបន្ថែមទៀត ដើម្បីចូល
រួមចំណែកធ្វើយ៉ាងណាឲ្យវិស័យនេះកាន់តែរីក
ចម្រើនឡើងទៀត។

www.elibraryofcambodia.org

គម្រោងប្រធានតែងសេចក្តី
ដែលឆ្លាប់ចេញក្នុងការប្រឡង

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សម័យប្រឡង ថ្ងៃទី២៤ កក្កដា ២០១១

ថ្នាក់វិទ្យាសាស្ត្រសង្គម

ប្រធាន៖ *គេថា "ការចេះរួបរួមសាមគ្គីគ្នារមែងទទួលបានជោគជ័យ ផ្ទុយទៅវិញការបែកបាក់សាមគ្គីនោះនឹងទទួលបរាជ័យ"។ តើពាក្យទាំងពីរល្អះនេះមានអត្ថន័យយ៉ាងដូចម្តេច? ចូរពន្យល់ដោយលើកយកអំណះអំណាងមកបញ្ជាក់។*

គម្រោងតែង

១. សេចក្តីផ្តើម

- *លំនាំបញ្ជា*៖ ពាក្យការបំពេញកិច្ចការណាមួយ មនុស្សគ្រប់រូបតែងមានបំណងចង់ឲ្យការងារនោះបានសម្រេច.....។

www.elibraryofcambodia.org

- *ចំណាលបញ្ហា*៖ ដោយហេតុនេះហើយទើបគេថា ឃ្លានាន។

- *ចំណាកចេញ*៖ តើពំនោលទាំងពីរល្បះខាងលើនេះមានអត្ថន័យយ៉ាងដូចម្តេចខ្លះ?

២. តូសេចក្តី

- *ឃ្លាភ្ជាប់សេចក្តី*៖ ដើម្បីជាជំនួយដល់ការបកស្រាយ.....។

- *ពន្យល់ពាក្យ*៖

• ការរួបរួមសាមគ្គី៖ ការរួបរួមគ្នាជាធ្លុងមួយ ឬជាដំណើរស្រុះស្រួលគ្នា ដើម្បីបំពេញកិច្ចការណាមួយឱ្យសម្រេច។

• ជោគជ័យ៖ ការឈ្នះ ឬការសម្រេចបំណង។

• បែកបាក់សាមគ្គី៖ ការប្រេះឆាគ្នា ញែកចេញពីគ្នា មិនរួបរួមគ្នា។

• បរាជ័យ៖ការចុះចាញ់ ឬការមិនសម្រេចបំណង។

www.elibraryofcambodia.org

- *ពន្យល់ន័យប្រធាន*៖ ការរួបរួមគ្នាតែងតែមានជ័យជម្នះសម្រេចតាមបំណង ផ្ទុយទៅវិញបើមិនរួបរួមគ្នាទេ គេនឹងចុះចាញ់មិនសម្រេចបំណង។

- *បកស្រាយ*៖ "ការចេះរួបរួមសាមគ្គីគ្នារមែងទទួលបានជោគជ័យ ផ្ទុយទៅវិញការបែកបាក់សាមគ្គីនោះនឹងទទួលបរាជ័យ"។

ក. ការចេះរួបរួមសាមគ្គីគ្នារមែងទទួលបានជោគជ័យ៖

- មានភាពស្មោះត្រង់ ចិត្តតែមួយ (ឆន្ទៈរួមគ្នា)
- មិនរើសអើងគ្រប់ស្រទាប់នៃមនុស្ស (មិនប្រកាន់ទិន្នាការជាតិសាសន៍)។
- ចេះគោរពឆន្ទៈ គោរពសិទ្ធិ គោរពច្បាប់ (មានអធ្យាស្រ័យយោគយល់គ្នា)។
- នាំមកនូវភាពជោគជ័យ ក្នុងបំណងរួមណាមួយ (ឯកភាពគ្នា)។

www.elibraryofcambodia.org

- បានផ្តល់អត្ថប្រយោជន៍ដល់ឧត្តមភាពបុគ្គល ឧត្តមភាពជាតិ (កិត្តិយស, កិត្យានុភាព)។
- នាំមកនូវអត្ថិភាពសង្គម ជៀសផុតពីការគាបសង្កត់ដោយជាតិសាសន៍ដទៃ (ពលិកម្មដើម្បីបុព្វហេតុជាតិ)។...

ឧទាហរណ៍៖

ក្នុងសង្គមគ្រួសារនិងសង្គមជាតិ

- គ្រួសារចេះសាមគ្គីគ្នា ហើយមានទឹកចិត្តរួមគ្នានឹងធ្វើឱ្យគ្រួសារមានសេចក្តីសុខ(សុភមង្គល)។
- កងទ័ពនៅសមរភូមិរួបរួមសាមគ្គីគ្នាប្រយុទ្ធនឹងសត្រូវដើម្បីបុព្វហេតុជាតិ ទើបអាចការពារបាននូវបូរណ ភាពទឹកដី មរតកវប្បធម៌។
- កីឡាករ(ប្រណាំងទូក, បាល់ទាត់...)ដែលមាននូវឆន្ទៈរួមគ្នាវេញជាធ្លុងមួយ នឹងអាចដណ្តើមបានជ័យលាភីក្នុងការប្រកួត។

www.elibraryofcambodia.org

- ប្រជារាស្ត្រគ្រប់ស្រទាប់ជាន់ថ្នាក់ និងអ្នកដឹកនាំ រួបរួមគ្នាដើម្បីអភិវឌ្ឍជាតិ នោះសង្គមនឹងមានការកែចម្រើនឆាប់រហ័ស។

ប្រវត្តិសាស្ត្រ

- នៅសម័យអង្គរ ដោយមានការរួបរួមគ្នារវាងប្រជារាស្ត្រនិងប្រជារាស្ត្រ រវាងប្រជារាស្ត្រនិងព្រះរាជ (ឧទា. ស្តេចជ័យវរ្ម័នទី៧)ក្នុងកិច្ចការពារទឹកដី និងការកសាងជាតិ នាំឱ្យខ្មែរមានកិត្យានុភាពនិងភាពរុងរឿងបំផុតក្នុងប្រវត្តិសាស្ត្រ។
- នៅសម័យអាណានិគមបារាំង ដោយមានការរួបរួមគ្នាជាបន្តបន្ទាប់ពីសំណាក់អាចារ្យស្វា, ពោធិ កំបោរ, អាចារ្យហែមចៀវ ... ក្នុងកិច្ចការការពារទឹកដីនិងវប្បធម៌អក្សរសាស្ត្រជាតិ ទើបខ្មែរអាចរក្សាបាននូវមរតកវប្បធម៌ជាតិ។

www.elibraryofcambodia.org

អក្សរសិល្ប៍ តាមរយៈរឿង

- ភូមិតិរច្ឆាន កម្លាំងសាមគ្គីភាពរវាងប្រជារាស្ត្រ ក្រាំងលាវ ក៏បានសម្រេចជោគជ័យក្នុងការប្រឆាំងនឹងវ៉ែស៊ីដង់បាដេស ហើយក៏ធ្វើឱ្យអាណានិគមនិយមបារាំងសើរើពិនិត្យលើការគ្រប់គ្រងរបស់ខ្លួនចំពោះរាស្ត្រខ្មែរដែរ។

- គូលីកំណែន ដោយមានការរួបរួមគ្នា (យឹមមានបទពិសោធតស៊ូ លឹមជាកសិករ ម៉ឹងជាបញ្ញវន្ត និងដូងជាមេដឹកនាំប្រជារាស្ត្រ) ក៏បានជោគជ័យលើអាណានិគមនិយមបារាំង (ដើម្បីឯករាជ្យ សេរីភាព ប្រជាធិបតេយ្យ)។

- រឿងអាខ្ទាក់អាខ្ទិនបង្ហាញពីកម្លាំងសាមគ្គីរបស់អ្នកទាំងពីរ ដែលចេះពឹងផ្អែកលើជំនាញរៀងៗខ្លួនជួយគ្នាទៅវិញទៅមក រហូតអាចបានសម្រេចបំណងក្នុងការធ្វើដំណើរទៅមុខ....។

www.elibraryofcambodia.org

ខ. ការបែកបាក់សាមគ្គីនាំមកនូវបរាជ័យ៖

- មិនមានភាពស្មោះត្រង់ មិនមានចិត្តតែមួយ នាំឱ្យមានឆន្ទៈមិនរួមគ្នា។

- រើសអើងគ្រប់ស្រទាប់នៃមនុស្ស នាំឱ្យមានការប្រកាន់និន្នាការ និងជាតិសាសន៍។

- មិនចេះគោរពឆន្ទៈ គោរពសិទ្ធិ គោរពច្បាប់ នាំឱ្យមនុស្សរស់នៅមិនសុខសាន្ត មិនចុះសម្រុងគ្នា និងមានភាពអាណាធិបតេយ្យ។

- ការបែកបាក់សាមគ្គីនាំមកនូវអស្ថិរភាពសង្គម ជៀសមិនផុតពីការគាបសង្កត់ដោយជាតិសាសន៍ដទៃ ត្បិតមនុស្សមិនហ៊ានធ្វើពលីកម្មដើម្បីបុព្វហេតុជាតិ។ ឧទាហរណ៍៖

ក្នុងសង្គមគ្រួសារនិងសង្គមជាតិ

- បើគ្រួសារមួយមានការបែកបាក់សាមគ្គីគ្នា គ្មានទឹកចិត្តរួមគ្នាទេ ធ្វើឱ្យគ្រួសារមិនមានសេចក្តីសុខ (គ្មានសុភមង្គល)។

www.elibraryofcambodia.org

- បើកងទ័ពនៅសមរភូមិមិនសាមគ្គីគ្នាប្រយុទ្ធនឹងសត្រូវដើម្បីបុព្វហេតុជាតិទេ គេក៏ពុំអាចការពារបាននូវបូរណភាពទឹកដីបានឡើយ។

- បើកីឡាករ (ទូក បាល់ទាត់...) បែកបាក់សាមគ្គីគ្នា មិនវេញជាធ្លុងមួយទេ នោះមិនអាចដណ្តើមបានជ័យលាភីលើគូប្រកួតឡើយ។

- បើប្រជារាស្ត្រគ្រប់ស្រទាប់ជាន់ថ្នាក់ និងអ្នកដឹកនាំមិនរួបរួមគ្នាដើម្បីអភិវឌ្ឍជាតិទេ សង្គមមិនមានការរីកចម្រើនឡើយ។

ប្រវត្តិសាស្ត្រ

- បើនៅសម័យអង្គរពុំមានការរួបរួមគ្នារវាងប្រជារាស្ត្រ និងប្រជារាស្ត្រ រវាងរាស្ត្រ និងព្រះរាជាក្នុងកិច្ចការពារទឹកដី ការកសាងប្រាសាទទេ ពុំមានកិត្យានុភាពរុងរឿងឡើយ។

- បើនៅសម័យអាណានិគមនិយមបារាំង ពុំមានការរួបរួមគ្នាជាបន្តបន្ទាប់ពីសំណាក់អាចារ្យស្វា,

www.elibraryofcambodia.org

ពោធិ៍កំបោរ, អាចារ្យហ៊ីមចៀវនិងអ្នកស្នេហាជាតិផ្សេងទៀត ក្នុងការការពារទឹកដីនិងវប្បធម៌អក្សរសាស្ត្រជាតិទេនោះ ម្ល៉ះខ្មែរពុំអាចរក្សាបានមរតកវប្បធម៌ជាតិឡើយ។...

ក្នុងអក្សរសិល្ប៍

- រឿងភូមិតិរច្ឆាន ដោយសារតែមិនមានឯកភាពគ្នារវាងប្រជារាស្ត្រក្រាំងលាវ និងជួន នៅ ទើបពួកគេទទួលរងការបាញ់សម្លាប់ពីសំណាក់ទាហានបារាំង និងចាប់យកទៅដាក់គុក។

- រឿងអាខ្ជាក់អាខ្ជិន ដោយសារតែអ្នកទាំងពីរពុំសាមគ្គីគ្នាតាមជំនាញរៀងៗខ្លួន ទើបពុំអាចអុំទូកដល់ត្រើយបាន (មិនសម្រេចបំណងក្នុងការធ្វើដំណើរទៅមុខ)។...

សរុប៖ ការរួបរួមសាមគ្គីគ្នារមែងទទួលបានជោគជ័យ។ ផ្ទុយទៅវិញបើបែកបាក់សាមគ្គីគ្នា គេនឹងទទួលបរាជ័យយ៉ាងពិតប្រាកដមែន។

www.elibraryofcambodia.org

៣. សេចក្ដីបញ្ចប់

- *សន្ទិដ្ឋានទស្សនៈប្រជានៈ* ទស្សនៈប្រជានមានអត្ថន័យជ្រាលជ្រៅ ព្រោះបានបង្ហាញពីសារប្រយោជន៍នៃសាមគ្គីភាព និងផលអាក្រក់នៃការបែកបាក់សាមគ្គី.....។

- *មតិផ្ទាល់ខ្លួន*ៈ ដូចនេះក្នុងនាមជាកូនខ្មែរ យើងគប្បីចេះស្រឡាញ់គ្នា សាមគ្គីគ្នាការពារទឹកដី.....។

www.elibraryofcambodia.org

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សម៉ោងប្រឡង ថ្ងៃទី០៦ សីហា ២០១២

ថ្នាក់វិទ្យាសាស្ត្រ

ប្រធាន៖ *ទស្សនៈមួយពោលថា "ទ្រឹស្តីព្រះពុទ្ធសាសនាជួយឲ្យសង្គមខ្មែរបង្កើតបានវប្បធម៌សន្តិភាព"។ តើទស្សនៈនេះមានន័យដូចម្តេច ? ចូរពន្យល់ដោយលើកយកអំណះអំណាងមកបញ្ជាក់។*

គម្រោងតែង៖

១. សេចក្តីផ្តើម

- *លំនាំបញ្ហា៖*
- *ចំណាលបញ្ហា៖*
- *ចំណោទបញ្ហា៖* សូរបែបប្រធានពន្យល់។

២. តួសេចក្តី

- *ឃ្លាភ្ជាប់សេចក្តី៖*
- *ពន្យល់ពាក្យ៖*

www.elibraryofcambodia.org

- ទ្រឹស្តីពុទ្ធសាសនា ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ, បណ្តាំព្រះពុទ្ធ, ព្រះធម៌។
- វប្បធម៌សន្តិភាព គឺការកសាងតម្លៃនៃគុណធម៌ ចរិយាធម៌ និងសីលធម៌ ក្នុងឥរិយាបថទាំងបួនដែលឆ្លុះបញ្ចាំងពីការគោរពជីវិត ការគោរពចំពោះមនុស្សជាតិនិងភាពថ្លៃថ្នូររបស់មនុស្ស ផង។ ការគោរពសិទ្ធិមនុស្ស និងបដិសេធចោលនូវគ្រប់រូបភាពនៃអំពើហិង្សា ព្រមទាំងគោរពនូវគោលការណ៍ សេរីភាព យុត្តិធម៌ និងសាមគ្គីធម៌ ភាពមានអធ្យាស្រ័យ និងការយោគយល់គ្នារវាងក្រុមមនុស្ស និង បុគ្គល។

- ពន្យល់ន័យប្រធាន៖

- *បំណងស្រាយ*៖ ទ្រឹស្តីពុទ្ធសាសនាជួយឲ្យសង្គមខ្មែរ បង្កើតបានវប្បធម៌សន្តិភាព។

www.elibraryofcambodia.org

គោលការណ៍ព្រះពុទ្ធសាសនា៖

+ សីលប្រាំ

+ ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់(ចូរអ្នកវៀរចាក អំពើអាក្រក់សាងតែអំពើជាកុសល)

+ ធម៌អហិង្សា(មិនបំពានលើរូបកាយអ្នកដទៃ...)

+ ត្រូវជម្រះបន្ទិលទាំងផ្លូវកាយនិងផ្លូវចិត្ត កាត់បន្ថយទំនាស់ តណ្ហា បង្កើតធម៌អហិង្សា ហើយចេះសាបគ្នា ស្រឡាញ់គ្នា ជួយសង្គ្រោះគ្នាទៅវិញទៅមក

+ ម្ហូបចមិនរើសអើង មិនប្រកាន់ជ្នា ហើយរួបគ្នាស្អប់ខ្ពើមសង្គ្រាម

+ ពៀរអាងប់ដោយការមិនចងពៀរ ហើយបង្កើតសេចក្ដីស្អាតស្អំបរិសុទ្ធផ្លូវចិត្ត

+ ឱ្យមនុស្សលះបង់អំពើអកុសល រួបគ្នាកសាងតែអំពើជាកុសល ដើម្បីមនុស្សជាតិទូទៅ

www.elibraryofcambodia.org

ឧទាហរណ៍ៈ

- ក្នុងរឿងព្រះវេស្សន្តរ ព្រះវេស្សន្តរគោរពលទ្ធិប្រជាធិបតេយ្យ លះបង់ភពល្អង្គយាងទៅសាងផ្នួសដើម្បីចម្លងសត្វៈលោកឱ្យរួចផុតពីទុក។

- រឿងសុវណ្ណសាម

- រឿងព្រះតេមិយ

- រឿងព្រះរកទិព្យថ្មីៈលើផែនដីចាស់

- ក្នុងសង្គម ខ្មែរជាជាតិស្លូតត្រង់ ស្រឡាញ់សន្តិភាព មិត្តភាព ដ៏ងដែលណ្ហូនពានប្រទេសជិតខាង។ នេះបញ្ជាក់ថាខ្មែរជាពុទ្ធសាសនិកជនស្រឡាញ់វប្បធម៌ សន្តិភាព។

+ រីឯគោលបំណងនៃវប្បធម៌សន្តិភាពមានៈ

- លើកទឹកចិត្តដល់ការអប់រំសន្តិភាព សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ ការសន្ធោសអធ្យាស្រ័យ និងការយោគយល់អន្តរជាតិ។

www.elibraryofcambodia.org

- ការពារ និងការពារសិទ្ធិមនុស្ស ហើយប្រឆាំងនឹងការរើសអើងគ្រប់រូបភាព។
- លើកគោលការណ៍ប្រជាធិបតេយ្យដល់គ្រប់លំដាប់ថ្នាក់ក្នុងសង្គម។
- រស់នៅដោយការសន្ធោស អធ្យាស្រ័យ និងសាមគ្គី។
- ប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ហើយធានាការអភិវឌ្ឍ ដែលមានលក្ខណៈស្វ័យគ្រប់គ្រង ដើម្បីភាពរុងរឿងសម្រាប់ទាំងអស់គ្នា ដែលផ្តល់ឱ្យជនគ្រប់រូបមានជីវភាពរស់នៅប្រកបដោយគុណភាព និងភាពថ្លៃថ្នូរ។

ដោយផ្អែកលើខ្លឹមសារ និងគោលបំណងនៃទ្រឹស្តី ព្រះពុទ្ធសាសនា និងវប្បធម៌សន្តិភាពនោះ យើងឃើញថាទ្រឹស្តីនៃព្រះពុទ្ធសាសនាពិតជាបានបង្កើតឱ្យមានវប្បធម៌សន្តិភាព ព្រោះខ្លឹម

www.elibraryofcambodia.org

សារមួយខាងលើគឺឈរនៅលើគោលការណ៍
មនុស្សនិយមដូចគ្នា។

សរុប៖ ទ្រឹស្តីព្រះពុទ្ធសាសនាពិតជាជួយឱ្យ
សង្គមខ្មែរបង្កើតបានវប្បធម៌សន្តិភាពមែន។

៣. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន តាមបែបប្រធានពន្យល់
- គតិអប់រំ ឬមតិផ្ទាល់ខ្លួន។

www.elibraryofcambodia.org

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សម័យប្រឡង ថ្ងៃទី១៣ តុលា ២០១៤

ថ្នាក់វិទ្យាសាស្ត្រ (រយៈពេល៩០នាទី)

ប្រធាន៖ *មានទស្សនៈមួយចែងថា "អក្សរសាស្ត្រលត់ជាតិលោយ អក្សរសាស្ត្រពណ្ណរាយ ជាតិថ្លើងជ្ជាន"។ ចូរអ្នកធ្វើការបកស្រាយទស្សនៈនេះ ដោយយកវិត្តន៍អក្សរសិល្ប៍ខ្មែរមកបញ្ជាក់។*

គម្រោងតែង

១. សេចក្តីផ្តើម

- *លំនាំបញ្ហា៖*
- *ចំណាលបញ្ហា៖*
- *ចំណោទបញ្ហា៖* (ចោទតាមបែបពន្យល់)

២. តួសេចក្តី

- *ឃ្លាភ្ជាប់សេចក្តី៖*
- *ពន្យល់ពាក្យ៖*

www.elibraryofcambodia.org

អក្សរសាស្ត្រ៖ វិជ្ជាអក្សរ, ក្បួនច្បាប់អក្សរ, វិជ្ជាខាងនិពន្ធ ឬក្បួនច្បាប់នានាសម្រាប់ឱ្យមនុស្សអនុវត្ត ប្រតិបត្តិតាម។

រលត់រលាយ៖ បាត់បង់ សាបសូន្យ។

ពណ្ណរាយ៖ ពន្លឺរស្មីត្រចេះត្រចង់។

ថ្កើងថ្កាន៖ រុងរឿង រីកចម្រើន។

- ពន្យល់ន័យប្រធាន៖

ន័យរបស់ប្រធានបានលើកឡើងថា ក្បួនច្បាប់គម្ពីរទាំងឡាយ នៅពេលវាបាត់បង់សាបសូន្យ គឺពិតជានាំឱ្យជាតិបាត់បង់ ឬចុះអន់ថយ តែបើវារុងរឿងចម្រើនឡើង ជាតិក៏រស់គង់វង្ស រីកចម្រើនរុងរឿងឡើង។

- បំណកស្រាយ៖

ក. បង្ហាញពីតម្លៃរបស់អក្សរសាស្ត្រខ្មែរ

- ជាមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់ជាតិ

- ជាដួងព្រលឹងនៃប្រវត្តិជាតិ

www.elibraryofcambodia.org

- ជាអត្តសញ្ញាណជាតិខ្មែរ

- ជាមធ្យោបាយសម្រាប់ទំនាក់ទំនងគ្រប់ប្រភេទ

- ផ្តល់នូវពុទ្ធិ ចំណេះដឹង [illegible]អប់រំដ៏ច្រើនសម្រាប់ក្មួនចៅជាតិខ្មែរ

ខ. កាលណាអក្សរសាស្ត្ររលត់ គឺពិតជានាំឱ្យប្រទេសជាតិត្រូវបាត់បង់

- អត្តសញ្ញាណជាតិ

- ពួជសាសន៍ ត្រូវគេមើលងាយ

- វប្បធម៌ ទំនៀមទម្លាប់របស់ជាតិ

- ប្រទេសជាតិត្រូវធ្លាក់ស្រុតចុះអន់ថយ

- ត្រូវរស់ស្ថិតនៅក្រោមចំណុះរបស់ប្រទេសដទៃ

ឧទាហរណ៍៖

- វិវត្តន៍អក្សរសិល្ប៍

សម័យអាណានិគមបារាំង

www.elibraryofcambodia.org

- បារាំងចង់បំបាត់អក្សរសាស្ត្រខ្មែរ បំបាត់វប្ប ធម៌ខ្មែរ ហើយបំពក់បំពុលវប្បធម៌របស់បារាំង នាំ ឱ្យអក្សរសាស្ត្រខ្មែរស្ទើររលត់រត់ទៅសំងំនៅក្នុងវត្ត អារាម ដើម្បីឱ្យព្រះសង្ឆជួយថែរក្សា។ ពេលនោះ ប្រទេសជាតិខ្មែរត្រូវធ្លាក់ដុនដាប ស្ថិតនៅក្រោម ចំណុះរបស់បារាំង។

- នៅសម័យប៉ុលពត អក្សរសាស្ត្រខ្មែរត្រូវបាន បំបាត់ទាំងស្រុង ពេលនោះប្រទេសជាតិខ្មែរ បាន ក្លាយទៅជាវាលពិឃាត។

- អក្សរសិល្ប៍រឿងភូមិតិរច្ឆាន អ្នកនិពន្ធបាន រៀបរាប់បង្ហាញឱ្យឃើញពីសេចក្ដីទុក្ខសោកដ៏ សែនវេទនារបស់ប្រជាជនខ្មែរ ដែលរស់នៅក្រោម ការគាបសង្កត់ និងក្រោមការប្រើអំណាចផ្តាច់ការ របស់ពួកបារាំង។

www.elibraryofcambodia.org

គ. កាលណាអក្សរសាស្ត្រពណ្ណរាយ នោះ ប្រទេសជាតិពិតជាមានភាពរុងរឿងជឿនលឿន គ្រប់ផ្នែក គ្រប់វិស័យដូចជា៖

- ប្រទេសជាតិទទួលបានឯករាជ្យ កិត្យានុភាព
- មានអត្តសញ្ញាណផ្ទល់របស់ខ្លួន
- មានសមភាព តម្លាភាព
- ជាតិ ពុជសាសន៍ ស្ថិតស្ថេរគង់វង្ស
- មានបូរណភាពទឹកដី
- បរទេសមិនមើលងាយ មិនហ៊ានឈ្លានពាន

ឧទាហរណ៍៖

វិវត្តន៍អក្សរសិល្ប៍សម័យអង្គរ

- អក្សរសាស្ត្រខ្មែរមានភាពរុងរឿង មានអ្នកនិពន្ធល្បីៗជាច្រើន ពេលនោះប្រទេសជាតិមានភាពល្បីល្បាញអស្ចារ្យ។

- អក្សរសិល្ប៍រឿងរាមកេរ្ត៍ អ្នកនិពន្ធបានបញ្ជាក់ពីសកម្មភាពរបស់ព្រះបាទទសរថ ដែលជា

www.elibraryofcambodia.org

ក្សត្រមួយព្រះអង្គដែលបានប្រកាន់ពាក្យសត្យ និងប្រវេណីក្សត្រត្រឹមត្រូវ ដែលអាចញ៉ាំងឱ្យព្រះនគរគេចផុតពីការកើតសង្គ្រាម បណ្ដារាស្ត្ររស់នៅប្រកបដោយសេចក្ដីសុខ សុភមង្គល។

- វិវត្តន៍អក្សរសិល្ប៍សម័យឯករាជ្យ អក្សរសិល្ប៍ខ្មែរសម័យនោះ អក្សរសាស្ត្រខ្មែរមានការរីកចម្រើនយ៉ាងខ្លាំងបំផុត ហើយប្រទេសជាតិក៏បានប្រែមុខមាត់ថ្មី ស្គាល់ឥស្សរភាពខ្មែរពិតប្រាកដ។

- អក្សរសិល្ប៍រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ អ្នកនិពន្ធបានបញ្ជាក់ពីភាពរីកចម្រើនជឿនលឿនក្នុងសម័យសង្គមរាស្ត្រនិយម ហើយពេលនោះអក្សរសាស្ត្រជាតិក៏រុងរឿងផងដែរ។

- វិវត្តអក្សរសិល្ប៍សម័យបច្ចុប្បន្ន អក្សរសិល្ប៍អក្សរសាស្ត្រជាតិមានការរីកចម្រើន នាំឱ្យប្រទេសជាតិមានភាពថ្កើងថ្កាន។

www.elibraryofcambodia.org

សរុបមតិ៖

រួមសេចក្ដីមក បើអក្សរសាស្ត្ររលត់ នោះប្រទេសជាតិនឹងត្រូវបាត់បង់នូវអត្តសញ្ញាណជាតិ វប្បធម៌ជាតិ តែបើអក្សរសាស្ត្រមានរស្មីត្រចះត្រចង់រុងរឿងហើយ ប្រទេសជាតិក៏មានកិត្យានុភាព រុងរឿង ស្ថិតស្ថេរគង់វង្សទៅតាមនោះដែរ។

៣. សេចក្ដីបញ្ចប់

បញ្ចប់មក ឆ្លងតាមការស្រាយបំភ្លឺ និងកសុតាងដូចដែលបានបញ្ជាក់ខាងលើ យើងអាចសន្និដ្ឋានបានថា មតិរបស់ប្រធានពិតជាមានតម្លៃ និងអត្ថន័យដ៏ជ្រាលជ្រៅបំផុត ដែលបានលើកយកមកបង្ហាញឱ្យឃើញពីសារៈសំខាន់របស់អក្សរសាស្ត្រ បានផ្ដល់ការអប់រំដាស់តឿនឱ្យស្រឡាញ់ និងលើកស្ទួយអក្សរសាស្ត្រជាតិខ្លួន។ ដូចនេះក្នុងនាមយើង..... ខិតខំការពារ ថែរក្សាអក្សរសាស្ត្រជាតិឱ្យបានរុងរឿង។

www.elibraryofcambodia.org

ប្រធានគំរូ៖ *ពំនោលមួយបានពោលថា "យុវជនជាទំពាំងស្នងឫស្សី"។ ចូរពន្យល់ពំនោលនោះឱ្យបានក្បោះក្បាយ។*

គម្រោង៖

បុព្វបុរសយើងគាត់បានឆ្លងកាត់បទពិសោធនៃជីវិតច្រើនរាប់មិនអស់ ជួនកាលល្អជួនកាលអាក្រក់ ដោយមើលឃើញពីភាពលំបាកទាំងនេះហើយ លោកក៏បានខិតខំចងក្រងស្នាដៃទុកជាមេរៀនបទពិសោធជីវិតដល់កូនចៅជំនាន់ក្រោយកុំឱ្យជួបឧបសគ្គ។ អាស្រ័យហេតុនេះហើយបានជាមានពំនោលមួយពោលថា "យុវជនជាទំពាំងស្នងឫស្សី"។

តើពំនោលខាងលើនេះមានអត្ថន័យដូចម្តេចខ្លះ?

មុននឹងធ្វើការបកស្រាយទស្សនៈខាងលើឱ្យបានក្បោះក្បាយ យើងគួរតម្លៃដោះស្រាយនូវពាក្យ "ស្នង" ជាមុនសិន។ "ស្នង" មានន័យថាជំនួសឱ្យអ្វីមួយ ឬក៏បន្តវេន បន្តតួនាទីដូចទំពាំងជាអ្នកបន្តវេន

www.elibraryofcambodia.org

ឱ្យបូស្សី ឯមនុស្ស ក្មេង ឬតូចបន្តវេន ឬជំនួសឱ្យ
មនុស្សធំ ឬចាស់។

ដូចនេះទស្សនៈរបស់ប្រធានចង់និយាយថា
នៅលើលោកយើងនេះពុំមានអ្វីជាអមតៈទេ ទោះបី
មនុស្ស សត្ត្ব រុក្ខជាតិតែងតែមានការផ្លាស់ប្តូរគ្នាជា
និច្ច ទៅតាមលក្ខណៈធម្មជាតិជាដាច់ខាត ពុំអាច
មាននរណាមួយអាចកែប្រែ ឬប្រឆាំងបានឡើយ។

- ទំពាំងជាកូនបូស្សីដើមខ្ចី ទន់ ផុយ ងាយបាក់
និងងាយបត់បែន។

- សារៈសំខាន់នៃទំពាំង គឺសម្រាប់យកទៅធ្វើ
ម្ហូបអាហារ និងធ្វើថ្នាំព្យាបាលនៃជំងឺខ្លះៗ ដើម្បី
បំបាត់ការឈឺចាប់ ដូចជារលាកជាដើម។

- បូស្សី ភ្លាយមកពីទំពាំងមានដើមរឹងមាំ ធំ
ហើយវែង។

បូស្សីអាចយកមកបម្រើការបានយ៉ាងច្រើន
ដូចជាគ្រឿងសំណង់ផ្សេងៗ ធ្វើជាឧបករណ៍
នេសាទ ធ្វើជាឧបករណ៍តន្ត្រី ដូចជារនាម ប៊ី ផ្លែទ្រ
... និងធ្វើគ្រឿងសាស្ត្រាវុធជាដើម។

www.elibraryofcambodia.org

- តម្លៃរមរ៉ាងទំ៖ាំងនិងបូស្សី

បូស្សីមានតម្លៃល្អពិតលុះត្រាតែមិនវៀច មិនខ្ចូច មិនពុក។ បើចង់បានបូស្សីល្អលុះត្រាតែថែទំ៖ាំងបានល្អដែរ។

- ប្រៀបធៀបបូស្សីទៅនឹងមនុស្ស

- យុវជនជាមនុស្សនៅក្មេងខ្ចី ខ្ចីទាំងរាងកាយ ខ្ចីទាំងចិត្តគំនិត ងាយបត់បែន (គ្មានបទពិសោធ) ពុំទាន់ផ្តល់តម្លៃអ្វីល្អដល់សង្គមនៅឡើយទេ។

- ផុតវ័យនេះនឹងក្លាយទៅជាពលរដ្ឋដែលពេញលក្ខណៈ: មានប្រយោជន៍ច្រើនដល់សង្គមជាតិ។

- ទាញលក្ខណៈអប់រំធៀបនឹងបូស្សីខ្ចូច

- ខ្ទះការអប់រំពីតូច ឬពីយុវវ័យ ជួនកាលក៏អាចផ្តល់ផលវិបាកដល់សង្គមនៅពេលគេធំពេញវ័យ មិនខុសអ្វីនឹងបូស្សីដែលខ្ចូចនោះទេ។

- ការអប់រំពុំទាន់ដល់កម្រិត ទទួលផលមកវិញក៏បានតិចដែរ។

- ជួនកាលអាចឱ្យគេក្លាយជាជនមិនល្អក្នុងសង្គម ក្លាយជាឧបសគ្គ៖ាំងស្ទះដល់ការរីកចម្រើន

www.elibraryofcambodia.org

នៃប្រទេសជាតិ ដូចជាជនពាល សេពគ្រឿងញៀន ជាជនពុករលួយ ក្បត់ជាតិ....។

-ដូច្នេះដើម្បីឱ្យយុវជនក្លាយជាមនុស្សមានប្រយោជន៍ដល់សង្គម យើងត្រូវអប់រំគេឱ្យបានដិតដល់ទាំងផ្លូវកាយទាំងផ្លូវចិត្ត ឱ្យមានសុខភាពល្អ កម្លាំងមាំមួន ប្រាជ្ញាឈ្លាសវៃ សតិអារម្មណ៍ស្អាតស្អំ ស្រឡាញ់ជាតិមាតុភូមិ ប្រៀបដូចឫស្សីល្អមានសារៈសំខាន់ដល់មនុស្សដែរ។

សរុប

ទំពាំងល្អនាំឱ្យឫស្សីល្អ។

យុវជនស្នងពលរដ្ឋ យុវជនមានការអប់រំល្អ នាំឱ្យគេក្លាយជាពលរដ្ឋល្អ ជនល្អជាធនធានមនុស្សដ៏ល្អដល់សង្គមជាតិ។

យោបល់បញ្ចប់ៈ

មតិរបស់ប្រធានមានលក្ខណៈល្អត្រឹមត្រូវ ព្រោះថា មានលក្ខណៈអប់រំកែប្រែមនុស្សឱ្យខិតខំប្រឹងប្រែងកសាងខ្លួនឱ្យបានល្អ ហើយមានសាមគ្គីភាពរវាងគ្នានឹងគ្នា។

www.elibraryofcambodia.org

ឯកសារពិគ្រោះ

ចាប ពិន (២០០៤) *អធិប្បាយសុភាសិតខ្មែរ* ប្រមូលចងក្រងដោយលោក ហ៊ីង គឹមថន។

ឆាយ ប៊ុនឡាយ (១៩៩៤) *តែងសេចក្តីថ្នាក់ទី១១* ។

ឆាយ សុខៃ (២០១២) *ស្វែងយល់ពីក្បួនតែងសេចក្តីខ្មែរ*។

ពូន សឹម (១៩៦៨) *អធិប្បាយ រឹតវ៉ែកសុភាសិតហរមបុរាណ* បោះផ្សាយ: បណ្ណាគារសេង ស៊ុនឌឿន។

លាង ហាប់អាន (?) *ប្រជុំវិធីសាស្ត្រតែងសេចក្តីគំរូសម្រាប់ថ្នាក់ទី៥.៤.៣ទំនើប* ភ្នំពេញ:បណ្ណាគារ មាយើង ។

លាង ហាប់អាន (១៩៦៦) *សិក្សាអត្ថបទ(សិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ)* ភ្នំពេញ:ពោធិ៍ពុម្ព សឹងហេង។

www.elibraryofcambodia.org

សៃ សារ (១៩៦៣) *វិជ្ជានិពន្ធន៍ខ្មែរចម្រុះ* ភ្នំពេញ: បណ្ណាគារភ្នំពេញ។

សៃ សារ (១៩៧០) *បរិមាធិប្បាយពិសេស* ភ្នំពេញ: បណ្ណាគារភ្នំពេញ។

សៃ សារ, ថោង ថៃ និងដទៃទៀត (១៩៧២) *វិញ្ញាសាតែងសេចក្តីគ្រូ* ភ្នំពេញ :បណ្ណាគារមាយើង ។

ស៊ីត សុធា និងពន់ រាយ (២០១០) *វិជ្ជានិពន្ធ* ភ្នំពេញ: សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធីខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្តេនជា eBook ដោយ សៀង ស៊ីវ៉ាន់
ខែមិថុនា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្ថែមទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្ចៅ ឃុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

☞ សៀវភៅនេះមាន

- ➢ ប្រាប់ពីវិធីសាស្ត្រធ្វើតែងសេចក្តី ជាពិសេសគឺប្រធានពន្យល់
- ➢ ប្រធានគំរូមាន២០ប្រធាន
- ➢ ប្រធានធ្លាប់ចេញក្នុងការប្រឡងមាន ៣ប្រធាន

☞ ប្រធានពិតាអក្សា

នឹងចេញផ្សាយតាប៉ានេះហើយ!

សូមទាក់ទងតាមទូរស័ព្ទលេខ៖

០១២ ៤៥ ២១ ០៦

០១៦ ៧២ ៥៤ ៨៤

www.elibraryofcambodia.org